ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# សិក្សាសង្គម

សម្រាប់

## កម្រិតបឋមសិក្សា

២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៥០៥ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា
# កម្រិតបឋមសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សា**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សានេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្ដីផ្ដើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សាជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលនិងក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតបឋមសិក្សា បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតបឋមសិក្សា សំដៅបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

វត្ថុបំណងនៃការធ្វើកំណែលម្អកម្មវិធីសិក្សា គឺត្រូវពិនិត្យឡើងវិញនូវកម្មវិធីសិក្សាចាស់ដើម្បីធ្វើបច្ចុប្បន្នកម្មឱ្យស្របតាមសេចក្តីត្រូវការរបស់អ្នកសិក្សា សហគមន៍ ប្រទេសជាតិ និងឱ្យស្របតាមបរិបទនៃដំណើរវិវឌ្ឍរបស់ពិភពលោក។

សិក្សាសង្គមគឺជាបណ្តុំមុខវិជ្ជាផ្នែកសង្គមសាស្ត្រនិងមនុស្សសាស្ត្រ។ មុខវិជ្ជាសិក្សាសង្គមមានគោលបំណងពង្រឹងនិងពង្រីកសមត្ថភាពរបស់សិស្សានុសិស្សដែលជាប្រជាពលរដ្ឋសកម្មរបស់ប្រទេសជាតិតាមរយៈការតម្រង់ទិសការសិក្សាអំពីទ្រឹស្តីនិងការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងអត្តសញ្ញាណ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ សេដ្ឋកិច្ច និងនយោបាយ។

បណ្តុំមុខវិជ្ជាសិក្សាសង្គមមានមុខវិជ្ជារង: ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា និងគេហសេដ្ឋកិច្ចវិទ្យា។

ការសិក្សាមុខវិជ្ជាសិក្សាសង្គម គឺធានាឱ្យសិស្ស៖

- ទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាទាក់ទងនឹងសីលធម៌ អត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ សេដ្ឋកិច្ច និងនយោបាយក្នុងប្រទេសនិងក្នុងតំបន់។
- អភិវឌ្ឍបំណិនពលរដ្ឋពាក់ព័ន្ធទៅនឹងតួនាទីនិងការទទួលខុសត្រូវក្នុងនាមជាសិស្សនិងជាពលរដ្ឋ នៅក្នុងសាលារៀន គ្រួសារ សហគមន៍ សង្គមជាតិ និងលើឆាកអន្តរជាតិ។
- ប្រើប្រាស់ចំណេះដឹងនិងបំណិនដែលបានមកពីការសិក្សាមុខវិជ្ជានានានៅក្នុងបណ្តុំមុខវិជ្ជាសិក្សាសង្គមសម្រាប់ការរៀនសូត្រនិងការរស់នៅប្រចាំថ្ងៃ។
- ស្រឡាញ់ជាតិ ធម្មជាតិ សាសនា និងព្រះមហាក្សត្រ ក្នុងនាមជាពលរដ្ឋមានការចេះដឹង និងការទទួលខុសត្រូវមានមោទនភាពជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ។
- មានសមត្ថភាពក្នុងការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចផ្ទាល់ខ្លួន គ្រួសារ សហគមន៍ និងសង្គមជាតិតាមរយៈការបណ្តុះវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពាក់ព័ន្ធនឹងការច្នៃប្រឌិតផលិតផល ការរៀបចំជំនួញបំណិនផ្នែកគណនេយ្យ អាជីវកម្ម សហគ្រាសធុនតូច ការសិក្សាទីផ្សារ ការសិក្សាពីចរាចរណ៍ទំនិញចរាចរណ៍មូលបត្រ និងសហគ្រិនភាព។

ម៉ោងសិក្សាទាំង៤មុខវិជ្ជារងនៃមុខវិជ្ជាសិក្សាសង្គមនៅកម្រិតបឋមសិក្សាមាន៣ម៉ោងសិក្សាក្នុងមួយសប្តាហ៍សម្រាប់ការបង្រៀននិងរៀន។

អនុគណៈកម្មការមុខវិជ្ជាឯកទេសសិក្សាសង្គម រំពឹងថា កម្មវិធីសិក្សាលម្អិតនេះនឹងក្លាយជាឯកសារគោលជាបង្អែកសម្រាប់ការនិពន្ធសៀវភៅសិស្សនិងសៀវភៅគ្រូពីថ្នាក់ទី១ដល់ទី៦ រួមទាំងជាត្រីវិស័យចង្អុលទិសសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់រៀននិងសាលារៀនប្រកបដោយគុណភាព។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសសិក្សាសង្គម**

# មាតិកា


ប្រកាស.......................................................................................................... i
បុព្វកថា.......................................................................................................... iii
អារម្ភកថា.......................................................................................................... iv
មាតិកា.......................................................................................................... v
១- សេចក្តីផ្តើម.......................................................................................................... 1
២- គោលបំណង.......................................................................................................... 1
៣- គោលគំនិតសំខាន់ៗ.......................................................................................................... 3
៤- របាយម៉ោងសិក្សា.......................................................................................................... 4
៥- ការណែនាំអនុវត្ត.......................................................................................................... 4
៦- ការវាយតម្លៃ.......................................................................................................... 5
៧- តារាងកម្មវិធីសិក្សា.......................................................................................................... 7
៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១.......................................................................................................... 7
៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី២.......................................................................................................... 18
៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៣.......................................................................................................... 28
៧.៤- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៤.......................................................................................................... 39
៧.៥- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៥.......................................................................................................... 52
៧.៦- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៦.......................................................................................................... 66
៨- ឯកសារយោង.......................................................................................................... 82
៩- បញ្ជីឈ្មោះគណៈកម្មការ.......................................................................................................... 84

## ១- សេចក្តីផ្តើម

ក្នុងបរិបទសកលភាវូបនីយកម្ម ពិភពលោកមានការវិវត្តជឿនលឿនយ៉ាងឆាប់រហ័ស ជាពិសេស ភាពទំនើបកម្ម ផ្នែកបច្ចេកវិទ្យា ធ្វើឱ្យសន្ទុះនៃការប្រកួតប្រជែងសេដ្ឋកិច្ច-សង្គម មានល្បឿនលឿនខ្លាំងក្លា ស្ទើរពេញពិភពលោក។ ភាពទំនើបជឿនលឿនប្រកបដោយសីលធម៌ ក្នុងការប្រកួតប្រជែងលើវិស័យ បច្ចេកវិទ្យា និងសេដ្ឋកិច្ចសង្គម នេះជាកម្លាំងរុញច្រានមួយដ៏ខ្លាំងមហាសាលដែលច្រានសង្គមជាតិ និងពិភពលោកឆ្ពោះទៅរកវឌ្ឍនភាព ភាពសុខ ដុមរមនា និងសន្តិភាពក្នុងពិភពលោកទាំងមូល។

កម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គមធានាការអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាព រីកចម្រើនគ្រប់ផ្នែកដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការ ស្នេហាជាតិ មនុស្សជាតិទាំងអស់ ដើម្បីអភិវឌ្ឍជាតិ និងធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

## ២- គោលបំណង

គោលបំណងរួមនៃការអប់រំមុខវិជ្ជាសិក្សាសង្គមនៅកម្រិតបឋមសិក្សា គឺការអប់រំសិស្សឱ្យស្គាល់ពីតម្លៃការទទួល ខុសត្រូវលើសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន មានការជឿជាក់លើខ្លួនឯង មានឥរិយាបថវិជ្ជមានជាមួយអ្នកដទៃ មានសីលធម៌ សុជីវធម៌ក្នុងការរស់នៅល្អ ចេះដោះស្រាយបញ្ហានៅក្នុងគ្រួសារ សហគមន៍ សង្គមជាតិ និងមានទំនាក់ ទំនងល្អជាមួយមនុស្សដទៃ។

មុខវិជ្ជានេះ មានបំណងចង់ឱ្យសិស្ស ចូលរួមថែរក្សាវប្បធម៌ អរិយធម៌ អត្តសញ្ញាណជាតិ ព្រមទាំងមានចំណេះ ដឹងអំពីសិទ្ធិកុមារ ច្បាប់សំខាន់ៗរបស់ប្រទេស។ ការសិក្សាមុខវិជ្ជានេះនឹងធ្វើឱ្យសិស្សមានការយល់ដឹងអំពីជីវភាពរស់ នៅក្នុងសង្គម បណ្តុះការយល់ដឹងនិងក្តីស្រឡាញ់ចំពោះទឹកដី បណ្តុះស្មារតីភាពជាពលរដ្ឋសកល ដែលមានចរិក លក្ខណៈមូលដ្ឋានចាំបាច់ ក្នុងនាម ជាអ្នកកសាងសង្គមប្រជាធិបតេយ្យប្រកបដោយសន្តិភាព សម្រាប់ការរស់នៅក្នុង សង្គមជាតិ និងពិភពលោក។

ផ្តើមចេញពីការយល់ដឹងពីតម្លៃសីលធម៌ នឹងនាំឱ្យសិស្ស គោរពប្រតិបត្តិច្បាប់របស់ប្រទេស ដើម្បីចូលរួមថែរក្សា សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ មិនប្រព្រឹត្តអំពើអវិជ្ជមានដែលសង្គមស្អប់ខ្ពើម ព្រមទាំងចូលរួមកសាងវប្បធម៌ សន្តិភាព អភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព និងយល់ដឹងអំពីទំនាក់ ទំនងល្អជាមួយមនុស្សនៅលើពិភពលោក។ តាមរយៈការចូលរួមសកម្មភាពសិក្សា និងការអនុវត្តជាប្រចាំ ដែលធ្វើឱ្យសិស្សយល់ដឹងអំពីសកម្មភាពផ្សេងៗក្នុងន័យ ការពារសុវត្ថិភាព ជីវភាពរស់នៅប្រកបដោយ ផាសុកភាព បរិស្ថានរស់នៅដ៏ល្អ និងឱ្យសិស្សដឹងខ្លួនថា ខ្លួនជាសមាជិក ម្នាក់របស់សង្គម។

មុខវិជ្ជាសិក្សាសង្គមមានគោលបំណងបណ្តុះសិស្ស ៖

- ឱ្យមានចំណេះដឹងទាក់ទងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ច្បាប់ ទំនៀមទម្លាប់ នយោបាយកម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់
- ជាពលរដ្ឋមានបំណិនទាក់ទងនឹងតួនាទីក្នុងការទទួលខុសត្រូវក្នុងនាមជាសិស្ស ជាពលរដ្ឋនៅក្នុង សាលារៀន គ្រួសារ សហគមន៍ សង្គមជាតិ
- ឱ្យប្រើប្រាស់ចំណេះដឹង និងបំណិនដែលបានមកពីការសិក្សាមុខវិជ្ជានានានៅក្នុងមុខវិជ្ជាសិក្សាសង្គម សម្រាប់ការរៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ
- ស្រឡាញ់ជាតិ ធម្មជាតិ សាសនា និងព្រះមហាក្សត្រក្នុងនាមជាពលរដ្ឋដែលមានការចេះដឹង និង ការទទួលខុសត្រូវ មានមោទនភាពចំពោះជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ
- ការយល់ដឹងអំពីការរក្សាសុវត្ថិភាពរាងកាយ សុចរិតភាព យុត្តិធម៌ សិទ្ធិកុមារ

- ការយល់ដឹងអំពីភូមិសាស្ត្រ ប្រវត្តិសាស្ត្រនៅក្នុងប្រទេស ប្រទេសនៅក្នុងតំបន់ និងលើពិភពលោក
- សមត្ថភាពគិតពិចារណាអំពីលក្ខណៈពិសេសនៃបាតុភូតសង្គមក្នុងតំបន់ និងទំនាក់ទំនងទៅមក ព្រមទាំងបណ្តុះសមត្ថភាពស្តែងចេញពីអ្វីដែលបានគិត និងបានស្រាវជ្រាវផងដែរ
- ចំណាប់អារម្មណ៍ទៅលើកម្មវិធីបុណ្យជាតិនីមួយៗ និងពិចារណាអំពីអត្ថន័យនៃបុណ្យទាំងនោះ
- ការយល់ដឹងអំពីរបបនយោបាយ រដ្ឋធម្មនុញ្ញ និងទំនាក់ទំនងរវាងរដ្ឋសភា រដ្ឋាភិបាល និងតុលាការ។

ដើម្បីសម្រេចគោលបំណងរួមនៃការអប់រំមុខវិជ្ជាសិក្សាសង្គមនៅកម្រិតបឋមសិក្សា សិស្សទទួល បានសមាសភាគបីសំខាន់ៗជាមូលដ្ឋានដូចខាងក្រោម៖

### ១- វិជ្ជាសម្បទា

- យល់ដឹងពីខ្លួនឯង គ្រួសារ ទំនាក់ទំនងល្អជាមួយមនុស្សនៅជុំវិញខ្លួន និងការរៀបចំខ្លួនប្រកបដោយសុជីវធម៌ សីលធម៌
- ស្វែងយល់អំពីផលប៉ះពាល់នៃការគំរាមកំហែងដល់កុមារ និងរកវិធីដោះខ្លួនឱ្យរួចផុតពីការគំរាមកំហែង
- មានចំណេះដឹងអំពីសិទ្ធិ សិទ្ធិកុមារ និងទំនួលខុសត្រូវ រកវិធីឱ្យចៀសផុតពីការរំលោភបំពានលើសិទ្ធិកុមារ និងការកំណត់ជ្រើសរើសមុខរបរសម្រាប់អនាគត
- យល់ដឹងពីរចនាសម្ព័ន្ធនៃរដ្ឋបាលមូលដ្ឋាន រដ្ឋាភិបាល ស្ថាប័នតុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន
- ស្គាល់អំពីប្រវត្តិនៃជំនឿសាសនាផ្សេងៗ និងយល់ដឹងទំនាក់ទំនងរវាងសាសនា និងសង្គម
- ស្វែងយល់ពីឥរិយាបថខ្មែរ ពិធីបុណ្យបែបសាសនា ពិធីរៀបអាពាហ៍ពិពាហ៍ ទំនាក់ទំនងមិត្តភាព និងការដោះស្រាយទំនាស់ដោយសន្តិវិធី
- យល់ដឹងអំពីទំនាក់ទំនងល្អរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសនានានៅក្នុងតំបន់ និងលើពិភពលោក។

### ២- បំណិនសម្បទា

- ស្គាល់តម្លៃជាមនុស្សដែលមានគុណធម៌ និងការទទួលខុសត្រូវក្នុងការរស់នៅ
- អនុវត្តតាមច្បាប់ជាតិនិង ដើម្បីចូលរួមជួយថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងអភិវឌ្ឍសង្គម
- ប្រើប្រាស់បំណិនរបស់ខ្លួនក្នុងការសម្រេចចិត្តជ្រើសរើសអាជីពនានាពេលអនាគតបានត្រឹមត្រូវ
- អនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ
- វិភាគអំពីសារៈសំខាន់នៃតួនាទីរបស់សាសនានៅក្នុងសង្គម
- បង្ហាញវិធីផ្សេងៗក្នុងការកំសាន្ត ដោយចៀសវាងមិនប្រើប្រាស់គ្រឿងញៀន
- ពណ៌នាការទទួលខុសត្រូវរបស់ស្ថាប័ន នីតិបញ្ញត្តិ និតិប្រតិបត្តិ តុលាការ និងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន
- អនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនក្នុងនាមជាប្រជាពលរដ្ឋ
- មានបំណិនសំខាន់ៗក្នុងការគ្រប់គ្រងគ្រួសារ មានទំនាក់ទំនងល្អជាមួយអ្នកដទៃក្នុងសហគមន៍ និងប្រទេសជាតិ
- វិភាគ និងឆ្លុះបញ្ចាំងពីសារៈសំខាន់នៃទំនាក់ទំនងល្អជាមួយប្រទេសផ្សេងៗនៅលើពិភពលោក។

### ៣- ចរិយាសម្បទា

- ឱ្យតម្លៃលើខ្លួនឯង និងឱ្យតម្លៃដល់អ្នកដទៃ

- ប្រកាន់ខ្ជាប់នូវតម្លៃសីលធម៌ សុជីវធម៌ និងគុណធម៌
- បណ្ដុះស្មារតីចូលរួមចំណែកជួយអភិវឌ្ឍសហគមន៍ និងសង្គមជាតិ
- មានការទទួលខុសត្រូវក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ
- ស្រឡាញ់ជីវិតរបស់ខ្លួន និងក្រុមគ្រួសារដោយមិនប្រើប្រាស់គ្រឿងញៀន
- គោរពសេរីភាពនៃជំនឿសាសនារបស់អ្នកដទៃ
- មានសីលធម៌ និងការទទួលខុសត្រូវក្នុងការរស់នៅ
- មានការផ្លាស់ប្ដូរឥរិយាបថជាវិជ្ជមានក្នុងសកម្មភាពរស់នៅជាប្រចាំ
- មានការទទួលខុសត្រូវក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ
- គោរពច្បាប់ សិទ្ធិមនុស្ស និងបំពេញកាតព្វកិច្ចជាប្រជាពលរដ្ឋល្អ
- គោរព ឱ្យតម្លៃសេរីភាពនៃជំនឿសាសនា និងការប្រតិបត្តិសាសនារបស់អ្នកដទៃ
- រក្សាអត្តសញ្ញាណជាតិក្នុងទំនាក់ទំនងជាមួយអន្តរជាតិ។

## ៣- គោលគំនិតសំខាន់ៗ

មុខវិជ្ជាសិក្សាសង្គម ត្រូវបានកំណត់គោលគំនិតសំខាន់ពីរគឺៈ ស្ថានភាពសង្គមបច្ចុប្បន្ន និងដំណោះស្រាយ ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សឱ្យទទួលបានចំណេះដឹង បំណិន ក្នុងការដោះស្រាយបញ្ហានានា ក្នុងគ្រួសារ សហគមន៍ សង្គមជាតិ តំបន់ និងពិភពលោកដោយមានការទទួលខុសត្រូវ។

### ៣.១- ស្ថានភាពសង្គមបច្ចុប្បន្ន

ស្ថានភាពសង្គមបច្ចុប្បន្នផ្ដោតលើប្រធានបទទាក់ទងនឹងៈ

- តម្លៃមនុស្ស និងតម្លៃគ្រួសាររួមមានៈ សីលធម៌ សុជីវធម៌  ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការសម្រេចចិត្ត តម្លៃបញ្ញា ពលរដ្ឋល្អស្អាតស្អំ សេចក្ដីត្រូវការ និងមហិច្ឆតា គោលដៅនិងមធ្យោបាយក្នុងការប្រឆាំងអំពើពុករលួយ
- ទំនាក់ទំនងល្អក្នុងសហគមន៍ដូចជាៈ ការជួយកែលម្អគ្នា សុភមង្គលគ្រួសារ សិទ្ធិ និងករណីយកិច្ច សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិរក្សាអត្តសញ្ញាណ កម្មសិទ្ធិ កិច្ចការពារសិទ្ធិរបស់ខ្លួន តួនាទី និងភារកិច្ចរបស់តុលាការ ច្បាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ព្រមទាំងកិច្ចការពារបរិស្ថាន
- វប្បធម៌ និងសាសនា
- សង្គមជាតិយើងរួមមានៈ ការងារ និងយុវជន សន្តិភាព និងទំនាស់។

### ៣.២- ដំណោះស្រាយ

ដំណោះស្រាយ និងវិភាគលើបញ្ហាដែលកើតមាននៅក្នុងស្ថានភាពសង្គមបច្ចុប្បន្នផ្ដោតទៅលើៈ

- ការផ្លាស់ប្ដូរផ្នត់គំនិតមនុស្សអវិជ្ជមានទៅជាវិជ្ជមានប្រែក្លាយជាពលរដ្ឋល្អក្នុងសង្គម
- គ្រួសារ សហគមន៍ សង្គមជាតិ តំបន់ ពិភពលោក នាំឱ្យមានការរស់នៅក្នុងភាពសុខដុមនីយកម្ម សន្តិភាព និងអភិវឌ្ឍប្រកបដោយនិរន្តរភាព។

## ៤- របាយម៉ោងសិក្សា

| ថ្នាក់ទី | ចំនួនសប្តាហ៍ក្នុង១ឆ្នាំ | ចំនួនម៉ោងក្នុង១សប្តាហ៍ | ចំនួននាទីក្នុងម៉ោងសិក្សា | ចំនួនម៉ោងក្នុង១ឆ្នាំសិក្សា |
|---|---|---|---|---|
| ១-៦ | ៣៥ | ៣ | ៤០នាទី | ១០៥ម៉ោង |

## ៥- ការណែនាំការអនុវត្ត

ដើម្បីអនុវត្តកម្មវិធីសិក្សាសិក្សាសង្គម ឱ្យបានជោគជ័យគ្រូត្រូវ៖

- រៀបចំសកម្មភាពរៀន និងបង្រៀនដោយបែងចែកតាមក្រុមនៅក្នុងថ្នាក់
- ដើរតួជាអ្នកសម្របសម្រួល និងជួយសិស្សខ្សោយឱ្យបានច្រើន
- បញ្ជ្រាបតម្លៃការអប់រំពលរដ្ឋសាកលនៅគ្រប់សកម្មភាពបង្រៀននិងរៀនតាមមេរៀនទាំងអស់ក្នុងកម្មវិធីសិក្សា
- ណែនាំសិស្សឱ្យចេះអង្កេតតាមលក្ខណៈវិទ្យាសាស្ត្រជាមូលដ្ឋាន ដើម្បីទទួលបានព័ត៌មាន និងផ្តល់ព័ត៌មានដោយផ្សារភ្ជាប់ដំណោះស្រាយបញ្ហាជាក់ស្តែងក្នុងសហគមន៍
- ជំរុញនិងលើកទឹកចិត្តសិស្សឱ្យចូលរួមធ្វើសកម្មភាពសិក្សាផ្សេងៗដូចជា ការចូលរួមក្នុងល្បែងសិក្សា ការដើរតួ ការឡើងធ្វើបទបង្ហាញតាមក្រុម និងរកអំណះអំណាង ការពារគំនិតរបស់ខ្លួន
- បង្រៀនពីងាយទៅលំបាក ពីរូបី ពាក់កណ្តាលរូបី ទៅអរូបី និងមានភាពងាយស្រួល ចៀសវាងប្រើពាក្យពេចន៍ ដែលមិនសមស្របតាមវ័យរបស់សិស្ស
- ប្រើសម្ភារឧបទេស និងការអនុវត្តគំរូឱ្យបានជាអតិបរមា
- បង្ហាញរូបគំរូ ណែនាំសិស្សឱ្យសង្កេត និងដាក់សម្ភារៈសម្រាប់ធ្វើនៅចំពោះមុខសិស្ស
- ណែនាំសិស្សឱ្យរកសម្ភារៈ និងព័ត៌មានត្រៀមទុកមុនការបង្រៀនមេរៀន
- ជំរុញ និងលើកទឹកចិត្តដល់សិស្សឱ្យហ៊ានសួរសំណួរ និងដាក់បញ្ហាដើម្បីដោះស្រាយ
- បណ្តុះស្មារតីសិស្សឱ្យចេះស្រាវជ្រាវ វិភាគ ពិចារណា សំយោគ ឆ្លុះបញ្ចាំង ច្នៃប្រឌិត បង្កើតថ្មី និងអនុវត្តក្នុងសហគមន៍របស់ខ្លួន។

### ៥.១- វិធីសាស្ត្របង្រៀន

- គោលការណ៍ទី១៖ការបង្រៀនផ្តោតលើសកម្មភាពសម្របសម្រួលក្នុងការសិក្សារបស់សិស្ស ដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល។
- គោលការណ៍ទី២៖ការបង្រៀនផ្តោតលើសកម្មភាពជួយ និងលើកទឹកចិត្តសិស្សឱ្យចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងការទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹងដែលផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជា ការសហការ និងការអង្កេត។
- គោលការណ៍ទី៣៖ ការបង្រៀនត្រូវបន្តនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យសិស្សស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សា។

- គោលការណ៍ទី៤៖ ការបង្រៀនត្រូវផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត ក្នុងបរិស្ថានជុំវិញតាមរយៈការប្រើប្រាស់វិធីសាស្រ្ត និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្បូរបែប និងមានបច្ចុប្បន្នភាព។

### ៥.២- វិធីសាស្រ្តបង្រៀន

ដោយផ្អែកលើគោលការណ៍ទាំងអស់ខាងលើ គ្រូអនុវត្តវិធីសាស្រ្តផ្សេងៗដូចជា៖

- ការបង្រៀនមុខវិជ្ជាសិក្សាសង្គមអាចប្រព្រឹត្តទៅតាមវិធីសាស្រ្តខុសៗគ្នាអាស្រ័យលើល្បិចនិងភាពប៉ិនប្រសប់របស់គ្រូ ឱ្យស្របនឹងកម្រិតបញ្ញា មជ្ឈដ្ឋាន និងជីវភាពរស់នៅរបស់សិស្ស។
- ការបង្រៀនអាចផ្តល់ជាទ្រឹស្តី ការប្រតិបត្តិ ទស្សនកិច្ចសិក្សា ឆាកល្ខោនខ្លីៗ ការសម្តែងតួ និទានរឿង ឬសកម្មភាពផ្សេងទៀត ជាសកម្មភាពច្នៃប្រឌិតរស់រវើករបស់គ្រូដែលមាន លក្ខណៈជាក់ស្តែង និងការចូលរួមយ៉ាងសកម្មរបស់សិស្ស។
- ការបង្រៀនមុខវិជ្ជាសិក្សាសង្គមត្រូវបណ្តុះគំនិតស្រឡាញ់វប្បធម៌ជាតិ មានឥរិយាបថល្អ ទម្លាប់ល្អ សេចក្តីថ្លៃថ្នូររបស់ខ្លួន ចេះគិតពិចារណាសមហេតុផល ជាពលរដ្ឋមិនមានការរើសអើងជាតិសាសន៍ វប្បធម៌ សាសនា និងប្រត្តិបត្តិនូវអំពើល្អស្របតាមគោលការណ៍សីលធម៌ជាតិ និងសាកល។
- ការបង្រៀនមុខវិជ្ជាសិក្សាសង្គម គ្រូត្រូវប្រើវិធីសាស្រ្តទំនើបដូចជា វិធីពិភាក្សា វិធីសហការ វិធីសម្ភាសធ្វើបាឋកថា វិធីដោះស្រាយបញ្ហា(Problem Solving) ការសិក្សាស្រាវជ្រាវ មេរៀន (Lesson Study) ការសិក្សាតាមបែបរិះរក (Inquiry-base Learning)។
- ឧទាហរណ៍៖ ក្នុងការបង្រៀនមុខវិជ្ជាសិក្សាសង្គម យើងក៏អាចប្រើវិធិសិក្សាតាមបែបរិះរក ដែលមានយុទ្ធសាស្រ្តឆ្លើយតបយ៉ាងត្រឹមត្រូវនឹងគោលវិធីសិស្សមជ្ឈមណ្ឌល ដែលផ្តល់ឱកាសឱ្យសិស្ស ត្រិះរិះពិចារណា សង្កេត និងស្រាវជ្រាវដែលមានយុទ្ធវិធីលម្អិត៤ដំណាក់កាលដូចខាងក្រោម៖
  - **ការបង្កើតស្ថានភាព បញ្ហាដោយគ្រូ ឬសិស្ស៖** គ្រូត្រួតពិនិត្យការអនុវត្តកិច្ចការស្រាវជ្រាវ កិច្ចការផ្ទះដែលបានដាក់ឱ្យសិស្សធ្វើ និងចោទសំណួរទាក់ទងទៅនឹងមេរៀនប្រចាំថ្ងៃ
  - **វិធីស្វែងរកគំនិតដើម្បីដោះស្រាយបញ្ហាអំណះអំណាង) និងហេតុផល៖**(គ្រូឱ្យសិស្សធ្វើសកម្មភាពសង្កេតរូបភាពផ្សេងៗ និងធ្វើការពន្យល់បកស្រាយរូបភាព
  - **ផ្ទៀងផ្ទាត់វាយតម្លៃ(ការពន្យល់ពីអំណះអំណាងដែលប្រមូលបាន)៖** សិស្សពង្រីកខ្លឹមសារទិន្នន័យឱ្យទៅជាការអនុវត្តក្នុងសហគមន៍ខ្លួនដោះស្រាយតាមរយៈ ការវិភាគ សិក្សាប្រៀបធៀបបញ្ហាផ្សេងៗ។
  - **ការដោះស្រាយបញ្ហា ការសំយោគ ការសន្និដ្ឋាន សកម្មភាពផ្សព្វផ្សាយអំណះអំណាង) ពិតប្រាកដទទ្បីករណ៍ និងជាក់លាក់សម្រាប់ការពន្យល់** (៖ សិស្សសង្ខេបខ្លឹមសារសំខាន់ៗ បន្ទាប់មកឱ្យសិស្សធ្វើការស្រាវជ្រាវឯកសារផ្សេងៗទៀតតាមរយៈកិច្ចការផ្ទះ ស្រង់ប្រមូលលទិន្នន័យ ធ្វើជាតារាង ក្រាភិចដ្យាក្រាម ធ្វើការប្រៀបធៀប និងការស្វែងរកគំនិតបង្កើតថ្មី ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវផ្តោតលើ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយា សម្បទា។ ការវាយតម្លៃជាការវាស់ស្ទង់សមត្ថភាពសិស្សដើម្បីឱ្យដឹងថា លទ្ធផលនៃការសិក្សារបស់សិស្ស ទទួលបានកម្រិតណា សំដៅរកព័ត៌មានឬភស្តុតាងដើម្បីសន្និដ្ឋាន សម្រេចចិត្តនិងរកវិធីផ្តល់ធាតុចូល ដើម្បីជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្សនិងដំណើរការបង្រៀនរបស់គ្រូដោយផ្អែកលើកម្មវិធីសិក្សាលម្អិត និងស្តង់ដាកម្មវិធីសិក្សា ដែលជួយឱ្យដឹងថា

តើលទ្ធផលសិក្សារបស់សិស្សសម្រេចបានតាមកម្មវិធី សិក្សាលម្អិត ស្តង់ដាកម្មវិធីសិក្សាដែរឬទេ នៅពេលបង្រៀនចប់ខ្លឹមសារមេរៀននីមួយៗ។

ការវាយតម្លៃការរៀន និងបង្រៀនជាដំណើរការជានិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំង ភស្តុតាង អំពីកម្រិតសមត្ថភាពសិស្ស ក្រោយពីដំណើរការរៀននិងបង្រៀន ទាំងក្នុងថ្នាក់ទាំងក្រៅថ្នាក់ឱ្យឆ្លើយតប លទ្ធផលសិក្សាដែលបានរំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។

ការវាយតម្លៃត្រូវមានលក្ខណៈវិនិច្ឆ័យសមស្របទៅនឹងកម្រិតលទ្ធផលសិក្សានៃកម្រិតថ្នាក់នីមួយៗ។

### ៦.១- សារៈសំខាន់នៃការវាយតម្លៃ

ការវាយតម្លៃនៃការសិក្សារបស់សិស្សជាផ្នែកដ៏សំខាន់នៃការបង្រៀននិងរៀន។ ជាទូទៅការវាយតម្លៃមានសារៈសំខាន់ដូចខាងក្រោម៖

- វាស់កម្រិតចំណេះដឹង បំណិន ឥរិយាបថរបស់សិស្សក្រោយពីបានសិក្សាចប់ខ្លឹមសារមេរៀន ជំពូក ឬកម្មវិធីសិក្សាតាមថ្នាក់ និងតាមកម្រិតសិក្សានីមួយៗ
- វាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានាដូចជាតម្លៃសីលធម៌ ឥរិយាបថសាមគ្គីភាព ការស្រឡាញ់វប្បធម៌ ប្រពៃណីជាតិ។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងការបង្រៀនដោយផ្តល់ព័ត៌មានត្រឡប់ដល់គ្រូ សិស្ស មាតាបិតាឬអាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលារៀន និងអ្នកអប់រំ ដើម្បីជួយរកមធ្យោបាយលើកកម្ពស់គុណភាពនៃការរៀន និងការបង្រៀនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់
- ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស ក្នុងគោលបំណងកែលម្អឡើងវិញឱ្យទាន់ពេលនូវសកម្មភាពរៀននិងបង្រៀន
- ដើម្បីវាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាដំណាក់កាលៗ
- ដើម្បីផ្តល់ទិន្នន័យដែលជួយដល់ការធ្វើសេចក្តីសម្រេចចិត្តអំពីអនាគតរបស់សិស្សក្នុងការបន្តការសិក្សា។

### ៦.២- លក្ខខណ្ឌនៃការវាយតម្លៃ

ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃមានប្រសិទ្ធភាព ប្រកបដោយជោគជ័យ គ្រូត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី៖

- វត្ថុបំណងវង្វាយតម្លៃ (ដើម្បីអ្វី)
- សមត្ថភាព ឬបំណិនដែលត្រូវវាយតម្លៃ (លើអ្វី)
- កម្រិតវាយតម្លៃ (ត្រឹមណា)
- រូបភាពវង្វាយតម្លៃ (សំណេរ ផ្ទាល់មាត់ ការប្រតិបត្តិ ការសង្កេតផ្ទាល់)
- កាលបរិច្ឆេទវង្វាយតម្លៃ (ពេលណា)
- រយៈពេលវង្វាយតម្លៃ (ប៉ុន្មាននាទី ប៉ុន្មានម៉ោង)។

### ៦.៣- លំនាំនៃការវាយតម្លៃ

ការវាយតម្លៃ គឺផ្អែកតាមលំនាំដូចខាងក្រោម៖

- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ត្រូវផ្អែកតាមកម្រិតថ្នាក់នីមួយៗ
- ការវាយតម្លៃលទ្ធផលសិក្សាធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត
- ការវាយតម្លៃបញ្ចប់ភូមិសិក្សា ឬប្រឡងថ្នាក់ជាតិ។ល។

ការវាយតម្លៃត្រូវធ្វើឡើងដោយគ្រូបង្រៀនតាមថ្នាក់និងមុខវិជ្ជានីមួយៗក្នុងគោលបំណងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ ដោយផ្ដោតទៅលើចំណេះដឹង បំណិន និងឥរិយាបថទៅតាមមេរៀននីមួយៗ។ វិធីសាស្ត្រនៃការវាយតម្លៃមានដូចជា សំណួរផ្ទាល់មាត់ សំណួរសរសេរ ការពិភាក្សា ការសង្កេត កិច្ចការផ្ទះ ការប្រឡង និងគម្រោងស្រាវជ្រាវ

ដើម្បីវាយតម្លៃលទ្ធផលសិក្សាក្នុងថ្នាក់រៀននីមួយៗ។ គ្រូបង្រៀនត្រូវប្រមូល វិភាគ សំយោគ និងបកស្រាយលទ្ធផលនៃការវាយតម្លៃ ដើម្បីសម្រេចជ្រើសរើស និងកែសម្រួលវិធីសាស្ត្ររៀន និងបង្រៀន។

លទ្ធផលនៃការវាយតម្លៃនេះឆ្លុះបញ្ចាំងការបង្រៀន នឹងត្រូវប្រើប្រាស់សម្រាប់ការវាយតម្លៃ សាលារៀនផងដែរ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាម កម្រិតថ្នាក់នីមួយៗ ត្រូវធ្វើឡើងតាម ដំណាក់ដូចតទៅ៖

- ការវាយតម្លៃជាប្រចាំ៖ ធ្វើឡើងក្នុងពេលកំពុងបង្រៀនមេរៀននីមួយៗ
- ការវាយតម្លៃតាមដំណាក់៖ ធ្វើឡើងនៅពេលបញ្ចប់ដំណាក់តូចៗ នៃមេរៀនលើចំណេះដឹង បំណិន និងឥរិយាបថ
- ការវាយតម្លៃប្រចាំខែ និងប្រចាំឆមាស ៖ ធ្វើឡើងនៅពេលដំណាច់ខែ ឬបញ្ចប់ឆមាសនីមួយៗ នៃឆ្នាំសិក្សា។ គ្រូ និងគណៈគ្រប់គ្រងសាលារៀន គួរតែផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ ដល់សិស្ស និងមាតាបិតាសិស្សឬអាណាព្យាបាលសិស្ស អំពីលទ្ធផលសិក្សាដែលសិស្សទទួល បានទៅតាមដំណាក់កាលនីមួយៗ។ សិស្សត្រូវតែទទួលបានព័ត៌មានច្បាស់លាស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងជំហានដែលពួកគេត្រូវអភិវឌ្ឍបន្ត ដើម្បីខិតខំបង្កើនលទ្ធផលសិក្សារបស់ពួកគេឱ្យកាន់តែល្អប្រសើរឡើង ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១: គ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : គ្រួសារខ្ញុំ**<br>១.១- ការណែនាំខ្លួន<br>១.២- ការណែនាំសមាជិកក្នុងគ្រួសារ<br>១.៣- រចនាសម្ព័ន្ធគ្រួសារ<br>១.៤- ព័ត៌មានទាក់ទងនឹងគ្រួសារ | **វិជ្ជាសម្បទា**<br>- ណែនាំឱ្យស្គាល់ឈ្មោះ អាយុ និងមុខងាររបស់ខ្លួននៅក្នុងក្រុមគ្រួសារ។<br>- ពណ៌នាសមាជិកគ្រួសារ (ដោយប្រើពាក្យឪពុក ម្ដាយ បងប្អូនប្រុស បងប្អូនស្រី មីង ពូ អ៊ំប្រុសអ៊ំស្រី ជីដូនជីតា)។<br>- ប្រើរូបភាពងាយៗដើម្បីបង្ហាញរចនាសម្ព័ន្ធគ្រួសារ ឪពុក ម្ដាយ បងប្អូនប្រុស បងប្អូនស្រី (មើលតាមរូបដែលគ្រូគូរ)។<br>- ពណ៌នាសកម្មភាពសំខាន់ៗដែលគេចាប់អារម្មណ៍ក្នុងជីវភាពគ្រួសារកន្លងមក។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យគេស្គាល់ឈ្មោះ អាយុ និងមុខងាររបស់ខ្លួន។<br>- បង្ហាញរចនាសម្ព័ន្ធនៃគ្រួសាររបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់ សមាជិកក្រុមគ្រួសារ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី២** : **ជនគំរូក្នុងគ្រួសារ**<br>**សិក្សាបញ្ញត្តិ** : គំរូ គ្រួសារ លំដាប់លំដោយ តួនាទី<br>**មាតិកា** :<br>២.១- យាយ ឬ តា<br>២.២- ឪពុក ឬ ម្ដាយ<br>២.៣- បងប្រុស ឬ បងស្រី<br>**សំណួរត្រិះរិះ**:<br>• តើសមាជិកក្នុងគ្រួសារកូនស្រឡាញ់មួយណាជាងគេ? ព្រោះអ្វី?<br>• តើគាត់មាន សកម្មភាពអ្វីខ្លះដែលកូនចង់ធ្វើតាម? ព្រោះហេតុអ្វី? | **វិជ្ជាសម្បទា**<br>- បង្ហាញអំពីប្រវត្តិមនុស្សគំរូក្នុងគ្រួសារ។<br>**បំណិនសម្បទា**<br>- រៀបសមាជិកគ្រួសារតាមលំដាប់ពីចាស់មកក្មេង។<br>**ចរិយាសម្បទា**<br>- ប្រតិបត្តិតួនាទី និងភារកិច្ចក្នុងគ្រួសារ។ | ៥ម៉ |
| **មេរៀនទី៣** : **ការសិក្សារបស់ខ្ញុំ**<br>**សិក្សាបញ្ញត្តិ** : ប្រវត្តិការសិក្សា<br>**មាតិកា** :<br>៣.១- មត្តេយ្យកម្រិតទាប<br>៣.២- មត្តេយ្យកម្រិតមធ្យម<br>៣.៣- មត្តេយ្យកម្រិតខ្ពស់<br>៣.៤- ទីកន្លែង<br>៣.៥- ពេលវេលា<br>**សំណួរត្រិះរិះ**:<br>• មុនចូលរៀននៅទីនេះ តើកូន<br>• បានរៀនឬទេ? នៅឯណា? ប៉ុន្មានឆ្នាំ? រៀនជាមួយនរណា?<br>• តើប្អូនចងចាំសកម្មភាពអ្វីខ្លះស្ដីពីការរៀននោះ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការសិក្សានៅមត្តេយ្យសិក្សា ឬតាមផ្ទះ។<br>**បំណិនសម្បទា**<br>- កំណត់ពីចំនួនឆ្នាំដែលបានសិក្សានៅមត្តេយ្យសិក្សា។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ការសិក្សា មិត្តភក្តិ និងលោកគ្រូអ្នកគ្រូ។ | ៦ម៉ |
| **មេរៀនទី៤** : **កន្លែងដែលខ្ញុំរស់នៅ**<br>៤.១- គូរនិងផាត់ពណ៌រូបផ្ទះ<br>៤.២- ផ្ទះខ្ញុំធ្វើអំពី<br>៤.៣- សម្ភារៈក្នុងផ្ទះខ្ញុំ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីផ្ទះរបស់ខ្លួន ទីតាំង និងតំបន់ជុំវិញ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីរបៀបគូរ និងផាត់ពណ៌។<br>- ស្វែងរកបញ្ហាដែលមាននៅជុំវិញផ្ទះ។ | ៧ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ថែរក្សា និងទុកដាក់ សម្ភារៈក្នុងផ្ទះ។<br>- ស្វែងរកវិធីដោះស្រាយបញ្ហា។ | |
| **មេរៀនទី៥** : **ប្រដាប់ប្រដាសិក្សារបស់ខ្ញុំ**<br>៥.១- រូបភាពសៀវភៅអាន សៀវភៅសរសេរ ខ្មៅដៃ បន្ទាត់ ជ័រលុប នៅលើតុ<br>៥.២- រូបភាពរបស់ប្រប្រាស់ខាងលើនៅក្នុងកាតាប<br>៥.៣- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញវិធីទុកដាក់ប្រដាប់ប្រដាសិក្សាទៅក្នុងកាតាប។<br>**បំណិនសម្បទា**<br>- ចេះរៀបចំទុកដាក់របស់ប្រើប្រាស់ផ្ទាល់ខ្លួនឱ្យស្ថិតនៅតាមកន្លែងរបស់វា។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ទុកដាក់ប្រដាប់ប្រដា ប្រើប្រាស់ឱ្យស្ថិតនៅ តាមកន្លែងរបស់វា។ | ២ម៉ |
| **មេរៀនទី៦** : **បត់ក្រដាសជារូបចាប**<br>៦.១- រូបភាពការបត់ក្រដាសតាមដំណាក់<br>៦.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញវិធីបត់ក្រដាសជារូបចាប។<br>**បំណិនសម្បទា**<br>- ចេះបត់ក្រដាសធ្វើជារូបចាប។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការផលិតស្នាដៃមួយដោយការបត់ក្រដាស។ | ១ម៉ |
| **មេរៀនទី៧** : **កាត់ក្រដាសបិទផ្គុំធ្វើរូបផ្កា**<br>៧.១- រូបភាពការកាត់បិទជារូបផ្កាតាមដំណាក់<br>៧.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញវិធីកាត់ក្រដាស និងបិទផ្គុំជារូបផ្កា។<br>**បំណិនសម្បទា**<br>- ចេះកាត់បិទផ្គុំក្រដាសជារូបផ្កា។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការផលិតស្នាដៃមួយដោយការ កាត់ក្រដាស និងបិទផ្គុំ។ | ១ម៉ |
| **មេរៀនទី៨** : **ខ្ញុំអាចធ្វើបាន**<br>៨.១- សមត្ថភាពនិងអំពើល្អរបស់ខ្លួន<br>៨.២- ចរិតលក្ខណៈផ្ទាល់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានអ្វីដែលខ្លួនអាចធ្វើបាន និងអំពើល្អរបស់ខ្លួន (ឧ. ខ្ញុំពូកែខាងរត់ ឬចូលចិត្តជួយអ្នកដទៃ)។<br>- ពណ៌នាចរិតលក្ខណៈផ្ទាល់ខ្លួន។<br>**បំណិនសម្បទា**<br>- បង្ហាញសមត្ថភាពអំពើល្អរបស់ខ្លួន និងរបស់អ្នកដទៃ។<br>- វិនិច្ឆ័យចរិតលក្ខណៈផ្ទាល់ខ្លួន ( ឧ. ការចូលចិត្ត  មិនចូលចិត្តរបស់ខ្លួន )។<br>**ចរិយាសម្បទា**<br>- ខិតខំប្រឹងប្រែងបង្កើនសមត្ថភាពដើម្បីជីវិតខ្លួន។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៩ : កិច្ចការប្រចាំថ្ងៃរបស់ខ្ញុំ**<br>៩.១- កិច្ចការប្រចាំថ្ងៃនៅផ្ទះ<br>៩.២- កិច្ចការនៅសាលារៀន<br>៩.៣- ការចូលរួមការងារនៅសាលារៀន | **វិជ្ជាសម្បទា**<br>- សង្ខេបកិច្ចការប្រចាំថ្ងៃដែលត្រូវបំពេញមុនទៅសាលារៀន និងត្រឡប់មកពីសាលារៀនវិញ។<br>- ពណ៌នាតម្រូវការរៀបចំសម្ភារទៅសាលារៀននិងពន្យល់មូលហេតុ។<br>**បំណិនសម្បទា**<br>- អនុវត្តកិច្ចការប្រចាំថ្ងៃដែលត្រូវបំពេញមុនទៅសាលារៀន និងត្រឡប់មកពីសាលារៀនវិញ។<br>- បង្ហាញតម្រូវការរៀបចំសម្ភារទៅសាលារៀន នៅសាលារៀន និងពន្យល់មូលហេតុ។<br>**ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវក្នុងការបំពេញការងាររបស់ខ្លួនក្នុងនាមជាកូនល្អ សិស្សល្អ មិត្តល្អ។ | ៣ម៉ |
| **ជំពូកទី២ : ភូមិខ្ញុំ** | | |
| **មេរៀនទី១ : ផ្ទះខ្ញុំ**<br>១.១- ផ្ទះខ្ញុំ<br>១.២- សារៈសំខាន់របស់ផ្ទះខ្ញុំ | **វិជ្ជាសម្បទា**<br>- ពណ៌នាបានពីទីតាំង និងសារៈសំខាន់ផ្ទះ។<br>**បំណិនសម្បទា**<br>- កំណត់បានពីទីតាំងរបស់ផ្ទះនិងធ្វើបែងចែកបានពីការលំបាក និ<br>ភាពងាយស្រួលនៃការតាំងទីលំនៅ។<br>**ចរិយាសម្បទា**<br>- មានគំនិតស្រឡាញ់ ភូមិឋាន។ | ៦ម៉ |
| **មេរៀនទី២ : ការគោរព**<br>២.១- ការគោរព<br>- ការគោរពសមាជិកគ្រួសារ<br>- ការគោរពមិត្តភក្តិ<br>- ការគោរពលោកគ្រូ អ្នកគ្រូ<br>- ការគោរពចាស់ទុំ<br>- ការគោរពព្រះសង្ឃ<br>២.២- សារៈសំខាន់នៃការគោរព | **វិជ្ជាសម្បទា**<br>- រៀនឆ្លើយ បាទ ចាស អរគុណ សុំទោស និងហាត់សម្ដែងកាយវិការ គោរពអ្នកនៅជុំវិញខ្លួនឱ្យបានត្រឹមត្រូវ។<br>- ពណ៌នាសារៈសំខាន់នៃទម្លាប់ល្អក្នុងការគោរព ការប្រាស្រ័យទាក់ទង។<br>**បំណិនសម្បទា**<br>- អនុវត្តឆ្លើយ បាទ ចាស អរគុណ សុំទោស សម្ដែងកាយវិការគោរពបានត្រឹមត្រូវចំពោះអ្នកនៅជុំវិញខ្លួន។<br>- បង្ហាញកាយវិការ និងពាក្យសំដីគោរពបងប្អូនប្រុស បងប្អូនស្រី ឪពុក ម្ដាយ ចាស់ព្រឹទ្ធាចារ្យ មិត្តភក្តិ លោកគ្រូ អ្នកគ្រូ។<br>- ប្រើប្រាស់ចំណេះដឹងអនុវត្តកាយវិការ និងពាក្យសំដី គោរពព្រះសង្ឃ។<br>**ចរិយាសម្បទា**<br>- គោរពប្រតិបត្តិ និងឱ្យតម្លៃចំពោះមនុស្សជុំវិញខ្លួន។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៣ : តុបតែងខ្លួន**<br>៣.១- រូបភាពកុមារាម្នាក់និងកុមារីម្នាក់ដែលកំពុងរៀនថ្នាក់ទី១<br>៣.២- រូបភាពដំណើរតុបតែងខ្លួនតាមដំណាក់ | **វិជ្ជាសម្បទា**<br>- បង្ហាញវិធីតុបតែងខ្លួនប្រាណ។<br>**បំណិនសម្បទា**<br>- ចេះតុបតែងខ្លួនប្រាណតាមការច្នៃប្រឌិតរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការតុបតែងខ្លួនប្រាណដែលមានលក្ខណៈសមរម្យ។ | ២ម៉ |
| **មេរៀនទី៤ : ការបណ្ដុះគ្រាប់សណ្ដែកបាយ**<br>៤.១- រូបភាពកែវដាក់ត្រាំគ្រាប់សណ្ដែកបាយ៦ឬ៧គ្រាប់ដែលមានដំណើរវិវឌ្ឍជាបន្តបន្ទាប់<br>៤.២- កិច្ចការប្រតិបត្តិ<br>៤.៣- ប្រយោជន៍សណ្ដែកបណ្ដុះ | **វិជ្ជាសម្បទា**<br>- បង្ហាញដំណើរវិវឌ្ឍនៃដំណុះគ្រាប់សណ្ដែកតាមរយៈការតម្រៀបរូបភាពតាមលំដាប់លំដោយ។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីបណ្ដុះគ្រាប់សណ្ដែកបាយ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការបង្កើតស្នាដៃតាមរយៈការបណ្ដុះគ្រាប់ធញ្ញជាតិ។ | ៣ម៉ |
| **ជំពូកទី៣ : សហគមន៍ខ្ញុំ** | | |
| **មេរៀនទី១ : ប្រវត្តិភូមិខ្ញុំ**<br>**សិក្សាបញ្ញត្តិ :** ប្រវត្តិភូមិ បេតិកភណ្ឌ<br>**មាតិកា :**<br>១.១- ប្រវត្តិភូមិ (ម្ចាស់ភូមិ មូលហេតុដាក់ឈ្មោះ ធនធាន និងអាយុកាល)<br>១.២- កេរដំណែលក្នុងភូមិ (បេតិកភណ្ឌ)<br>**សំណួរត្រិះរិះ:**<br>- តើភូមិដែលប្អូនរស់នៅមានឈ្មោះអ្វី? មានន័យដូចម្ដេច? និងមានតំណាលយ៉ាងដូចម្ដេច?<br>- តើក្នុងភូមិមានសម្ភារប្រើប្រាស់ចាស់ៗ ឬទីកន្លែងណាខ្លះដែលអ្នកភូមិគោរព ស្រឡាញ់ និងថែរក្សា? | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីប្រវត្តិនៃការកកើតភូមិខ្ញុំ។<br>**បំណិនសម្បទា**<br>- កត់សម្គាល់អំពីធនធាន និងបេតិកភណ្ឌដែលមានក្នុងភូមិ។<br>**ចរិយាសម្បទា**<br>- ថែរក្សាធនធាននិងបេតិកភណ្ឌដែលមានក្នុងភូមិ។ | ៥ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : អំពីទិស**<br>២.១- ថ្ងៃរះ<br>២.២- ថ្ងៃលិច<br>២.៣- ថ្ងៃត្រង់<br>២.៤- ទិសាភាគ<br>២.៥- ការរកទិស<br>២.៦- ពេលយប់ | **វិជ្ជាសម្បទា**<br>- បង្ហាញបានដោយការចងចាំពីតំបន់ជុំវិញ ព្រមទាំងបង្ហាញពីទិសទាំងបួន។<br>**បំណិនសម្បទា**<br>- ពន្យល់បានពីទិសទាំងបួន និងបង្ហាញពីទិសដែលត្រូវធ្វើដំណើរពីផ្ទះទៅសាលារៀន។<br>- បង្ហាញបានពីទិស និងទីតាំងមួយចំនួននៅលើផែនទី។<br>**ចរិយាសម្បទា**<br>- មានទម្លាប់ប្រើវិធីរកទិសទាំងពេលថ្ងៃនិងពេលយប់បានច្បាស់លាស់។ | ៦ម៉ |
| **មេរៀនទី៣ : ប្រភេទវត្ថុប្រើប្រាស់**<br>៣.១- រូបភាពវត្ថុធ្វើអំពីឈើ<br>៣.២- រូបភាពវត្ថុធ្វើអំពីប្លាស្ទិក<br>៣.៣- រូបភាពវត្ថុធ្វើអំពីលោហៈ<br>៣.៤- រូបភាពវត្ថុធ្វើអំពីកែវ | **វិជ្ជាសម្បទា**<br>- បង្ហាញការញែកវត្ថុប្រើប្រាស់ទៅតាមប្រភេទនៃសារធាតុរបស់វា។<br>**បំណិនសម្បទា**<br>- ចេះទុកដាក់សំរាមដោយញែកតាមប្រភេទ។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ញែកសំរាមទៅតាមប្រភេទនៃសារធាតុ របស់វា។ | ៣ម៉ |
| **មេរៀនទី៤ : ល្បែងសង់ទ្រុងជ្រូក**<br>៤.១- រូបភាពល្បែងសង់ទ្រុងជ្រូកដោយចង្កឹះ<br>៤.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញវិធីសាងសង់សំណង់មួយ បែបល្បែង។<br>**បំណិនសម្បទា**<br>- ចេះសាងសង់សំណង់បែបល្បែង។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការសាងសង់សំណង់ផ្សេងៗ។ | ២ម៉ |
| **ជំពូកទី៤ : ស្រុកខ្ញុំ** | | |
| **មេរៀនទី១ : ធាតុអាកាស**<br>១.១- ក្ដៅ និងត្រជាក់<br>១.២- ខ្យល់បក់<br>១.៣- ភ្លៀង | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីធាតុអាកាស ក្ដៅ ត្រជាក់ ខ្យល់បក់ និងភ្លៀង។<br>**បំណិនសម្បទា**<br>- បែងចែកបានពីធាតុអាកាសក្ដៅ ត្រជាក់ ខ្យល់បក់ និងភ្លៀង និងរកឃើញបញ្ហាដែលបណ្ដាលមកពីក្ដៅ ត្រជាក់ ភ្លៀងខ្លាំងពេក។<br>**ចរិយាសម្បទា**<br>- រកវិធីការពារខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ | ៦ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : ជនគំរូក្នុងភូមិ**<br>**សិក្សាបញ្ញត្តិ :** ស្នាដៃ, អ្នកភូមិ<br>**មាតិកា :**<br>២.១- ស្នាដៃ<br>២.២- មនុស្សល្អក្នុងភូមិ និងចរិតលក្ខណៈ<br>២.៣- វីរភាព<br>**សំណួរត្រិះរិះ :**<br>• តើអ្នកភូមិមួយណា ដែលប្អូនស្រឡាញ់ជាងគេ? ព្រោះអ្វី?<br>• តើមានសកម្មភាពអ្វីខ្លះ ដែលប្អូនចង់ធ្វើតាម? ព្រោះហេតុអ្វី? | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះមនុស្សដែលមានស្នាដៃក្នុងភូមិ និងភាពជាគំរូរបស់គាត់<br>**បំណិនសម្បទា**<br>- រៀបរាប់ស្នាដៃសមយាន់ៗរបស់គាត់តាមលំដាប់លំដោយ (ពីមុន និងសព្វថ្ងៃ)<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃមនុស្សដែលមានស្នាដៃ និងកោតសរសើរហើយយកគំរូតាមគាត់ | ៥ម៉ |
| **មេរៀនទី៣ : ប្រវត្តិសាលារៀនខ្ញុំ**<br>**សិក្សាបញ្ញត្តិ :** សាលារៀន ថែរក្សា<br>**មាតិកា :**<br>៣.១- ប្រវត្តិឈ្មោះសាលា (មូលហេតុនៃការដាក់ឈ្មោះ)<br>៣.២- ទីតាំង (អគារ សួនច្បារ ដើមឈើ) ធនធានក្នុងសាលា<br>៣.៣- ចម្ងាយពីផ្ទះ<br>៣.៤- កសាងពេលណា (ស្ថាបនិក)?<br>**សំណួរត្រិះរិះ :**<br>• តើពីផ្ទះទៅសាលារៀនមានចម្ងាយប៉ុន្មាន?<br>• តើសាលាដែលប្អូនរៀនមានឈ្មោះអ្វី? មានន័យដូចម្តេច?<br>• តើប្អូនត្រូវធ្វើអ្វីខ្លះដើម្បីថែរក្សាសាលារៀនឱ្យស្អាត គ្មានសំរាមបរិស្ថានល្អ និងរឹងមាំជានិច្ច? | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីប្រវត្តិសាលារៀនរបស់ប្អូនដោយបញ្ជាក់ឈ្មោះសាលា ទីតាំង និងចម្ងាយផ្លូវ<br>- ប្រាប់ឈ្មោះអ្នកកសាងនិងពេលវេលាសាងសង់។<br>**បំណិនសម្បទា**<br>- ពន្យល់ពីមូលហេតុនៃការដាក់ឈ្មោះសាលា។<br>**ចរិយាសម្បទា**<br>- រួមគ្នាថែរក្សាការពារសាលារៀនឱ្យស្អាត និងមានភាពរឹងមាំជានិច្ច។ | ៦ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤ : អ្នកគ្រូរបស់ខ្ញុំ**<br>៤.១- រូបភាពអ្នកគ្រូៈដឹកដៃសិស្ស នាំសរសេរអក្សរលើក្ដារខៀន ឈរក្បែរសិស្សគោរពទង់ជាតិ ឈរណែនាំសិស្សឱ្យទុកដាក់ស្បែកជើង ក្នុងទូឈរណែនាំឱ្យសិស្សញ៉ាំអាហារដោយមានសណ្ដាប់ធ្នាប់នៅក្នុងអាហារដ្ឋាន<br>៤.២- រូបភាពឪពុកម្ដាយទៅទទួលកូន ដល់សាលារៀន ។ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពណាមួយក្នុងមេរៀន ដែលខ្លួនពេញចិត្តជាងគេ។<br>**បំណិនសម្បទា**<br>- សម្ដែងតួជាអ្នកគ្រូនៅក្នុងថ្នាក់រៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃ និងគោរពអាជីពគ្រូបង្រៀន។ | ២ម៉ |
| **មេរៀនទី៥ : ពិន្ទុសន្សំពិសេស**<br>៥.១- រូបភាពសកម្មភាពផ្សេងៗក្នុងសាលារៀន ដែលត្រូវទទួលពិន្ទុពិសេសអំពីគ្រូ ៖<br>- មករៀនទាន់ពេល និងទៀងទាត់រាល់ថ្ងៃ<br>- មិនរំខានមិត្តភក្តិ<br>- មិនចោលសំរាមផ្ដេសផ្ដាស<br>- ចូលរួមធ្វើការងារជាមួយមិត្តភក្តិ<br>- ជួយពន្យល់មេរៀនមិត្តភក្តិ ឧ. មេរៀនប្រតិបត្តិ<br>៥.២- រូបភាពតំណាងពិន្ទុ<br>- រូបភាពផ្កាតំណាងពិន្ទុតាមប្រភេទ<br>+ ផ្កាម្លិះ :មករៀនទាន់ពេល និងទៀង ទាត់<br>+ ផ្កាកុលាប : មិនរំខានមិត្តភក្តិ<br>+ ផ្កាចំប៉ា : មិនចោលសំរាមផ្ដេសផ្ដាស<br>+ ផ្ការំដួល : ចូលរួមធ្វើការងារជាមួយមិត្តភក្តិ<br>+ ផ្កាស្បៃរឿង :ជួយពន្យល់មេរៀនដល់មិត្តភក្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពសកម្មភាពដែលត្រូវទទួលបានពិន្ទុសន្សំ<br>- រៀបរាប់ពីសារៈសំខាន់នៃការសន្សំ។<br>**បំណិនសម្បទា**<br>- បំពេញសកម្មភាពល្អៗដើម្បីបានទទួលពិន្ទុសន្សំសម្រាប់យករង្វាន់<br>- បង្ហាញពីសារៈសំខាន់ក្នុងការសន្សំ។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់សន្សំគុណសម្បត្តិ។ | ២ម៉ |

| | | |
|---|---|---|
| ៥.៣- ការប្តូរពិន្ទុយកផលិតផល<br>- ផ្កាម្លិះ៥ = ខ្មៅដៃ១<br>- ផ្កាម្លិះ១០ = សៀវភៅសរសេរ ១<br>- ផ្កាកុលាប៥ = ...... | | |
| **មេរៀនទី៦ : កិច្ចការនៅសាលារៀន**<br>៦.១- កិច្ចការអនុវត្តប្រចាំថ្ងៃ<br>៦.២- វិធីនៃការបំពេញកិច្ចការប្រចាំថ្ងៃ<br>៦.៣- ការចូលរួមការងារនៅសហគមន៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់កិច្ចការសំខាន់ៗដែលត្រូវអនុវត្តប្រចាំថ្ងៃនៅសាលារៀន<br>- ប្រាប់បានវិធីនៃការបំពេញកិច្ចការប្រចាំថ្ងៃរបៀបនៃការសន្សំសំចៃ និងការថែទាំសម្ភារសិក្សា ទ្រព្យសម្បត្តិសហគមន៍។<br>**បំណិនសម្បទា**<br>- បង្ហាញកិច្ចការសំខាន់ៗដែលបានអនុវត្តប្រចាំថ្ងៃនៅសាលារៀន និងនៅសហគមន៍<br>- បង្ហាញរបៀបនៃការសន្សំសំចៃ និងការថែទាំសម្ភារសិក្សា។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃនិងគោរពការងាររបស់ខ្លួនឯង និងអ្នកដទៃ<br>- បណ្តុះស្មារតីចូលរួមសហការក្នុងការធ្វើកិច្ចការនានានៅសាលារៀននិងសហគមន៍។ | ៣ម៉ |
| **ជំពូកទី៥ : សង្គមជាតិ** | | |
| **មេរៀនទី១ : ទម្លាប់ល្អរបស់ខ្ញុំ**<br>១.១- ឥរិយាបថគួរធ្វើ<br>១.២- ឥរិយាបថមិនគួរធ្វើ<br>១.៣- សារៈសំខាន់នៃទម្លាប់ល្អ | **វិជ្ជាសម្បទា**<br>- រៀបរាប់ឥរិយាបថដែលគួរធ្វើ និងមិនគួរធ្វើនៅផ្ទះនៅសាលារៀន<br>- ពណ៌នាសារៈសំខាន់នៃទម្លាប់ល្អនៅផ្ទះ សាលារៀន សហគមន៍ (មិនចោលសំរាមផ្តេសផ្តាសថែរក្សាទ្រព្យសម្បត្តិសាលារៀននិងសហគមន៍)។<br>**បំណិនសម្បទា**<br>- ចូលរួមសម្តែងតួអំពីឥរិយាបថគួរធ្វើ និងមិនគួរធ្វើនៅផ្ទះ នៅសាលារៀន និងនៅសហគមន៍<br>- បង្ហាញសារៈសំខាន់នៃទម្លាប់ល្អនៅផ្ទះ សាលារៀន សហគមន៍(មិនចោល សម្រាមផ្តេសផ្តាស ថែរក្សាទ្រព្យសម្បត្តិនៅផ្ទះ សាលារៀន សហគមន៍)។<br>**ចរិយាសម្បទា**<br>- មានស្មារតី និងឥរិយាបថចូលរួមធ្វើឱ្យផ្ទះ សាលារៀន សហគមន៍ ជាកន្លែងដ៏ល្អប្រសើរសម្រាប់ការរស់នៅ ការសិក្សារៀនសូត្រ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : មិត្តខ្ញុំ**<br>២.១- រូបភាពសិស្សធំ តូច (ថ្នាក់ទី១) រួមគ្នាសម្អាតថ្នាក់រៀន<br>២.២- រូបភាពសិស្សធំ ជួយលើកសិស្សតូចដែលកំពុងដួល<br>២.៣- រូបភាពសិស្សស្រីប្រុសកំពុងអង្គុយរៀនក្នុងថ្នាក់ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពណាមួយដែលខ្លួនពេញចិត្តក្នុងបណ្ដារូបភាពក្នុងមេរៀន។<br>**បំណិនសម្បទា**<br>- សម្គាល់បាន និងប្រាប់តាមសកម្មភាពល្អៗរបស់មិត្តក្នុងថ្នាក់រៀន។<br>**ចរិយាសម្បទា**<br>- បណ្ដុះទឹកចិត្តស្រឡាញ់រាប់អានមិត្តរួមថ្នាក់។ | ២ម៉ |
| **មេរៀនទី៣ : ការគោរពនានាផ្សេងៗគ្នា**<br>៣.១- ការស្ដាប់ដោយយកចិត្តទុកដាក់<br>៣.២- ការទទួលយកអ្វីដែលត្រឹមត្រូវ<br>៣.៣- ការជួយកែលម្អគ្នា | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីការរៀនស្ដាប់ រៀនគិត និងយល់ស្របឬបដិសេធ ព្រមទាំងទទួលយកអ្វីដែលល្អ និងជួយកែលម្អអ្វីដែលមិនល្អ។<br>- ទទួលយកអ្វីដែលល្អ  បដិសេធអ្វីដែលមិនល្អ ចំពោះការមើលឃើញ និងការយល់ឃើញផ្សេងៗគ្នា។<br>**បំណិនសម្បទា**<br>- ស្ដាប់ រិះគិត ទទួលយក ផ្ដល់យោបល់ដល់អ្នកដទៃចំពោះមើល ឃើញ និងយល់ឃើញខុសពីខ្លួន។<br>**ចរិយាសម្បទា**<br>- ទទួលយកគំនិតល្អរបស់អ្នកដទៃ ហើយថ្លឹងថ្លែងអ្វីដែលត្រឹមត្រូវ និងអ្វីដែលមិនត្រឹមត្រូវ។ | ៣ម៉ |
| **មេរៀនទី៤ : ការបង្ការគ្រោះថ្នាក់នៅតាមដងផ្លូវ**<br>៤.១- សុវត្ថិភាពក្នុងការធ្វើដំណើរ<br>៤.២- សកម្មភាពគ្រោះថ្នាក់ចរាចរណ៍<br>៤.៤.  សុវត្ថិភាពនៅពេលកំពុងជិះយានយន្ត<br>៤.៥- កន្លែងលេងនិងដើរបានដោយសុវត្ថិភាព | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីលក្ខណៈសុវត្ថិភាពក្នុងការធ្វើដំណើរតាមដងផ្លូវ (ឧ. ដើរប្រកាន់ស្ដាំដៃពេលធ្វើដំណើរតាមផ្លូវសាធារណៈ និងផ្លូវលំ)។<br>- ពន្យល់សកម្មភាពដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវ។<br>- ប្រាប់ពីការអនុវត្ត និងផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ដល់មិត្តភក្ដិឪពុកម្ដាយ បងប្អូន។<br>**បំណិនសម្បទា**<br>- អនុវត្តការធ្វើដំណើរតាមដងផ្លូវស្របតាមច្បាប់ចរាចរណ៍<br>- បង្ហាញសកម្មភាពដែលបង្កឱ្យមានគ្រោះថ្នាក់នៅតាមផ្លូវ<br>- សួរសំណួរចំពោះឪពុកម្ដាយ បងប្អូនអំពីការធ្វើដំណើរប្រកបដោយសុវត្ថិភាពចរាចរណ៍។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ចរាចរណ៍ជាប់ជានិច្ច។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥** : **ការរាប់អានគ្នា**<br>៥.១- ការស្រឡាញ់បងប្អូន<br>៥.២- ការរាប់អានមិត្តភក្តិ<br>៥.៣- ការរាប់អានអ្នកជិតខាង | **វិជ្ជាសម្បទា**<br>- ពន្យល់ការគោរព ការស្រឡាញ់បងប្អូន មិត្តភក្តិ អ្នកជិតខាង<br>- ពណ៌នាសកម្មភាពដែលបង្ហាញឥរិយាបថក្នុងការជួយគ្នា។<br>**បំណិនសម្បទា**<br>- សម្តែងការគោរពស្រឡាញ់រាប់អានបងប្អូន មិត្តភក្តិ អ្នកជិតខាង។<br>**ចរិយាសម្បទា**<br>- មានស្មារតី គោរពស្រឡាញ់រាប់អានបងប្អូន មិត្តភក្តិ អ្នកជិតខាង។ | ៣ម៉ |
| **មេរៀនទី៦** : **នំអំបែង មៀវខ្យាយ**<br>៦.១- គ្រឿងផ្សំ(រូបភាព)<br>៦.២- វិធីធ្វើ(រូបភាព)<br>៦.៣- វិធីរក្សាទុក(រូបភាព)<br>៦.៤- ប្រភេទនំអំបែងដទៃទៀត | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីគ្រឿងផ្សំ វិធីធ្វើ និងវិធីរក្សាទុកនំអំបែង។<br>**បំណិនសម្បទា**<br>- សង្កេត និងអនុវត្តវិធីធ្វើនំអំបែងនៅសាលារៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើនំចំណីដោយខ្លួនឯង។ | ៣ម៉ |

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី២ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : គ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : ការគោរពឪពុកម្ដាយចាស់ទុំ និងអ្នកដទៃ**<br>១.១- ការគោរព បម្រើជីដូន ជីតា ឪពុក ម្ដាយ ចាស់ទុំ<br>១.២- ការគោរពស្ត្រីភេទ ជនពិការ<br>១.៣- ភាពដូចគ្នា និងខុសគ្នារវាងយើងនិងអ្នកដទៃ (ដូចជា: អត្តសញ្ញាណ ភាសា សាសនា) | **វិជ្ជាសម្បទា**<br>- ពណ៌នាកាយវិការគោរព បម្រើជីដូន ជីតា ឪពុក ម្ដាយ ចាស់ទុំ<br>- ពណ៌នាកាយវិការគោរព និងឱ្យតម្លៃចំពោះស្ត្រីភេទ ជនពិការ<br>- ផ្ដល់យោបល់ពីអ្វីដែលធ្វើឱ្យយើងមានភាពស្រដៀងគ្នានឹងអ្នកដទៃហើយអ្វីដែលធ្វើឱ្យយើងមានភាពខុសគ្នាពីអ្នកដទៃ។<br>**បំណិនសម្បទា**<br>- អនុវត្តកាយវិការគោរព បម្រើជីដូន ជីតា ឪពុក ម្ដាយ ចាស់ទុំ និងអ្នកដទៃ (ស្ត្រីភេទ ជនពិការ)<br>- បង្ហាញភាពដូចគ្នា និងខុសគ្នារវាងយើងនិងអ្នកដទៃ។<br>**ចរិយាសម្បទា**<br>- គោរព និងឱ្យតម្លៃជីដូន ជីតា ឪពុក ម្ដាយ ចាស់ទុំ និងអ្នកដទៃដោយកាយ វាចា ចិត្ត។ | ៣ម៉ |
| **មេរៀនទី២ : សំលៀក និងស្បែកជើងរបស់ខ្ញុំ**<br>២.១- កន្លែងដាក់កាតាប(រូបភាព)<br>២.២- កន្លែងដាក់ស្បែកជើង(រូបភាព)<br>២.៣- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញកន្លែងដាក់ កាតាប និងស្បែកជើង។<br>**បំណិនសម្បទា**<br>- រៀបចំទុកដាក់សំលៀក និងស្បែកជើង របស់ខ្លួនឱ្យស្ថិតនៅតាមកន្លែងរបស់វា។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ទុកដាក់របស់ប្រើប្រាស់ផ្ទាល់ខ្លួនឱ្យមានសណ្ដាប់ធ្នាប់។ | ២ម៉ |
| **មេរៀនទី៣ : តុរៀនរបស់ខ្ញុំ**<br>៣.១ -តុរៀនស្អាត(រូបភាព)<br>៣.២- តុរៀនមានកម្រាល(រូបភាព)<br>៣.៣- តុរៀនមានផ្កា(រូបភាព) | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញតុរៀនរបស់ខ្លួនដែលមានការរៀបចំលម្អរួចរាល់។<br>**បំណិនសម្បទា**<br>- ចេះសម្អាត និងតុបតែងតុរៀនតាម ការច្នៃប្រឌិតរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ថែទាំ និងតុបតែងលម្អរបស់ប្រើប្រាស់។ | ២ម៉ |
| **ជំពូកទី២ : ភូមិខ្ញុំ** | | |
| **មេរៀនទី១ : ទីតាំងភូមិ និងសាលារៀនខ្ញុំ**<br>១.១- ទីតាំងភូមិខ្ញុំ<br>១.២- កន្លែងផ្សេងៗនៅក្នុងភូមិខ្ញុំ<br>១.៣- គូរផែនទីងាយៗពីទីតាំងសាលារៀន | **វិជ្ជាសម្បទា**<br>- ពណ៌នាបានអំពីទីតាំងនិងកន្លែងផ្សេងៗនៅក្នុងភូមិនិងសាលារៀន។<br>**បំណិនសម្បទា**<br>- គូរផែនទីងាយៗ និងបង្ហាញបាន ពីទីតាំងសាលារៀន (វាលស្រែ វត្ត មណ្ឌលសុខភាព ផ្សារ ផ្ទះ) | ៨ម៉ |

| | | |
|---|---|---|
| | - ចេះរកការលំបាកងាយៗនៅតាមផ្លូវពីផ្ទះទៅសាលារៀន។<br>**ចរិយាសម្បទា**<br>- មានគំនិតបង្កើតថ្មី ថែរក្សា និងអភិវឌ្ឍទីតាំងដូចជាសាលារៀន វាលស្រែ វត្តមណ្ឌលសុខភាព ផ្សារ ផ្ទះ និងស្វែងរកវិធីដោះស្រាយការលំបាក។ | |
| **មេរៀនទី២ : សណ្ដាប់ធ្នាប់ល្អ**<br>២.១- ឯកសណ្ឋានសិស្ស<br>២.២- សុជីវធម៌ក្នុងការបរិភោគ<br>២.៣- ការប្រាប់ដំណឹងមុនចូលកន្លែងណាមួយ<br>២.៤- ការគោរពពេលវេលា | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីរបៀបនៃការស្លៀកពាក់ជាឯកសណ្ឋានសិស្ស សុជីវធម៌ក្នុងការបរិភោគ ការជូនដំណឹងមុនចូលកន្លែងណាមួយ។<br>- រៀបរាប់ផលប្រយោជន៍នៃការគោរពពេលវេលា។<br>**បំណិនសម្បទា**<br>- បង្ហាញការស្លៀកពាក់ឯកសណ្ឋានសិស្សជាប្រចាំពេលទៅសាលារៀន និងសម្ដែងតួអំពីការបរិភោគប្រកបដោយសុជីវធម៌<br>- អនុវត្តអំពីការឱ្យដំណឹងមុនចូលកន្លែងណាមួយ។<br>**ចរិយាសម្បទា**<br>- មានអាកប្បកិរិយាល្អ ការទទួលខុសត្រូវប្រកបដោយសុជីវធម៌ និងមានសណ្ដាប់ធ្នាប់ល្អក្នុងការរស់នៅ។ | ៤ម៉ |
| **មេរៀនទី៣ : កិច្ចការរបស់អ្នកភូមិខ្ញុំ**<br>៣.១- រូបភាពស្ដីពីសកម្មភាពរបស់អ្នកភូមិ<br>៣.២- ពេលព្រឹកព្រលឹម<br>៣.៣- ពេលថ្ងៃត្រង់<br>៣.៤- ពេលល្ងាច<br>៣.៥- ការសម្ដែងតួ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញនិងរៀបរាប់សកម្មភាព របស់អ្នកភូមិតាមរូបភាពក្នុងមេរៀន។<br>**បំណិនសម្បទា**<br>- សម្ដែងតួត្រាប់តាមសកម្មភាពរបស់ អ្នកភូមិដែលមានបង្ហាញក្នុងរូបភាព។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃភាពសកម្ម ក្នុងការប្រកបការងារចិញ្ចឹមជីវិត។ | ២ម៉ |
| **មេរៀនទី៤ : ខ្ញុំជួយថែទាំសាលារៀន**<br>៤.១- សាលារៀន<br>៤.២- បរិស្ថានសាលារៀនខ្ញុំ<br>៤.៣- តើអ្នកត្រូវធ្វើដូចម្ដេចខ្លះដើម្បីឱ្យសាលារៀនមានបរិស្ថានល្អ? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខណៈទូទៅនៃទីតាំងសំណង់អគារ ព្រមទាំងបង្ហាញសោភណ្ឌភាពសាលារៀន ដូចជាសួនច្បារ សួនបន្លែ...។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យឃើញពីសោភណភាពរបស់សាលារៀន ព្រមទាំងសកម្មភាពចូលរួមរបស់សិស្សានុសិស្ស<br>- កំណត់បានពីផលវិបាកដែលបណ្ដាលមកពីភាពកខ្វក់។<br>**ចរិយាសម្បទា**<br>- មានគំនិតស្រឡាញ់ និងថែរក្សាបរិស្ថាន សាលារៀននិងលំនៅឋានឱ្យមានសោភណភាព។ | ៨ម៉ |

| ជំពូកទី៣ : សហគមន៍ខ្ញុំ | | |
|---|---|---|
| **មេរៀនទី១ : ប្រវត្តិឃុំ ឬ សង្កាត់ខ្ញុំ**<br>**សិក្សាបញ្ញត្តិ:** ឃុំ សង្កាត់ ការថែរក្សា<br>**មាតិកា :**<br>១.១- ឈ្មោះឃុំ ឬសង្កាត់<br>១.២- ទីតាំង<br>១.៣- ដើមកំណើត (ប្រវត្តិឃុំ ឬអ្នកកសាង)<br>១.៤- មូលហេតុនៃការដាក់ឈ្មោះ<br>១.៥- ធនធានក្នុងឃុំនិងបេតិកភណ្ឌ<br>**សំណួរត្រិះរិះ :**<br>• តើឃុំ ឬសង្កាត់ដែលប្អូនរស់នៅមានឈ្មោះអ្វី? មានន័យដូចម្តេច? នៅឯណា?<br>• តើមានបេតិកភណ្ឌអ្វីខ្លះក្នុងឃុំ?<br>• តើប្អូនត្រូវធ្វើអ្វីខ្លះដើម្បីថែរក្សាឃុំ ឬសង្កាត់ដែលប្អូនរស់នៅឱ្យស្អាត គ្មានសំរាម និងមានម្លប់ឈើគ្រប់ទីកន្លែង? | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីប្រវត្តិនៃការកកើតឃុំខ្ញុំ។<br>**បំណិនសម្បទា**<br>- កត់ត្រាអំពីធនធាន និងបេតិកភណ្ឌដែលមានក្នុងឃុំ។<br>**ចរិយាសម្បទា**<br>- វាយតម្លៃអំពីការចូលរួមថែរក្សាបរិស្ថានក្នុងឃុំ ឬសង្កាត់ឱ្យបានស្អាត | ៦ម៉ |
| **មេរៀនទី២ : ខ្ញុំជួយថែទាំសហគមន៍**<br>២.១- ប្រភពកខ្វក់ក្នុងសហគមន៍<br>២.២- ការរួមគ្នាថែរក្សាសហគមន៍ | **វិជ្ជាសម្បទា**<br>- ប្រាប់បានប្រភពកខ្វក់ក្នុងសហគមន៍ និងពន្យល់ពីរបៀបកាត់បន្ថយឬបំបាត់ភាពកខ្វក់ទាំងនោះ<br>- ប្រាប់បានពីរបៀបថែរក្សា ឬថែទាំសហគមន៍ឱ្យបានស្អាតល្អ។<br>**បំណិនសម្បទា**<br>- បង្ហាញមូលហេតុនិងប្រភពដែលធ្វើឱ្យកខ្វក់ក្នុងសហគមន៍និងពន្យល់របៀបកាត់បន្ថយឬបំបាត់ភាពកខ្វក់ទាំងនោះ<br>- បង្ហាញរបៀបសម្អាតសហគមន៍ឱ្យបានស្អាតល្អ មានអនាម័យ។<br>**ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវប្រកបដោយសីលធម៌ និងចូលរួមថែរក្សាបរិស្ថានសហគមន៍។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៣ : នៅពេលខ្វះទឹក**<br>៣.១- រូបភាពជាគូស្ដីពីការប្រើប្រាស់ទឹកដោយខ្ជះខ្ជាយធៀបនឹងការប្រើប្រាស់ ទឹកសន្សំសំចៃនៅពេល៖<br>-លុបលាងខ្លួនប្រាណ<br>-បោកគក់លាងសំអាត<br>-ចម្អិនអាហារ<br>-ដាំដំណាំ<br>-ចិញ្ចឹមសត្វ<br>៣.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពស្ដីពីការប្រើប្រាស់ទឹកដោយសន្សំសំចៃ។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីសន្សំសំចៃទឹកក្នុងការលុបលាងខ្លួនប្រាណ និងការបោកគក់លាងសម្អាត<br>- បង្ហាញពីសារៈសំខាន់នៃការសន្សំសំចៃ ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការសន្សំសំចៃក្នុងការប្រើប្រាស់ទឹកនៅពេលខ្វះទឹក។ | ៣ម៉ |
| **មេរៀនទី៤ : ប្រភេទសំរាមឬសំណល់នានារលាយក្នុងទឹក**<br>៤.១- ប្រភេទសំរាម ឬសំណល់រលាយក្នុងទឹក(រូបភាព)<br>៤.២- ប្រភេទសំរាម ឬសំណល់មិនរលាយក្នុងទឹក(រូបភាព)<br>៤.៣- កិច្ចការប្រតិបត្តិៈញែកសំរាមឬសំណល់តាមប្រភេទរលាយក្នុងទឹក និងប្រភេទមិនរលាយក្នុងទឹក | **វិជ្ជាសម្បទា**<br>- បង្ហាញការញែកសំរាមឬសំណល់នានារលាយក្នុងទឹក ឬមិនរលាយក្នុងទឹក។<br>**បំណិនសម្បទា**<br>- ចេះទុកដាក់សំរាមរលាយក្នុងទឹក ឬមិនរលាយក្នុងទឹក ឬសំណល់នានា ដោយញែកតាមប្រភេទ។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់ញែកសំរាម ឬសំណល់នានាទៅតាមប្រភេទនៃរលាយក្នុងទឹក ឬមិនរលាយក្នុងទឹក។ | ២ម៉ |
| **មេរៀនទី៥ : ការថែរក្សាទ្រព្យសម្បត្តិ**<br>៥.១- ការថែរក្សាទ្រព្យសម្បត្តិ<br>៥.២- ការស្ដាយចំពោះការបាត់បង់<br>៥.៣- ការប្រគល់របស់ដែលរើសបានឱ្យម្ចាស់ដើមវិញ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបនៃការថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ទ្រព្យសម្បត្តិរបស់អ្នកដទៃ  និងទ្រព្យសម្បត្តិសាធារណៈ<br>- រៀបរាប់អំពីការថែរក្សា និងប្រគល់ទ្រព្យសម្បត្តិឬវត្ថុដែលរើសបានទៅឱ្យម្ចាស់ដើមវិញ។<br>**បំណិនសម្បទា**<br>- បង្ហាញអំពីរបៀបនៃការថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួន  និងទ្រព្យសម្បត្តិសាធារណៈ<br>- បង្ហាញអារម្មណ៍សោកស្ដាយនិងចូលរួមសោកស្ដាយនៅពេលបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬអ្នកដទៃបាត់បង់ទ្រព្យសម្បត្តិ។<br>**ចរិយាសម្បទា**<br>- ចូលរួមថែរក្សាការពារទ្រព្យសម្បត្តិផ្ទាល់ខ្លួន អ្នកដទៃ និងសាធារណៈ។ | ៤ម៉ |

| ជំពូកទី៤ : ស្រុកខ្មុំ | | |
|---|---|---|
| **មេរៀនទី១ : បងប្រុសខ្ញុំ**<br>១.១- រូបភាពស្ដីពីសកម្មភាព របស់បងប្រុសក្នុង:<br>-ការបង្រៀនប្អូនស្រី (ថ្នាក់ទី១)នៅផ្ទះ<br>-ការជួយការងារស្រាលៗ នៅផ្ទះ<br>-ការចាត់ចែងប្រាក់កាស ដែលឪពុកម្ដាយផ្ដល់ឱ្យប្រចាំថ្ងៃ<br>១.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពណាមួយដែលខ្លួនពេញចិត្តជាងគេ។<br>**បំណិនសម្បទា**<br>- សម្ដែងតួត្រាប់តាមសកម្មភាពរបស់ បងប្រុសក្នុងមេរៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការលះបង់កម្លាំងកាយ ចិត្ត ពេលវេលា និងថវិកា ដើម្បីជួយជ្រោមជ្រែងសមាជិកក្រុមគ្រួសារ។ | ២ម៉ |
| **មេរៀនទី២ : ការឱ្យតម្លៃអ្នកដទៃ**<br>២.១- ការឱ្យតម្លៃអ្នកដទៃ<br>២.២- ការទទួលស្គាល់សមត្ថភាពអ្នកដទៃ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអំពីសមត្ថភាព និងអំពើល្អរបស់អ្នកដទៃ<br>- ប្រាប់បាននិងទទួលស្គាល់ស្នាដៃមិត្តរួមថ្នាក់និងអ្នកដទៃ។<br>**បំណិនសម្បទា**<br>- បង្ហាញការឱ្យតម្លៃទៅលើសមត្ថភាពនិងអំពើល្អរបស់អ្នកដទៃ<br>- កំណត់បានសមត្ថភាពដែលទទួលបានការលើកតម្កើង និង ការឱ្យតម្លៃរបស់អ្នកដទៃ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីគោរពនិងឱ្យតម្លៃអ្នកដទៃ។ | ៤ម៉ |
| **មេរៀនទី៣ : ប្រវត្តិរាជធានីភ្នំពេញ**<br>**សិក្សាបញ្ញត្តិ :** ភ្នំពេញ រាជធានី<br>**មាតិកា :**<br>៣.១- ទីតាំងភូមិសាស្ត្រ<br>៣.២- អ្នកកសាងភ្នំដូនពេញ<br>៣.៣- ប្រភពឯកសារ<br>៣.៤- កេរដំណែល និងសាសនា<br>**សំណួរគន្លឹះ :**<br>• ហេតុអ្វីបានមានឈ្មោះបែបនេះ? ស្ថិតនៅឯណា?<br>• តើមានកេរតំណែលអ្វីខ្លះ បានបន្សល់ទុកដល់ | **វិជ្ជាសម្បទា**<br>- ពិពណ៌នាអំពីទីតាំងភូមិសាស្ត្រ និងការដឹកនាំរបស់ដូនពេញ ក្នុងការបង្កើតភ្នំដូនពេញ។<br>**បំណិនសម្បទា**<br>- ប្រាប់បានពីមូលហេតុដែលដូនពេញអាចប្រើអ្នកស្រុកឱ្យលើក ដីពូនភ្នំ និងស្រង់ដើមគគីរ។<br>**ចរិយាសម្បទា**<br>- ពន្យល់អំពីតម្លៃនៃជំនឿសាសនា និងកម្លាំងសាមគ្គី។ | ៦ម៉ |

| | | |
|---|---|---|
| បច្ចុប្បន្ន?<br>• ហេតុអ្វីបានជាប្រជាជននៅរាជធានីរួមគ្នាសង់ភ្នំដូនពេញ? | | |
| **មេរៀនទី៤ : ប្រវត្តិព្រះបរមរាជវាំង**<br>**សិក្សាបញ្ញត្តិ :** ព្រះរាជា រាជវាំង<br>**មាតិកា :**<br>៤.១- ទីតាំងភូមិសាស្ត្រ<br>៤.២- អ្នកកសាង និងកាលបរិច្ឆេទ<br>៤.៣- ប្រភពឯកសារ<br>៤.៤- កេរដំណែល<br>**សំណួរត្រិះរិះ :**<br>• តើរាជវាំងមានទីតាំងនៅឯណា? កសាងពេលណា? និងកសាងដោយព្រះរាជអង្គណាខ្លះ?<br>• តើហេតុអ្វីបានជាមានការផ្លាស់ប្តូររាជវាំង?<br>• តើមានអ្វីខ្លះជាភស្តុតាង?<br>• តើត្រូវធ្វើអ្វីខ្លះដើម្បីថែរក្សារាជវាំងឱ្យបានគង់វង្ស? | **វិជ្ជាសម្បទា**<br>- ពិពណ៌នាពីទីតាំងភូមិសាស្ត្រ អ្នកកសាង និងកាលបរិច្ឆេទ។<br>**បំណិនសម្បទា**<br>- ប្រាប់បានពីមូលហេតុនៃការផ្លាស់ប្តូររាជវាំង។<br>**ចរិយាសម្បទា**<br>- គោរព និងឱ្យតម្លៃកេរដំណែលប្រវត្តិសាស្ត្រ។ | ៥ម៉ |
| **មេរៀនទី៥ : ខ្ញុំបណ្តុះគ្រាប់ឈូក**<br>៤.១- រូបភាពកែវដាក់ត្រាំគ្រាប់ឈូក ៦ឬ៧គ្រាប់ដែលមានដំណើរវិវឌ្ឍជាបន្តបន្ទាប់<br>៤.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញដំណើរវិវឌ្ឍនៃដំណុះគ្រាប់ ឈូកតាមរយៈការតម្រៀបរូបភាពតាម លំដាប់លំដោយ។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីបណ្តុះគ្រាប់ឈូក។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការបណ្តុះគ្រាប់ធញ្ញជាតិ ដើម្បីបង្កើតស្នាដៃ។ | ២ម៉ |
| **ជំពូកទី៥ : សង្គមជាតិ** | | |
| **មេរៀនទី១ : ផ្លូវទឹក**<br>១.២- ផ្លូវទឹក(ប្រឡាយមួយ)<br>-ដៃទន្លេ(កន្លែងប្រសព្វមុខ )<br>-ជ្រលងស្ទឹង | **វិជ្ជាសម្បទា**<br>- សង្កេតនិងបង្ហាញឱ្យឃើញអ្វីដែលហៅថា ផ្លូវទឹក អូរ ជ្រោះ។<br>- រៀបរាប់បានពីសារៈសំខាន់របស់ផ្លូវទឹក អូរ ជ្រោះ។<br>**បំណិនសម្បទា** | ៩ម៉ |

| | | |
|---|---|---|
| ១.២- អូរ ជ្រោះ<br>- អូរ<br>១.៣- ទឹកជ្រោះ | - កំណត់បានពីអ្វីដែលហៅថា ផ្លូវទឹក អូរជ្រោះ។<br>- អាចកំណត់បានពីសកម្មភាពដែលធ្វើឱ្យទឹក កខ្វក់។<br>**ចរិយាសម្បទា**<br>- ចូលរួមថែរក្សា ការពារបរិស្ថាន ផ្លូវទឹក អូរជ្រោះឱ្យបានល្អ។ | |
| **មេរៀនទី២** : **ប្រវត្តិសាលាវិចិត្រសិល្បៈ**<br>**សិក្សាបញ្ញត្តិ** : ស្នាដៃ វប្បធម៌ខ្មែរ<br>**មាតិកា** :<br>២.១- ទីតាំងភូមិសាស្ត្រ<br>២.២- អ្នកកសាង និងកាលបរិច្ឆេទ<br>២.៣- ប្រភពឯកសារ<br>២.៤- កេរដំណែល<br>**សំណួរគន្លឹះ** :<br>• តើសាលាវិចិត្រសិល្បៈមានលក្ខណៈពិសេសអ្វីខ្លះ? ស្ថិតនៅឯណា? កសាងដោយអ្នកណា? ពេលណា?<br>• ហេតុអ្វីបានជាគេកសាសាលានេះ?<br>• តើមានកេរតំណែលអ្វីខ្លះបន្សល់ទុកដល់បច្ចុប្បន្ន? | **វិជ្ជាសម្បទា**<br>- ពណ៌នាពីទីតាំង កាលបរិច្ឆេទ និងការកសាង។<br>**បំណិនសម្បទា**<br>- ពន្យល់ពីមូលហេតុនៃការកសាងសាលាវិចិត្រសិល្បៈ។<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីការចូលរួមថែរក្សាកេរដំណែលវប្បធម៌ជាតិ។ | ៥ម៉ |
| **មេរៀនទី៣** : **ប្រវត្តិពុទ្ធសាសនបណ្ឌិត្យ**<br>**សិក្សាបញ្ញត្តិ** : ស្នាដៃ ការអប់រំ<br>**មាតិកា** :<br>៣.១- ទីតាំងភូមិសាស្ត្រ<br>៣.២- អ្នកកសាង និងកាលបរិច្ឆេទ<br>៣.៣- ប្រភពឯកសារ<br>៣.៤- កេរដំណែល<br>**សំណួរគន្លឹះ** :<br>• តើពុទ្ធសាសនបណ្ឌិត្យមានលក្ខណៈពិសេសអ្វីខ្លះ ? ស្ថិតនៅឯណា និងកសាងដោយអ្នកណា? ឆ្នាំណា? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីទីតាំងភូមិសាស្ត្រ កាលបរិច្ឆេទ និងអ្នកកសាង។<br>**បំណិនសម្បទា**<br>- ពន្យល់ពីសារៈសំខាន់នៃពុទ្ធសាសនបណ្ឌិត្យ។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យពីការប្រតិបត្តិសាសនា និងលើកតម្លៃវប្បធម៌ជាតិ។ | ៥ម៉ |

| | | |
|---|---|---|
| • ហេតុអ្វីបានជាគេកសាងពុទ្ធសាសនបណ្ឌិត្យនេះ?<br>• តើសារៈសំខាន់នៃពុទ្ធសាសនបណ្ឌិត្យមានអ្វីខ្លះ? | | |
| **មេរៀនទី៤ : កិច្ចការពារខ្លួន**<br>៤.១- ស្ថានភាពមានសុវត្ថិភាព និងគ្មានសុវត្ថិភាព<br>៤.២- សកម្មភាពដែលចូលរួមដោយស្ម័គ្រចិត្តនិងការបង្ខំ<br>៤.៣- ការជួយគ្នាឱ្យចៀសផុតពីការគំរាមកំហែង<br>៤.៤- ការឱ្យតម្លៃនិងគោរពមនុស្ស | **វិជ្ជាសម្បទា**<br>- រៀបរាប់ស្ថានភាពមានសុវត្ថិភាពនិងគ្មានសុវត្ថិភាពនិងសម្ដែងអារម្មណ៍នៅក្នុងស្ថានភាពមានសុវត្ថិភាពនិងគ្មានសុវត្ថិភាព(ល្បែងដើរតួ)<br>- ប្រាប់សកម្មភាពដែលចូលរួមដោយស្ម័គ្រចិត្តនិងការបង្ខំឱ្យធ្វើការងារផ្សេងៗ<br>- ប្រាប់បានពីសកម្មភាពដែលគោរពឱ្យតម្លៃមនុស្ស។<br>**បំណិនសម្បទា**<br>- កំណត់បានសកម្មភាពការងារស្ម័គ្រចិត្ត និងសកម្មភាពនៃការបង្ខំឱ្យធ្វើការងារផ្សេងៗ<br>- រកវិធីដែលអាចជួយឱ្យចៀសផុតពីការគំរាមកំហែងនិងពីរបៀបទាក់ទងជាមួយនឹងអ្នកដែលអាចជួយការពារឱ្យមានសុវត្ថិភាព។<br>**ចរិយាសម្បទា**<br>- មានស្មារតីជួយអ្នកដែលរងគ្រោះ និងមានការប្រុងប្រយត្នពីសុវត្ថិភាពខ្លួនឯងនិងមិត្តភក្តិ។ | ៤ម៉ |
| **មេរៀនទី៥ : សុវត្ថិភាពក្នុងការធ្វើដំណើរ**<br>៥.១- ការធ្វើដំណើរប្រកាន់ស្ដាំ<br>៥.២- ការឆ្លងផ្លូវប្រកបដោយសុវត្ថិភាព<br>៥.៣- ភ្លើងនិងសញ្ញាចរាចរណ៍<br>៥.៤- វិធីការពារសុវត្ថិភាពតាមមធ្យោបាយធ្វើដំណើរ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីការធ្វើដំណើរប្រកាន់ស្ដាំ<br>- រៀបរាប់អំពីរបៀបនៃការឆ្លងប្រកបដោយសុវត្ថិភាព<br>- ពណ៌នាអត្ថន័យនៃភ្លើងនិងសញ្ញាចរាចរណ៍(មួយចំនួន)។<br>**បំណិនសម្បទា**<br>- បង្ហាញពីមូលហេតុនៃការធ្វើដំណើរប្រកាន់ស្ដាំ<br>- បង្ហាញរបៀបដើរឆ្លងផ្លូវដោយសុវត្ថិភាព<br>- ពន្យល់អំពីគ្រោះថ្នាក់នៃការលេងឬប្រទ្បេងគ្នានៅតាមដងផ្លូវ<br>- កាត់ក្រដាសពណ៌បិទធ្វើសញ្ញាចរាចរណ៍និងពន្យល់អំពីអត្ថន័យនៃភ្លើងនិងផ្លាកសញ្ញាចរាចរណ៍។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នជាប់ជានិច្ចនៅពេលធ្វើដំណើរតាមដងផ្លូវ។ | ៣ម៉ |

| ជំពូកទី៦ : កិច្ចការខ្ញុំ | | |
|---|---|---|
| **មេរៀនទី១ : ខ្ញុំបត់កន្សែងជូតមាត់ជារាងបីជ្រុង**<br>១.១- លំនាំនៃការបត់កន្សែងជូតមាត់ជារាងបីជ្រុង (រូបភាព)<br>១.២- ការរៀបដាក់កន្សែងផ្ទត់លើចានទៀប (រូបភាព)<br>១.៣- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពតាមលំនាំនៃការបត់កន្សែងជូតមាត់ជារាងបីជ្រុង។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីបត់កន្សែងជូតមាត់ និងរៀបដាក់លើចានទៀប។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់បត់កន្សែងជូតមាត់ដាក់ពីលើចានទៀប។ | ២ម៉ |
| **មេរៀនទី២ : ខ្ញុំធ្វើប្រអប់ដាក់ស្ករគ្រាប់**<br>២.១- រូបភាពស្ដីពីលំនាំនៃការផ្គុំបន្ទះផ្លាស្ទិចឬឈើធ្វើប្រអប់ដាក់ស្ករគ្រាប់<br>២.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពអំពីលំនាំនៃការផ្គុំបន្ទះផ្លាស្ទិចឬឈើធ្វើប្រអប់ដាក់ស្ករគ្រាប់។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីផ្គុំបន្ទះផ្លាស្ទិច ឬឈើធ្វើប្រអប់ដាក់ស្ករគ្រាប់។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការផ្គុំបន្ទះផ្លាស្ទិចឬឈើធ្វើប្រអប់ផ្សេងៗ។ | ២ម៉ |
| **មេរៀនទី៣ : ខ្ញុំចេះផាត់ពណ៌**<br>៣.១- លំនាំនៃការផាត់ពណ៌(រូបភាព)<br>៣.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ចង្អុលបង្ហាញរូបភាពតាមលំនាំនៃការផាត់ពណ៌លើរូបគំនូសព្រាង។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីផាត់ពណ៌លើរូបគំនូសព្រាង។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់យកចិត្តទុកដាក់ក្នុងការផាត់ពណ៌ឱ្យមានភាពស្មើសាច់ និងដាក់តាំងផ្ទាំងគំនូរជាគ្រឿងលម្អ។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤** : **ប្រសិទ្ធភាព ការងារក្រុម**<br>៤.១- ការធ្វើការងារជាក្រុម<br>៤.២- សារៈសំខាន់នៃការងារក្រុម | **វិជ្ជាសម្បទា**<br>- ពណ៌នាសារៈសំខាន់ និងសកម្មភាពនៃការចូលរួមធ្វើការងារជាក្រុម<br>- ប្រាប់បានពីរបៀបធ្វើការជាក្រុម។<br>**បំណិនសម្បទា**<br>- បង្ហាញសកម្មភាពនៃការចូលរួមយ៉ាងសកម្មក្នុងការធ្វើការងារជាក្រុម។<br>- អនុវត្តសកម្មភាពធ្វើការងារជាក្រុម។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយចូលរួមសហការជាមួយសមាជិកក្នុងក្រុម។ | ៣ម៉ |
| **មេរៀនទី៥** : **នំពងទា**<br>៥.១- គ្រឿងផ្សំ(រូបភាព)<br>៥.២- វិធីធ្វើ(រូបភាព)<br>៥.៣- វិធីរក្សាទុក(រូបភាព)<br>៥.៤- ប្រភេទនំដុតដទៃទៀត | **វិជ្ជាសម្បទា**<br>- រៀបរាប់គ្រឿងផ្សំ វិធីធ្វើ និងវិធីរក្សាទុក នំពងទា។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីធ្វើនំពងទានៅសាលារៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការចេះធ្វើនំចំណីដោយខ្លួនឯង។ | ២ម៉ |

## ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៣ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : ខ្ញុំ និងគ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : សណ្ដាប់ធ្នាប់ក្នុងផ្ទះខ្ញុំ**<br>១.១- កន្លែងគេងរបស់ខ្ញុំ (រូបភាពមានអត្ថបទ)<br>១.២- កន្លែងរៀនរបស់ខ្ញុំ (រូបភាពមានអត្ថបទ)<br>១.៣- កន្លែងខ្ញុំសម្អាតខ្លួន (រូបភាពមានអត្ថបទ)<br>១.៤- កន្លែងខ្ញុំញ៉ាំអាហារ (រូបភាពមានអត្ថបទ) | **វិជ្ជាសម្បទា**<br>- រៀបរាប់របៀបទុកដាក់របស់របរក្នុងផ្ទះ។<br>**បំណិនសម្បទា**<br>- ចេះរៀបចំរបស់របរក្នុងផ្ទះឲ្យស្ថិតនៅត្រឹមត្រូវតាមទីកន្លែងរបស់វា<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ក្នុងការរៀបចំផ្ទះឲ្យមានសណ្ដាប់ធ្នាប់។ | ២ម៉ |
| **មេរៀនទី២ : ទីកន្លែងដែលខ្ញុំរស់នៅ**<br>២.១- ទីតាំងស្រុក ឬខណ្ឌដែលខ្ញុំរស់នៅលើផែនទី<br>២.២- ដីក្នុងស្រុក ឬខណ្ឌខ្ញុំ<br>២.៣- ទេសភាពស្រុក ឬខណ្ឌខ្ញុំ<br>២.៤- ការរីកចម្រើនរបស់ស្រុក ឬខណ្ឌខ្ញុំ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីស្រុក ឬខណ្ឌ ឬក្រុង ខេត្ត ឬរាជធានី និងតំបន់ជុំវិញដែលខ្លួនរស់នៅដោយប្រើពាក្យបច្ចេកទេសភូមិវិទ្យា ឧ.ស្រះ ត្រពាំង អូរ បឹង ទន្លេ។<br>**បំណិនសម្បទា**<br>- គូរផែនទីងាយៗបានដោយដាក់សញ្ញាសម្គាល់ងាយៗ ដើម្បីបង្ហាញផ្លូវដែលសិស្ស ធ្វើដំណើរធម្មតាក្នុងមូលដ្ឋាន<br>- ស្វែងរកនូវចំណុចដែលមិនទាន់រីកចម្រើន និងមូលហេតុ។<br>**ចរិយាសម្បទា**<br>- បណ្ដុះគំនិតច្នៃប្រឌិត និងចេះ សហការគ្នា ក្នុងការ គូរផែនទីបង្ហាញផ្លូវតាមរយៈការ ប្រើសញ្ញាសម្គាល់ងាយៗ<br>- ចេះស្រឡាញ់ស្រុកឬខណ្ឌ ឬក្រុង ខេត្តឬរាជធានី និងតំបន់ជុំវិញដែលខ្លួនរស់នៅ និងរកវិធីកាត់បន្ថយចំណុចមិនទាន់រីកចម្រើន។ | ៥ម៉ |
| **មេរៀនទី៣ : ខ្ញុំតុបតែងលម្អលំនៅឋាន**<br>៣.១- ការតុបតែងលម្អលំនៅដ្ឋាន<br>- ផ្ទាំងគំនូរ (រូបភាពមានអត្ថបទ)<br>- ចង្កា-ដើមផ្កាព្យួរ (រូបភាពមានអត្ថបទ)<br>- សួនច្បារ (រូបភាពមានអត្ថបទ)<br>- ភាពស្អាតមានសណ្ដាប់ | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីវិធីតុបតែងលម្អលំនៅឋាន។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីតុបតែងលម្អទីកន្លែងរស់នៅតាមការច្នៃប្រឌិតរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ក្នុងការតុបតែងលំនៅដ្ឋានរបស់ខ្លួន។ | ២ម៉ |

| | | |
|---|---|---|
| ធ្លាប់(រូបភាពពីរមាន<br>អត្ថន័យផ្ទុយគ្នា)<br>- ភាពស្អាតមានអនាម័យ<br>(រូបភាពពីរមានអត្ថន័យ<br>ផ្ទុយគ្នា)<br>៣.២- កិច្ចការប្រតិបត្តិ | | |
| **មេរៀនទី៤** : **ឥរិយាបថល្អ<br>នៅផ្ទះនិង<br>នៅទីសាធារណៈ**<br>៤.១- ការចូលរួមសម្អាតផ្ទះសម្បែង<br>ភូមិស្ថាន វត្តអារាម<br>៤.២- សុជីវធម៌នៅតាម<br>ទីសាធារណៈ វត្តអារាម<br>៤.៣- ការឱ្យតម្លៃ គោរពមនុស្ស និង<br>បរិស្ថាន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការចូលរួមសកម្មភាពក្នុងការសម្អាតផ្ទះសម្បែង ភូមិស្ថាន វត្តអារាម<br>- ប្រាប់បានពីសុជីវធម៌នៅតាមទីសាធារណៈ ក្នុងវត្តអារាម និងការធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈ។<br>**បំណិនសម្បទា**<br>- ចូលរួមជួយការងារផ្ទះ សម្អាតទីកន្លែងផ្សេងៗជាមួយឪពុកម្ដាយ<br>- បង្ហាញឥរិយាបថល្អនៅតាមទីសាធារណៈនៅក្នុងវត្តអារាម និងការធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ឥរិយាបថល្អនៅតាមទីសាធារណៈ នៅក្នុងវត្តអារាម និងការធ្វើដំណើរ<br>- ឱ្យតម្លៃនិងគោរពមនុស្ស បរិស្ថាននិងវត្ថុទាំងអស់។ | ៣ម៉ |
| **ជំពូកទី២** : **ភូមិខ្ញុំ** | | |
| **មេរៀនទី១** : **អ្នកដឹកនាំភូមិ<br>ឃុំ/សង្កាត់**<br>១.១- មុខងារនិងភារកិច្ចរបស់មេភូមិ<br>មេឃុំ/ចៅសង្កាត់<br>១.២- ភូមិ ឃុំ/សង្កាត់<br>មានសុវត្ថិភាព | **វិជ្ជាសម្បទា**<br>- ពណ៌នាមុខងារនិងភារកិច្ចរបស់មេភូមិ មេឃុំ/ចៅសង្កាត់<br>- រៀបរាប់បានពីគោលការណ៍ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាព<br>**បំណិនសម្បទា**<br>- បង្ហាញពីភារកិច្ចនិងសកម្មភាពរបស់មេភូមិ មេឃុំ/ចៅសង្កាត់<br>- អនុវត្តតាមគោលការណ៍ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាព។<br>**ចរិយាសម្បទា**<br>- ចូលរួមសកម្មភាពផ្សេងជាមួយអាជ្ញាធរមូលដ្ឋាន (ប្រធានក្រុម មេភូមិ មេឃុំ/ចៅសង្កាត់ ) ដើម្បីសុវត្ថិភាព និងអភិវឌ្ឍមូលដ្ឋាន។ | ៣ម៉ |
| **មេរៀនទី២** : **ការផ្លាស់ប្ដូរ<br>សភាពពេល**<br>២.១- ធាតុអាកាស<br>២.២- ការប្រែប្រួលធាតុអាកាស<br>(សភាពពេល) | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីការប្រែប្រួលនៃសភាពពេល។<br>**បំណិនសម្បទា**<br>- សង្កេត និងកត់ត្រាបានពីបាតុភូត ធាតុអាកាសប្រចាំថ្ងៃ (បើកថ្ងៃ មានភ្លៀង) មានពពកច្រើន មានខ្យល់ និងផលរបស់វា | ៧ម៉ |

| | | |
|---|---|---|
| ២.៣- ពន្លឺ និងកម្ដៅព្រះអាទិត្យ<br>២.៤- លំនាំសភាពពេលប្រចាំថ្ងៃ<br>២.៥- ធាតុអាកាស និង ការបង្កើតផល | ក្នុងជីវភាពប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- ប្រើប្រាស់ពេលវេលាសមស្របសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ<br>- រកវិធីការពារខ្លួនពីការប្រែប្រួលនៃសភាពពេល។ | |
| **មេរៀនទី៣ : ស្នាដៃសង់ផ្ទះរបស់ខ្ញុំ**<br>៣.១- រូបភាពមានអត្ថបទអំពីដុំជ័រមួយគំនរ ការបន្ទុបដុំជ័រ និងរូបភាពផ្ទះដែលសង់ដោយការបន្ទុបដុំជ័រ។<br>៣.២- ការលេងល្បែងសង់ផ្ទះ | **វិជ្ជាសម្បទា**<br>- បង្ហាញពីរបៀបសង់ផ្ទះពីដុំជ័រ។<br>**បំណិនសម្បទា**<br>- អនុវត្តសកម្មភាពបន្ទុបដុំជ័រជារូបផ្ទះតាមការច្នៃប្រឌិតរបស់ខ្លួន<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការកសាងស្នាដៃសាងសង់នានា។ | ២ម៉ |
| **ជំពូកទី៣ : សហគមន៍ខ្ញុំ** | | |
| **មេរៀនទី១ : អ្នកដឹកនាំក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី**<br>១.១- មុខងារនិងភារកិច្ចរបស់អ្នកគ្រប់គ្រងក្រុង/ ស្រុក/ខណ្ឌ<br>១.២- មុខងារនិងភារកិច្ចរបស់អ្នកគ្រប់គ្រងខេត្ត/ រាជធានី<br>១.៣- ទស្សនកិច្ចសិក្សានៅសាលាក្រុង/ស្រុក/ខណ្ឌ | **វិជ្ជាសម្បទា**<br>- ពណ៌នាមុខងារនិងភារកិច្ចរបស់អ្នកគ្រប់គ្រងក្រុង/ស្រុក/ខណ្ឌ/ខេត្ត/ រាជធានី<br>**បំណិនសម្បទា**<br>- កំណត់សកម្មភាពរបស់អ្នកគ្រប់គ្រងក្រុង/ស្រុក/ខណ្ឌ/ខេត្ត / រាជធានី។<br>- ទស្សនកិច្ចដល់សាលាក្រុង/ស្រុក/ខណ្ឌឬសាលាឃុំ/សង្កាត់។<br>**ចរិយាសម្បទា**<br>- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍជាមួយអ្នកគ្រប់គ្រងក្រុង/ស្រុក/ខណ្ឌ/ខេត្ត/ រាជធានី។ | ៣ម៉ |
| **មេរៀនទី២ : ព្រះបាទហ៊ុនទៀន និងព្រះនាងលីវយី**<br>**សិក្សាបញ្ញត្តិ :** រឿងនិទាន ប្រពៃណីអាពាហ៍ពិពាហ៍<br>**មាតិកា :**<br>២.១- ប្រវត្តិតាមរឿងព្រេង<br>២.២- កំណើតប្រទេស និងរាជវង្ស<br>២.៣- ប្រពៃណី<br>- ព្រះនាងលីវយី<br>- ព្រះបាទហ៊ុនទៀន (តម្លៃប្រពៃណីទំនៀមទម្លាប់ខ្មែរ)<br>២.៤- វប្បធម៌ខ្មែរ និងឥណ្ឌា<br>**សំណួរគន្លឹះ :**<br>• តើប្រពៃណីទំនៀមទម្លាប់ | **វិជ្ជាសម្បទា**<br>- និទានរឿងព្រេងព្រះបាទហ៊ុនទៀននិងនាងលីវយី។<br>**បំណិនសម្បទា**<br>- បង្ហាញពីដើមកំណើតប្រពៃណីតោងស្បៃក្នុងពិធីរៀបអាពាហ៍ពិពាហ៍។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យពីការចូលរួមថែរក្សាវប្បធម៌ ប្រពៃណីដូនតា និងតម្លៃនៃគំនិតផ្សេងៗគ្នា។ | ៦ម៉ |

| | | |
|---|---|---|
| ខ្មែរទទួលឥទ្ធិពលពីណាខ្លះ?<br>• តើរឿងព្រេងនេះប្រាប់អ្វីខ្លះ ដែលទាក់ទងនឹងដើមកំណើតប្រទេសខ្មែរ និងរាជវង្សខ្មែរ? | | |
| **មេរៀនទី៣** : **ព្រះបាទតជ័យវរ្ម័នទី១**<br>**សិក្សាបញ្ញត្តិ** : ស្នាព្រះហស្ត ការអប់រំពុទ្ធិ ទេពកោសល្យ ភាពអង់អាច<br>**មាតិកា** :<br>៣.១- ប្រវត្តិ<br>៣.២- ស្នាព្រះហស្ត<br>៣.៣- ភាពជាអ្នកដឹកនាំ<br>៣.៤- អក្សរ័កាល<br>**សំណួរគន្លឹះ** :<br>• តើព្រះបាទភវវរ្ម័នទី១ មានវីរភាពគំរូយ៉ាងដូចម្ដេចខ្លះ?<br>• ចូរដៅស្នាព្រះហស្តតាមលំដាប់កាល | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រវត្តិ និងស្នាព្រះហស្តរបស់ព្រះបាទភវវរ្ម័នទី១។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបគុណសម្បត្តិនៃអ្នកដឹកនាំដោយផ្ដោតលើតម្លៃពុទ្ធិ និងទេពកោសល្យ ភាពទន់ភ្លន់ ឆន្ទៈអង់អាចការពារជាតិ ការបង្រួបបង្រួមប្រទេស និងសុខដុមនីយកម្ម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីទម្រង់នៃការដឹកនាំរបស់ព្រះបាទភវវរ្ម័នទី១ ដែលធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព។ | ៥ម៉ |
| **មេរៀនទី៤** : **ទម្លាប់ល្អនៅសាលារៀន**<br>៤.១- ការគោរពអ្នកដទៃ<br>៤.២- សកម្មភាពក្នុងការសហការគ្នា<br>៤.៣- ការគោរពវិន័យសាលារៀន<br>៤.៤- ការគោរពវិន័យនិងការទទួលខុសត្រូវ<br>៤.៥- ទំនាក់ទំនងល្អរវាងសិស្សនិងសិស្ស | **វិជ្ជាសម្បទា**<br>- រៀបរាប់សកម្មភាពនៃការគោរពលោកគ្រូ អ្នកគ្រូ និងអ្នកដទៃ<br>- រៀបរាប់អំពីទម្លាប់គួរធ្វើ និងមិនគួរធ្វើនៅសាលារៀននិងសហគមន៍។<br>**បំណិនសម្បទា**<br>- អនុវត្តការគោរពចំពោះលោកគ្រូ អ្នកគ្រូ អ្នកដទៃនិងគោរពវិន័យក្នុងសាលារៀន<br>- ចូលរួមពិភាក្សាអំពីមូលហេតុនៃការគោរពវិន័យផ្សេងៗ<br>- អភិវឌ្ឍទំនាក់ទំនងល្អរវាងសិស្សនិងសិស្ស<br>- ស្ដាប់និងឆ្លើយតបទៅនឹងអ្នកដទៃ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីទំនាក់ទំនងល្អរវាងសិស្សនិងសិស្ស សិស្សនិងអ្នកដទៃក្នុងសហគមន៍។ | ៣ម៉ |
| **មេរៀនទី៥**: **ការយកចិត្តទុកដាក់ចំពោះអ្នកនៅជុំវិញ**<br>៥.១- ការថែរក្សា និងមិនចង់បាន | **វិជ្ជាសម្បទា**<br>- ពន្យល់ពីមូលហេតុនៃការថែរក្សា និងការប្រគល់របស់របរដែលរើសបានជូនទៅម្ចាស់ដើមវិញ<br>- ឱ្យឧទាហរណ៍ពីរបៀបធ្វើយ៉ាងណានៅពេលរើសបានរបស់របរ | ៣ម៉ |

| | | |
|---|---|---|
| ទ្រព្យរបស់អ្នកដទៃធ្វើជារបស់ខ្លួន<br>៥.២- ការទទួលស្គាល់អារម្មណ៍របស់អ្នកដទៃ<br>៥.៣- ការប្រគល់របស់របរ ឬប្រាក់កាសដែលរើសបានជូនម្ចាស់ដើមវិញ | អ្នកដទៃ ។<br>**បំណិនសម្បទា**<br>- បង្ហាញមូលហេតុនិងសកម្មភាពនៃការថែរក្សា និងការប្រគល់របស់របរដែលរើសបានជូនទៅម្ចាស់ដើមវិញ<br>- ចូលរួមសម្តែងតួដែលបង្ហាញពីការរើសបាននិងប្រគល់របស់ជូនម្ចាស់ដើមវិញ។<br>**ចរិយាសម្បទា**<br>- មានឥរិយាបថវិជ្ជមាន ប្រកាន់ខ្ជាប់នូវស្មារតីស្មោះត្រង់ជួយរក្សាទុក មិនយករបស់របរអ្នកដទៃធ្វើជារបស់ខ្លួន និងយកចិត្តទុកដាក់ចំពោះអ្នកជុំវិញខ្លួន ទាំងនៅសាលារៀន និងទីសាធារណៈ។ | |
| **មេរៀនទី៦ : ស្នាដៃគំនូររបស់ខ្ញុំ**<br>៦.១- ការផលិតស្នាដៃគំនូរ<br>៦.២- សម្ភារៈគូរគំនូរ(រូបភាពមានអត្ថបទ)<br>៦.៣- របៀបគូរគំនូរ(រូបភាពមានអត្ថបទ)<br>៦.៤- របៀបផាត់ពណ៌(រូបភាពមានអត្ថបទ) | **វិជ្ជាសម្បទា**<br>- រៀបរាប់សម្ភារៈសម្រាប់គូរគំនូរ។<br>**បំណិនសម្បទា**<br>- អនុវត្តសកម្មភាពគូរគំនូរណាមួយនៅក្នុងថ្នាក់រៀន។<br>**ចរិយាសម្បទា**<br>- ចាត់ទុកការគូរគំនូរជាការបង្កើតស្នាដៃ ឬផលិតផល។ | ២ម៉ |
| **មេរៀនទី៧ : ខ្ញុំធ្វើជីកំប៉ុសគោក**<br>៧.១- ជីកំប៉ុសគោកជាអ្វី?<br>៧.២- ជីកំប៉ុសគោកមានប្រយោជន៍អ្វីខ្លះ?<br>៧.៣- វិធីធ្វើជីកំប៉ុសគោក<br>៧.៤- ការប្រតិបត្តិវិធីធ្វើជីកំប៉ុសគោកនៅសាលារៀន (រូបភាព) | **វិជ្ជាសម្បទា**<br>- បង្ហាញពីរបៀបធ្វើជីកំប៉ុសគោក។<br>**បំណិនសម្បទា**<br>- ចេះទុកដាក់សំរាមដោយញែកតាមប្រភេទ និងផ្សំជីកំប៉ុសគោក។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការញែកសំរាម និងការផ្សំជីកំប៉ុសគោក។ | ៣ម៉ |
| **ជំពូកទី៤ : ស្រុកខ្ញុំ** | | |
| **មេរៀនទី១ : កន្លែងផ្សេងៗនៅស្រុកខ្ញុំ**<br>១.១- កន្លែងសំខាន់ៗនៅស្រុកខ្ញុំ<br>១.២- ទីតាំងសំខាន់ៗនៅស្រុកខ្ញុំ<br>១.៣- ផ្លូវពីផ្ទះទៅសាលារៀនខ្ញុំ | **វិជ្ជាសម្បទា**<br>- ពណ៌នាបានពីទីតាំងសំខាន់ៗនៅក្នុងស្រុក។<br>**បំណិនសម្បទា**<br>- ចេះគូរផែនទីងាយៗ ដោយដាក់សញ្ញា សម្គាល់ងាយៗ ផ្លូវចូលផ្ទះ សាលារៀន។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ជួយថែរក្សាការពារ និងអភិវឌ្ឍកន្លែងផ្សេងៗនៅក្នុងស្រុក | ៥ម៉ |
| **មេរៀនទី២ : ការស្រឡាញ់** | **វិជ្ជាសម្បទា** | ៣ម៉ |

| | | |
|---|---|---|
| **រាប់អានគ្នា**<br>២.១- ការគោរពស្រឡាញ់អ្នកដទៃ<br>២.២- ការជួយគ្នានៅក្នុងសហគមន៍<br>២.៣- សារៈសំខាន់នៃការគោរពរាប់អានគ្នាក្នុងសហគមន៍ | - ប្រាប់បានពីរបៀបប្រាស្រ័យទាក់ទង គោរពស្រឡាញ់ សហការ និងយកចិត្តទុកដាក់ចំពោះអ្នកដទៃក្នុងសហគមន៍<br>- ពណ៌នាសកម្មភាពដែលបង្ហាញឥរិយាបថក្នុងការជួយគ្នានៅក្នុងសហគមន៍។<br>**បំណិនសម្បទា**<br>- អនុវត្តការប្រាស្រ័យទាក់ទង កិច្ចសហការ ការយកចិត្តទុកដាក់ចំពោះអ្នកដទៃក្នុងសហគមន៍<br>- ពន្យល់មូលហេតុនៃការជួយគ្នានៅក្នុងសហគមន៍។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រកាន់ខ្ជាប់ការគោរពស្រឡាញ់រាប់អានគ្នា និងជួយគ្នា។ | |
| **មេរៀនទី៣ : សុវត្ថិភាពនៅក្នុងតំបន់មានមីននិងគ្រាប់មិនទាន់ផ្ទុះ**<br>៣.១- អត្ថន័យនៃផ្លាកសញ្ញាមីន<br>៣.២- សុវត្ថិភាពក្នុងតំបន់មានគ្រាប់មីន<br>៣.៣- ការចៀសវាងលេងឬដំគ្រាប់មិនទាន់ផ្ទុះ | **វិជ្ជាសម្បទា**<br>- រៀបរាប់អត្ថន័យនៃផ្លាកសញ្ញាមីន<br>- ពណ៌នាឥរិយាបថប្រកបដោយសុវត្ថិភាពក្នុងតំបន់មានមីន និងគ្រាប់ មិនទាន់ផ្ទុះ។<br>**បំណិនសម្បទា**<br>- បង្ហាញឥរិយាបថមានសុវត្ថិភាពក្នុងតំបន់មានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ<br>- បង្ហាញនិងកំណត់អត្ថន័យនៃផ្លាកសញ្ញាមីន<br>- រាយការណ៍នៅពេលឃើញគ្រាប់មីន និងគ្រប់មិនទាន់ផ្ទុះ។<br>**ចរិយាសម្បទា**<br>- បង្កើនការប្រុងប្រយ័ត្នដែលនាំឱ្យចៀសផុតពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ | ២ម៉ |
| **មេរៀនទី៤ : វិន័យការងារ**<br>៤.១- វិន័យការងារ<br>- និយមន័យ<br>- អត្ថប្រយោជន៍<br>៤.២- គោរពពេលវេលា<br>- និយមន័យ<br>- អត្ថប្រយោជន៍<br>៤.៣- លក្ខណៈសកម្មការងារ<br>- និយមន័យ<br>- អត្ថប្រយោជន៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីអត្ថប្រយោជន៍នៃវិន័យការងារ។<br>**បំណិនសម្បទា**<br>- អនុវត្តការសង្កេត សម្គាល់ និងគ្រាប់តាមសកម្មភាពការងារ និងការគោរពពេលវេលារបស់កម្មកររោងចក្រ។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់គោរពវិន័យការងារ។ | ២ម៉ |
| **មេរៀនទី៥ : ពេលវេលាជាមាសប្រាក់**<br>៥.១- តម្លៃនៃពេលវេលា | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីតម្លៃនៃពេលវេលា។<br>**បំណិនសម្បទា** | ២ម៉ |

| | | |
|---|---|---|
| - ការគោរពពេលវេលា (រូបភាពមានអត្ថបទ)<br>- ការសន្សំពេលវេលា (រូបភាពមានអត្ថបទ)<br>- ការចំណេញពេលវេលា (រូបភាពមានអត្ថបទ)<br>- ការខាតពេលវេលា (រូបភាពមានអត្ថបទ)<br>៥.២- កិច្ចការប្រតិបត្តិ | - អនុវត្តវិធីសន្សំពេលវេលាដើម្បីទទួលបានផលប្រយោជន៍ណាមួយ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការសន្សំពេលវេលា។ | |
| **ជំពូកទី៥ : សន្តមជាតិ** | | |
| **មេរៀនទី១ : ព្រះបាទជ័យវរ្ម័នទី២**<br>**សិក្សាបញ្ញត្តិ :** ស្នាព្រះហស្ត គំរូ<br>**មាតិកា :**<br>១.១- ប្រវត្តិ<br>១.២- ស្នាព្រះហស្ត<br>១.៣- ភាពជាអ្នកដឹកនាំ<br>១.៤- អក្សកាល<br><br>**សំណួរត្រិះរិះ :**<br>• តើព្រះបាទជ័យវរ្ម័នទី២មានប្រវត្តិដូចម្តេច?<br>• តើព្រះបាទជ័យវរ្ម័នទី២មានវីរភាពជាគំរូយ៉ាងដូចម្តេចខ្លះ?<br>• រៀបរាប់ស្នាព្រះហស្តរបស់ព្រះអង្គតាមលំដាប់កាល។ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រវត្តិ និងស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី២។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបគុណសម្បត្តិនៃអ្នកដឹកនាំដោយផ្តោតលើតម្លៃពុទ្ធិ និងទេពកោសល្យ ភាពទន់ភ្លន់ ឆន្ទៈអង់អាចការពារជាតិ អធ្យាស្រ័យ ការបង្រួបបង្រួមប្រទេស និងសុខដុមនីយកម្ម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីការដឹកនាំរបស់ព្រះអង្គដែលធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព។ | ៥ម៉ |
| **មេរៀនទី២ : ព្រះបាទជ័យវរ្ម័នទី៧**<br>**សិក្សាបញ្ញត្តិ :** ស្នាព្រះហស្ត គំរូ វីរភាព ឆន្ទៈ សុខដុមនីយកម្ម<br>**មាតិកា :**<br>២.១- ប្រវត្តិ<br>២.២- ព្រះមហេសី<br>២.៣- ស្នាព្រះហស្ត<br>២.៤- ភាពជាអ្នកដឹកនាំ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រវត្តិ និងស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី៧។<br>**បំណិនសម្បទា។**<br>- ប្រៀបធៀបគុណសម្បត្តិនៃអ្នកដឹកនាំដោយផ្តោតលើតម្លៃពុទ្ធិ និងទេពកោសល្យ ភាពទន់ភ្លន់ ឆន្ទៈអង់អាចការពារជាតិ អធ្យាស្រ័យ ស្ត្រីជាអ្នកដឹកនាំ ការបង្រួបបង្រួមប្រទេស និងសុខដុមនីយកម្ម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីការដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលមាន | ៦ម៉ |

| | | |
|---|---|---|
| ២.៥- អក្ស័កាល<br>**សំណួរត្រិះរិះ** :<br>• តើប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧ ដូចម្តេច?<br>• តើព្រះបាទជ័យវរ្ម័នទី៧ មានវីរភាព ជាគំរូយ៉ាងដូចម្តេចខ្លះ?<br>• ចូររៀបស្នាព្រះហស្តរបស់ព្រះអង្គតាមលំដាប់កាល។<br>• តើព្រះមហេសីបានរួមចំណែកអ្វីខ្លះដល់ព្រះអង្គ? | ព្រហ្មវិហារធម៌។ | |
| **មេរៀនទី៣** : **អំពីខ្យល់បក់ និងភ្លៀង**<br>៣.១- ខ្យល់បក់<br>- ខ្យល់ជំនោរ<br>- ខ្យល់ព្យុះ<br>៣.២- ភ្លៀង<br>- ដំណើរទឹកភ្លៀង<br>- ប្រភេទភ្លៀង<br>៣.៣- ផលល្អ និងផលមិនល្អនៃខ្យល់បក់ និងភ្លៀង | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសញ្ញាដែលអាចឱ្យយើងដឹងបានថាមានខ្យល់បក់ និងសញ្ញានឹងអាចភ្លៀងធ្លាក់។<br>**បំណិនសម្បទា**<br>- បង្ហាញពីប្រភេទខ្យល់បក់ និងភ្លៀង<br>- ពន្យល់ឱ្យឃើញពីសារៈសំខាន់របស់ខ្យល់ព្រមទាំងឥទ្ធិពលរបស់វា។<br>**ចរិយាសម្បទា**<br>- មានគំនិត ក្នុងការការពារខ្លួននៅពេលមានខ្យល់បោកបក់ និងភ្លៀងខ្លាំង និងអាចទាញយកផលប្រយោជន៍ពីខ្យល់បក់ និងភ្លៀង។ | ៥ម៉ |
| **មេរៀនទី៤** : **លោកឪពុករបស់ខ្ញុំ**<br>៤.១- ការលះបង់កម្លាំងកាយដើម្បីជួយសង្គមនិងគ្រួសារ(រូបភាពមានអត្ថបទ)<br>៤.២- ការលះបង់កម្លាំងចិត្តដើម្បីជួយសង្គម និងគ្រួសារ(រូបភាពមានអត្ថបទ)<br>៤.៣- ការលះបង់ទ្រព្យសម្បត្តិដើម្បីជួយសង្គម និងគ្រួសារ (រូបភាពមានអត្ថបទ) | **វិជ្ជាសម្បទា**<br>- រៀបរាប់បានកិច្ចការរបស់លោកឪពុកក្នុងមេរៀន។<br>**បំណិនសម្បទា**<br>- ចេះសង្កេត សម្គាល់បាន និង គ្រាប់តាមលក្ខណសម្បត្តិរបស់លោកឪពុកដែលចេះជួយសង្គម និងគ្រួសារ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃនិងគោរពមនុស្សដែលមានកិត្តិនាម។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : ស្ទឹង ទន្លេ បឹង**<br>៥.១- ស្ទឹង<br>៥.២- ជ្រលងស្ទឹង<br>៥.៣- ទន្លេ<br>៥.៤- ជ្រលងទន្លេ<br>៥.៥- បឹង | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រភពដែលអាចឱ្យយើងដឹងបានថាអ្វីជាស្ទឹង ទន្លេ បឹង។<br>**បំណិនសម្បទា**<br>- ពន្យល់ឱ្យឃើញពីសារៈសំខាន់របស់ ស្ទឹង ទន្លេ បឹង។<br>**ចរិយាសម្បទា**<br>- មានគំនិត ចូលរួមថែរក្សាការពារបរិស្ថាន ស្ទឹង ទន្លេ បឹង ឱ្យបានល្អ និងអាចទាញយកផលប្រយោជន៍ពីស្ទឹង ទន្លេ បឹងទាំងនោះ។ | ៥ម៉ |
| **មេរៀនទី៦ : សីលធម៌ និង សាសនា**<br>៦.១- ជំនឿព្រះពុទ្ធសាសនា និង គ្រិស្តសាសនា<br>៦.២- គោលការណ៍អប់រំសំខាន់ របស់ព្រះពុទ្ធសាសនា និង គ្រិស្តសាសនា<br>៦.៣- ការមិនរើសអើងជំនឿ សាសនា | **វិជ្ជាសម្បទា**<br>- ពណ៌នាជំនឿព្រះពុទ្ធសាសនា និងគ្រិស្តសាសនានៅក្នុងសហគមន៍<br>- រៀបរាប់គោលការណ៍សំខាន់ៗនៃការអប់រំរបស់ព្រះពុទ្ធសាសនា និងគ្រិស្តសាសនា<br>- រៀបរាប់សកម្មភាពនៃការមិនរើសអើងជំនឿសាសនារបស់អ្នកដទៃ។<br>**បំណិនសម្បទា**<br>- កំណត់បានគោលការណ៍អប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា និងគ្រិស្តសាសនា។<br>**ចរិយាសម្បទា**<br>- គោរព ឱ្យតម្លៃ និងមិនរើសអើងសាសនាដទៃ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៧ : ព្រះបាទនរោត្តមសីហនុ**<br>**សិក្សាបញ្ញត្តិ :** ស្នាព្រះហស្ត គំរូវីរភាព ឆន្ទៈ ភាពទន់ភ្លន់ ឯករាជ<br>**មាតិកា**<br>៧.១- ប្រវត្តិ<br>៧.២- ស្នាព្រះហស្ត<br>៧.៣- ភាពជាអ្នកដឹកនាំ<br>៧.៤- អក្សរកាល<br>**សំណួរត្រិះរិះ :**<br>• តើព្រះបាទនរោត្តម សីហនុ មានប្រវត្តិដូចម្ដេច?<br>• តើព្រះបាទនរោត្តម សីហនុ មានវីរភាពជាគំរូ យ៉ាងដូចម្ដេចខ្លះ?<br>• តើព្រះអង្គមានស្នាព្រះហស្ត អ្វីខ្លះ? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រវត្តិ និងស្នាព្រះហស្តរបស់ព្រះបាទនរោត្តម សីហនុ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបគុណសម្បត្តិនៃអ្នកដឹកនាំដោយផ្ដោតលើតម្លៃពុទ្ធិ និងទេពកោសល្យ ភាពទន់ភ្លន់ ឆន្ទៈអង់អាចទាមទារឯករាជ្យ ការបង្រួបបង្រួមប្រទេស និងសុខដុមនីយកម្ម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីការស្រលាញ់ជាតិ មាតុភូមិ សុខសន្តិភាព និងការអភិវឌ្ឍ។ | ៥ម៉ |
| **ជំពូកទី៦ : កិច្ចការខ្ញុំ** | | |
| **មេរៀនទី១ : ទូសម្លៀកបំពាក់របស់ខ្ញុំ**<br>១.១- វិធីបត់សម្លៀកបំពាក់(រូបភាពមានអត្ថបទ)<br>១.២- វិធីរៀបចំទុកដាក់សម្លៀកបំពាក់ទុកក្នុងទូ<br>- កន្លែងទុកដាក់សម្លៀកបំពាក់ក្រៅ<br>- កន្លែងទុកដាក់សម្លៀកបំពាក់ក្នុង | **វិជ្ជាសម្បទា**<br>- បង្ហាញរូបភាពស្ដីពីរបៀបបត់សម្លៀកបំពាក់។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីបត់សម្លៀកបំពាក់និងវិធីរៀបចំទុកដាក់ក្នុងទូសម្លៀកបំពាក់។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការរៀបចំទុកដាក់សម្លៀកបំពាក់ឲ្យ មានសណ្ដាប់ធ្នាប់។ | ២ម៉ |
| **មេរៀនទី២ : ភាពស្មោះត្រង់**<br>២.១- អត្ថន័យនៃពាក្យសីលធម៌និងភាពស្មោះត្រង់<br>២.២- ផលវិបាកនៃទង្វើមិនស្មោះត្រង់ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអត្ថន័យនៃពាក្យសីលធម៌និងភាពស្មោះត្រង់<br>- រៀបរាប់ផលវិបាកនៃទង្វើមិនស្មោះត្រង់។<br>**បំណិនសម្បទា**<br>- បង្ហាញសារៈសំខាន់នៃការប្រកាន់ភាពស្មោះត្រង់<br>- បង្កើតនិងចូលរួមក្នុងល្បែងដើរតួដើម្បីបង្ហាញអារម្មណ៍នៃភាពស្មោះត្រង់និងមិនស្មោះត្រង់នៅក្នុងស្ថានភាពមួយ។ | ៣ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានភាពស្មោះត្រង់និងមានការទទួលខុសត្រូវជានិច្ច។ | |
| **មេរៀនទី៣ : ការទទួលស្គាល់អំពើល្អ**<br>៣.១- ការទទួលស្គាល់អំពើល្អរបស់មិត្ត<br>៣.២- ការទទួលស្គាល់សមត្ថភាពរបស់អ្នកដទៃ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអំពើល្អរបស់មិត្តភក្តិ និងអ្នកដទៃ<br>- ទទួលស្គាល់សមត្ថភាពរបស់អ្នកដទៃ។<br>**បំណិនសម្បទា**<br>- ទទួលស្គាល់សមត្ថភាពរបស់អ្នកដទៃនិងនិយាយរៀបរាប់អំពើល្អ និងទេពកោសល្យរបស់អ្នកដទៃ។<br>**ចរិយាសម្បទា**<br>- ចូលរួមក្នុងសកម្មភាពផ្សេងៗដើម្បីស្វែងយល់ពីអំពើល្អនិងទេពកោសល្យ និងសមត្ថភាពរបស់អ្នកដទៃ។ | ២ម៉ |
| **មេរៀនទី៤: ដំណុះគ្រាប់ស្រូវ**<br>៤.១- រូបភាពកែវដាក់ត្រាំគ្រាប់ស្រូវ៦ឬ៧គ្រាប់ដែលមានដំណើរវិវឌ្ឍជាបន្តបន្ទាប់<br>៤.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- បង្ហាញដំណើរវិវឌ្ឍនៃដំណុះគ្រាប់ស្រូវ តាមរយៈការតម្រៀបរូបភាពតាមលំដាប់លំដោយ។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីបណ្តុះគ្រាប់ស្រូវ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការបណ្តុះគ្រាប់ធញ្ញជាតិ ដើម្បីបង្កើតស្នាដៃ។ | ២ម៉ |
| **មេរៀនទី៥: ស្ងោរសណ្តែកបាយ**<br>៥.១- គ្រឿងផ្សំ<br>៥.២- របៀបធ្វើ<br>៥.៣- ថ្លៃដើម និងថ្លៃលក់នៅទីផ្សារ<br>៥.៤- បង្កើមប្រភេទស្ងោរដទៃទៀត | **វិជ្ជាសម្បទា**<br>- រៀបរាប់គ្រឿងផ្សំ និងវិធីស្ងោរសណ្តែកបាយ។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីស្ងោរសណ្តែកបាយនៅសាលារៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើនំចំណីដោយខ្លួនឯង។ | ២ម៉ |

## ៧.៤- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៤ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : គ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : ការរៀបចំខ្លួន**<br>១.១- អាកប្បកិរិយានិងរបៀបស្លៀកពាក់សមរម្យ<br>១.២- អាកប្បកិរិយានិងរបៀបស្លៀកពាក់ក្នុងការចូលរួមមហោស្រព<br>១.៣- អាកប្បកិរិយានិងរបៀបស្លៀកពាក់ក្នុងពិធីបុណ្យផ្សេងៗ<br>- បុណ្យសព<br>- បុណ្យចូលឆ្នាំ<br>- បុណ្យភ្ជុំបិណ្ឌ | **វិជ្ជាសម្បទា**<br>- អានបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន ហើយប្រាប់ពីរបៀបនៃការស្លៀកពាក់ឱ្យបានសមរម្យក្នុងនាមជាសិស្ស និងរៀបរាប់ពីការតាក់តែងកាយរបស់សិស្សស្រី សិស្សប្រុសឱ្យបានត្រឹមត្រូវ<br>- ពណ៌នារបៀបស្លៀកពាក់ និងការសម្តែងអាកប្បកិរិយានៅពេលចូលរួមក្នុងពិធីបុណ្យ និងមហោស្រពផ្សេងៗ។<br>**បំណិនសម្បទា**<br>- កំណត់បានពីការស្លៀកពាក់ និងការរៀបចំខ្លួនដើម្បីចូលរួមក្នុងពិធីបុណ្យ និងមហោស្រពផ្សេងៗ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីយកចិត្តទុកដាក់ឱ្យតម្លៃផ្ទាល់ខ្លួន នៅពេលចូលរួមក្នុងពិធីបុណ្យ និងមហោស្រពផ្សេងៗជាមួយអ្នកដទៃ។ | ២ម៉ |
| **មេរៀនទី២ : សរិយាបថល្អ**<br>២.១- ការសម្អាតបន្ទប់រៀន សាលារៀន និងកន្លែងសាធាណៈ<br>២.២- អាកប្បកិរិយាត្រឹមត្រូវក្នុងការបរិភោគ<br>២.៣- ការអនុវត្តជាប់ជាប្រចាំក្នុងការចោលសំរាមក្នុងធុង<br>២.៤- អនុវត្តជាប់ប្រចាំក្នុងការសម្អាតបរិស្ថាន | **វិជ្ជាសម្បទា**<br>- ប្រាប់បានសកម្មភាពចូលរួមជួយថែរក្សា សម្អាតបន្ទប់រៀន សាលារៀន និងកន្លែងសាធាណៈ<br>- ប្រាប់បានឥរិយាបថត្រឹមត្រូវក្នុងការបរិភោគ<br>- ប្រាប់បានរបៀបចោលសំរាមបានត្រឹមត្រូវ។<br>**បំណិនសម្បទា**<br>- កំណត់បានពីរបៀបនៃការសម្អាតបន្ទប់រៀន សាលារៀន និងទីសាធារណៈ<br>- កំណត់ទីតាំងនិងអនុវត្តជាប់ជាប្រចាំនូវការចោលសំរាមក្នុងធុងសំរាម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីចូលរួមអនុវត្តជាប់ជាប្រចាំក្នុងការសម្អាតបរិស្ថាន។ | ២ម៉ |
| **មេរៀនទី៣ : កន្លែងដំណេក**<br>៣.១- និយមន័យ "កន្លែងដំណេក"<br>៣.២- សារៈសំខាន់នៃកន្លែងដំណេក<br>៣.៣- របៀបរៀបចំកន្លែងដំណេក | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ និងសារៈសំខាន់នៃកន្លែងដំណេកនៅក្នុងគេហដ្ឋាន។<br>**បំណិនសម្បទា**<br>- រៀបចំឱ្យមានកន្លែងដំណេកនៅក្នុងគេហដ្ឋាន។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់រៀបចំកន្លែងដំណេកនៅក្នុងគេហដ្ឋាន។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤** : **សោភណភាព កន្លែងដំណេក**<br>៤.១- ភាពស្អាតមានអនាម័យ<br>៤.២- របៀបរៀបរយនៃប្រដាប់ប្រដា ដំណេក<br>៤.៣- ការតាំងគ្រឿងលម្អ | **វិជ្ជាសម្បទា**<br>- បង្ហាញពីភាពស្អាតមានអនាម័យ និង របៀបរៀបរយនៃកន្លែងដំណេក។<br>**បំណិនសម្បទា**<br>- រៀបចំកន្លែងដំណេកឱ្យមានសោភណភាព។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃសោភណភាពនៃ កន្លែងដំណេក ក្នុងគេហដ្ឋាន។ | ២ម៉ |
| **មេរៀនទី៥** : **ការទទួលខុសត្រូវ**<br>៥.១- ការទទួលខុសត្រូវទង្វើរបស់ខ្លួន<br>៥.២- អាកប្បកិរិយាប្រកបដោយការ ទទួលខុសត្រូវ(ឧ.ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លួន...)<br>៥.៣- អាកប្បកិរិយាពុំទទួលខុសត្រូវ<br>៥.៤- ការស្រឡាញ់ភាពយុត្តិធម៌<br>៥.៥- ផលប៉ះពាល់នៃការមិនទទួល ខុសត្រូវ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីអាកប្បកិរិយាដែលមានការទទួលខុសត្រូវ និង អាកប្បកិរិយាដែលគ្មានការទទួលខុសត្រូវ<br>- ប្រាប់បានអ្វីដែលត្រូវទទួលខុសត្រូវ និងសារៈសំខាន់នៃ<br>- អាកប្បកិរិយាដែលមានការទទួលខុសត្រូវ ការស្រឡាញ់យុត្តិធម៌។<br>**បំណិនសម្បទា**<br>- កំណត់បានអ្វីដែលត្រូវទទួលខុសត្រូវ និងសារៈសំខាន់នៃ អាកប្បកិរិយាដែលមានការទទួលខុសត្រូវ<br>- កំណត់បានផលប៉ះពាល់ចំពោះអាកប្បកិរិយាដែលគ្មានការ ទទួលខុសត្រូវ។<br>**ចរិយាសម្បទា**<br>- មានទំនួលខុសត្រូវរាល់សកម្មភាពរបស់ខ្លួន។ | ២ម៉ |
| **ជំពូក២ : ភូមិខ្ញុំ** | | |
| **មេរៀនទី១** : **សណ្ឋានដី**<br>១.១- សណ្ឋានដីតំបន់ទំនាប<br>១.២- ខ្ពង់រាបនិងភ្នំ<br>១.២- ភ្នំចាស់<br>១.៣- ភ្នំក្មេង | **វិជ្ជាសម្បទា**<br>- រៀបរាប់និងបង្ហាញឱ្យឃើញពីលក្ខណៈរបស់សណ្ឋានដី តំបន់ទំនាប តំបន់ខ្ពង់រាប ភ្នំ ភ្នំចាស់ ភ្នំក្មេង។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យឃើញពីសារៈសំខាន់របស់សណ្ឋានដីតាមតំបន់ នីមួយៗ។<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិតក្នុងការប្រើប្រាស់ដីឱ្យបានសមស្រប ទៅតាមសណ្ឋានដី ។ | ៦ម៉ |
| **មេរៀនទី២**: **មូលដ្ឋានគ្រឹះនៃ ការសិក្សាប្រវត្តិវិទ្យា**<br>**សិក្សាបញ្ញត្តិ** : ប្រវត្តិសាស្ត្រ ពេលវេលា ភស្តុតាង<br>**មាតិកា** : | **វិជ្ជាសម្បទា**<br>- ប្រាប់ពីនិយមន័យប្រវត្តិវិទ្យា និងប្រវត្តិសាស្ត្រ។<br>**បំណិនសម្បទា**<br>- រៀបលំដាប់កាលដោយយកព្រឹត្តិការណ៍ជាតឹកតាង គិតទាំង ពុទ្ធសករាជ និងគ្រិស្តសករាជ។ | ៥ម៉ |

| | | |
|---|---|---|
| ២.១- ស្វែងយល់ពីអតីតកាល<br>**សំណួរត្រិះរិះ** :<br>• តើប្រវត្តិវិទ្យា និង ប្រវត្តិសាស្ត្រជាអ្វី?<br>• តើប្រវត្តិវិទ្យាសិក្សាពីអ្វីខ្លះ?<br>២.២- ភស្តុតាង និងបំណកស្រាយ<br>**សំណួរត្រិះរិះ** :<br>• តើគេអាចដឹងពីអតីតកាល តាមរយៈអ្វីខ្លះ?<br>២.៣- កាលវិទ្យា<br>ក. ពុទ្ធសករាជ<br>ខ. គ្រិស្តសករាជ<br>• ទសវត្សរ៍<br>• សតវត្សរ៍<br>• សហវត្សរ៍<br>**សំណួរត្រិះរិះ** :<br>• តើទសវត្សរ៍ និងសតវត្សរ៍ជាអ្វី និងគណនាដោយរបៀបណា? | **ចរិយាសម្បទា**<br>- ភ្ជាប់សេចក្ដីសន្និដ្ឋានអំពីប្រវត្តិសាស្ត្រទៅនឹងភស្តុតាង។ | |
| **មេរៀនទី៣ : បុរេប្រវត្តិសាស្ត្រកម្ពុជា**<br>**សិក្សាបញ្ញត្តិ** : ទឹកដី ជនជាតិខ្មែរ ដើមកំណើត លំនៅដ្ឋាន បុរាណវត្ថុ ច្នៃប្រឌិត មរតក<br>**មាតិកា** :<br>៣.១- ជនជាតិខ្មែរ និងជីវភាពរស់នៅ<br>ក. ល្អាងស្ពាន<br>ខ. ក្បាលរមាស<br>គ. ភូមិមូល<br>ឃ. សំរោងសែន និងម្លូព្រៃ<br>ង. អង្គរបុរី<br>**សំណួរត្រិះរិះ** :<br>• តើជនជាតិខ្មែរបានរស់នៅកន្លែងណាខ្លះ និងមានភស្តុតាងបុរាណវិទ្យាអ្វីខ្លះ?<br>• តើលំនៅដ្ឋាន និងការរស់នៅរបស់ខ្មែរមានលក្ខណៈបែបណា? | **វិជ្ជាសម្បទា៖**<br>- ប្រាប់អំពីវត្ថុសិល្បៈក្នុងបុរេប្រវត្តិសាស្ត្រ<br>- រៀបរាប់ពីដើមកំណើត និងការរស់នៅរបស់ជនជាតិខ្មែរ តាមរយៈភស្តុតាងបុរាណវិទ្យា។<br>**បំណិនសម្បទា៖**<br>- ផ្សារភ្ជាប់បុរាណវត្ថុទៅនឹងសកម្មភាពខ្មែរបុរាណ<br>- ភ្ជាប់ទំនាក់ទំនងនៃវត្ថុប្រើប្រាស់ខ្មែរក្នុងបុរេប្រវត្តិសាស្ត្រ ជាមួយនឹងវត្ថុប្រើប្រាស់បច្ចុប្បន្ន។<br>**ចរិយាសម្បទា៖**<br>- សរសេរអត្ថបទខ្លី ពីជីវិតកុមារខ្មែរអាយុ៩ឆ្នាំក្នុងសម័យបុរេប្រវត្តិ<br>- សន្និដ្ឋានរួមអំពីការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមានក្នុងការច្នៃប្រឌិត បង្កើតវត្ថុប្រើប្រាស់ជាប្រយោជន៍ដល់មនុស្សជាតិ។ | ៥ ម៉ |

| | | |
|---|---|---|
| មានអ្វីជាភស្តុតាង?<br>៣.២- កេរមរតកសម័យបុរេប្រវត្តិ<br>ក. គំនូរសម័យបុរេប្រវត្តិ<br>ខ. វត្ថុបុរាណ<br>**សំណួរត្រិះរិះ** :<br>• តើក្នុងភូមិរបស់អ្នកមានវត្ថុប្រើប្រាស់ ឬវត្ថុសិល្បៈអ្វីខ្លះស្រដៀងគ្នានឹងវត្ថុប្រើប្រាស់ និងវត្ថុសិល្បៈក្នុងសម័យបុរេប្រវត្តិសាស្ត្រ?<br>• ហេតុអ្វីបានជាប្រជាជនខ្មែរក្នុងបុរេប្រវត្តិសាស្ត្រផលិតវត្ថុប្រើប្រាស់ និងវត្ថុសិល្បៈ?<br>៣.៣- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ**:<br>• ពលរដ្ឋមានគុណធម៌ត្រូវប្រកាន់ការគិតវាចា និងការប្រព្រឹត្តិដូចម្ដេចខ្លះដើម្បីបន្តនិរន្តរភាពនៃការច្នៃប្រឌិតវត្ថុប្រើប្រាស់ និងវត្ថុសិល្បៈជាប្រយោជន៍ជាតិ និងមនុស្សជាតិ? | | |
| **មេរៀនទី៤** : **សិប្បករនៅភូមិខ្ញុំ**<br>៤.១- សិប្បករប្រភេទផ្សេងៗ នៅកម្ពុជា<br>៤.២- លក្ខណសម្បត្តិរួមរបស់សិប្បករ<br>៤.៣- ស្នាដៃរបស់សិប្បករ<br>៤.៤- អត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់សិប្បករ<br>- កម្រៃពលកម្ម<br>- ភាពជាម្ចាស់ស្នាដៃ<br>- ការទទួលស្គាល់ស្នាដៃ | **វិជ្ជាសម្បទា**<br>- រៀបរាប់សិប្បករប្រភេទផ្សេងៗនិងលក្ខណសម្បត្តិតាមអត្ថបទមេរៀន។<br>**បំណិនសម្បទា**<br>- សង្កេតសម្គាល់បាននិងគ្រាប់តាមគំរូនៃភាពស្ទិតស្ទាញក្នុងការងាររបស់សិប្បករផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃ និងគោរពការងាររបស់សិប្បករផ្សេងៗ។ | ២ម៉ |
| **មេរៀនទី៥** : **កម្រងសិទ្ធិទាំងបួនរបស់កុមារ**<br>៥.១- កម្រងសិទ្ធិរស់រានមានជីវិត<br>៥.២- កម្រងសិទ្ធិក្នុងការអភិវឌ្ឍ<br>៥.៣- កម្រងសិទ្ធិទទួលការការពារ | **វិជ្ជាសម្បទា**<br>- ពណ៌នាកម្រងសិទ្ធិទាំងបួនរបស់កុមារនិងព្រំដែននៃសិទ្ធិ។<br>**បំណិនសម្បទា**<br>- ឱ្យឈ្មោះ និងអនុវត្តសិទ្ធិសំខាន់ៗរបស់ខ្លួនឱ្យស្ថិតក្នុងព្រំដែននៃសិទ្ធិ។ | ២ម៉ |

| | | |
|---|---|---|
| ៥.៤- កម្រងសិទ្ធិក្នុងការចូលរួម | **ចរិយសម្បទា**<br>- ចូលរួមលើកស្ទួយសិទ្ធិកុមារ ហើយកុមារត្រូវស្រឡាញ់រាប់អាន និងជួយគ្នាទៅវិញទៅមក។ | |
| **មេរៀនទី៦** : **នំគូរ**<br>៦.១- គ្រឿងផ្សំ<br>៦.២- របៀបធ្វើ<br>៦.៣- គណនានិងប្រៀបធៀប ថ្លៃដើម និងតម្លៃលក់នៅទីផ្សារ<br>៦.៤- ប្រភេទនំគូរដទៃទៀត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគ្រឿងផ្សំ និងរបៀបធ្វើនំគូរ។<br>**បំណិនសម្បទា**<br>- អនុវត្តការធ្វើនំគូររួចហើយគណនានិងប្រៀបធៀបថ្លៃដើម និងតម្លៃលក់នៅទីផ្សារ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើនំចំណីដោយខ្លួនឯង។ | ២ម៉ |

| **ជំពូក៣ : សហគមន៍ខ្ញុំ** | | |
|---|---|---|
| **មេរៀនទី១** : **ហ្វូណន និង រដ្ឋដំបូងនៅអាស៊ីអាគ្នេយ៍**<br>**សិក្សាបញ្ញត្តិ :** រឿងព្រេង រដ្ឋ ភស្តុតាង មរតក និរន្តរភាព ទសពិធរាជធម៌ ចរិតវិជ្ជមាន<br>**មាតិកា :**<br>១.១- រដ្ឋដំបូង<br>ក. ការកកើតរដ្ឋហ្វូណនតាមរយៈរឿងព្រេង (ព្រះថោង នាងនាគ)<br>ខ. ការកកើតរដ្ឋហ្វូណនតាមរយៈសិលាចារឹកចាម (កៅណ្ឌិន្យ សោមា)<br>គ. ការកកើតរដ្ឋហ្វូណនតាមរយៈកំណត់ត្រាចិន(ហ៊ុនទៀន លីវយី)<br>ឃ. ការកកើតរដ្ឋហ្វូណនតាមរយៈភស្តុតាង<br>**សំណួរគន្លឹះ** :<br>• តើមានការពន្យល់យ៉ាងដូចម្តេចខ្លះស្តីពីដើមកំណើតរដ្ឋខ្មែរដំបូង?<br>១.២- ទីតាំងភូមិសាស្ត្រ<br>ក. អាណាចក្រហ្វូណន<br>ខ. រាជធានី | **វិជ្ជាសម្បទា៖**<br>- ប្រាប់ពីការកកើតរដ្ឋហ្វូណនតាមរយៈរឿងព្រេង<br>- ប្រាប់ពីការកកើតរដ្ឋដោយប្រើភស្តុតាងបុរាណវិទ្យា<br>- ប្រាប់អំពីទីកន្លែងសំខាន់ៗ និងរាជធានីក្នុងសម័យហ្វូណន ដោយប្រើភស្តុតាងបុរាណវិទ្យា<br>- ប្រាប់អំពីព្រះរាជាដែលមានស្នាដៃ និងមនុស្សសំខាន់ៗក្នុងសម័យហ្វូណន<br>- រៀបរាប់ពីស្នាព្រះហស្តផ្នែកស្ថាបត្យកម្ម និងការអភិវឌ្ឍវប្បធម៌ និងសេដ្ឋកិច្ចរបស់ព្រះរាជាមួយអង្គៗ។<br>**បំណិនសម្បទា៖**<br>- ប្រៀបធៀបគោលការណ៍ដឹកនាំនៃព្រះរាជាមួយអង្គៗ។<br>**ចរិយាសម្បទា៖**<br>- សន្និដ្ឋានរួមអំពីការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមានដើម្បីថែរក្សា និងអភិវឌ្ឍមរតកប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្សជាតិ។ | ៥ម៉ |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើហ្វូណនលាតសន្ធឹងពីណាដល់ណាធៀបនឹងទីតាំងបច្ចុប្បន្ន និងមានភស្តុតាងបុរាណវិទ្យាអ្វីខ្លះបន្សល់ទុក?<br>១.៣- សន្តតិវង្ស និងស្នាព្រះហស្ត<br>ក. ព្រះបាទកៅណ្ឌិន្យ និងមេត្តាធម៌<br>ខ. ព្រះបាទស្រីមារៈ(ហ្វាន់ចេម៉ាន់)៖ ឧស្សាហ៍ព្យាយាម និងស្មោះត្រង់<br>**សំណួរត្រិះរិះ** :<br>• សម័យកាលហ្វូណនមានព្រះរាជាណាខ្លះដែលបន្សល់ស្នាព្រះហស្តដល់មនុស្សជំនាន់ក្រោយ?<br>១.៤- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• ហេតុអ្វីបានជាអ្នកដឹកនាំត្រូវមានមេត្តាធម៌ ការឧស្សាហ៍ព្យាយាម និងស្មោះត្រង់? | | |
| **មេរៀនទី២** : **សណ្ឋានដីប្រទេសកម្ពុជា**<br>២.១- សណ្ឋានដីតំបន់ទំនាបកណ្ដាល<br>២.២- សណ្ឋានដីតំបន់ខ្ពង់រាប<br>២.៣- សណ្ឋានដីតំបន់ភ្នំ និងកូនភ្នំ<br>២.៤- សណ្ឋានដីតំបន់មាត់សមុទ្រ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីសណ្ឋានដី តំបន់ទំនាបកណ្ដាល តំបន់ខ្ពង់រាប តំបន់ភ្នំនិងកូនភ្នំ និងតំបន់មាត់សមុទ្រ។<br>**បំណិនសម្បទា**<br>- ចេះប្រៀបធៀបតំបន់សណ្ឋានដី។<br>**ចរិយាសម្បទា**<br>- បណ្ដុះគំនិតស្រឡាញ់មាតុភូមិរបស់ខ្លួនដោយសារភាពអំណោយផលនៃសណ្ឋានដី។ | ៥ម៉ |
| **មេរៀនទី៣** : **បុណ្យប្រពៃណី**<br>៣.១- អត្ថន័យ និងសារៈសំខាន់នៃពិធីបុណ្យកឋិន<br>៣.២- អត្ថន័យ និងសារៈសំខាន់នៃពិធីបុណ្យមាឃបូជា<br>៣.៣- អត្ថន័យ និងសារៈសំខាន់នៃពិធីបុណ្យពិសាខបូជា | **វិជ្ជាសម្បទា**<br>- រៀបរាប់កាលបរិច្ឆេទ អត្ថន័យ និងសារៈសំខាន់នៃពិធីបុណ្យកឋិនទាន មាឃបូជា និងពិសាខបូជា។<br>**បំណិនសម្បទា**<br>- កំណត់បានពីរបៀបរៀបចំពិធីបុណ្យកឋិនទាន មាឃបូជា ពិសាខបូជា និងការប្រតិបត្តិ។<br>**ចរិយាសម្បទា**<br>- ចូលរួមគោរពប្រតិបត្តិពិធីសាសនា និងថែរក្សាប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤: សម្បត្តិរបស់ម្ដាយខ្ញុំ**<br>៤.១- វិជ្ជាសម្បត្តិ<br>៤.២- ចរិយាសម្បត្តិ<br>៤.៣- រូបសម្បត្តិ<br>៤.៤- ទ្រព្យសម្បត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ផ្ទាល់មាត់ វិជ្ជាសម្បត្តិ ចរិយាសម្បត្តិ រូបសម្បត្តិរបស់អ្នកម្ដាយក្នុងអត្ថបទមេរៀន។<br>**បំណិនសម្បទា**<br>- សរសេរអំពីគុណសម្បត្តិរបស់ម្ដាយខ្លួន ពាក់ព័ន្ធនឹងសម្បត្តិទាំងបួន ក្នុងនោះមានការរក្សា និងគ្រប់គ្រងទ្រព្យសម្បត្តិ។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់អ្នកម្ដាយ។ | ២ម៉ |
| **មេរៀនទី៥ : ភាពស្មោះត្រង់ចំពោះជាតិ**<br>២.១- អត្ថន័យនៃពាក្យ ស្មោះត្រង់<br>២.២- ភាពស្មោះត្រង់ចំពោះជាតិ<br>២.៣- ភាពស្មោះត្រង់ចំពោះសាសនា<br>២.៤- ភាពស្មោះត្រង់ចំពោះព្រះមហាក្សត្រ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអត្ថន័យនៃពាក្យ ស្មោះត្រង់ ភាពស្មោះត្រង់ចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។<br>- រៀបរាប់ផលវិបាកនៃទង្វើមិនស្មោះត្រង់ចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។<br>**បំណិនសម្បទា**<br>- បង្ហាញសារៈសំខាន់នៃការប្រកាន់ភាពស្មោះត្រង់ចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។<br>**ចរិយាសម្បទា**<br>- មានភាពស្មោះត្រង់និងមានភក្ដីភាពចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។ | ៣ម៉ |
| **ជំពូក៤ : ស្រុកខ្ញុំ** | | |
| **មេរៀនទី១ : ការគោរព (ទំនាក់ទំនងល្អក្នុងសហគមន៍)**<br>១.១- អត្ថន័យនៃការគោរព<br>១.២- ការប្រព្រឹត្តិឥរិយាបថអាចទទួលបានការគោរព<br>១.៣- សាមគ្គីភាព និងការអត់ឱនអធ្យាស្រ័យគ្នា<br>១.៤- ការចរចានិងដំណោះស្រាយ | **វិជ្ជាសម្បទា**<br>- ពន្យល់បានអត្ថន័យនៃ " ការគោរព "<br>- ប្រាប់បានអំពីការប្រព្រឹត្តឥរិយាបថរបស់ខ្លួនដែលអាចទទួលបានការឱ្យតម្លៃពីអ្នកដទៃ<br>- ប្រាប់បានអំពីសារៈសំខាន់នៃសាមគ្គីភាព ការអត់ឱនអធ្យាស្រ័យ ការប្រាស្រ័យទាក់ទងគ្នា ចេះចរចានិងដោះស្រាយទំនាស់។<br>**បំណិនសម្បទា**<br>- កំណត់ឥរិយាបថដែលបង្ហាញការគោរពគ្នាទៅវិញទៅមក<br>- រកវិធីដើម្បីបង្កើនសាមគ្គីភាព ការអត់ឱនអធ្យាស្រ័យគ្នា និងការដោះស្រាយបញ្ហាដោយសន្តិវិធី។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ឥរិយាបថគោរពគ្នាទៅវិញទៅមក បង្កើនសាមគ្គីភាព និងដោះស្រាយទំនាស់ដោយអហិង្សា។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : ចេនឡា និង វីរនារីពីមហាក្សត្រ**<br>**សិក្សាបញ្ញត្តិ** : ការដឹកនាំ ក្សត្រីយានី ក្សត្របុរី<br>**មាតិកា :**<br>២.១- ទីតាំងភូមិសាស្ត្រ<br>ក.អាណាចក្រចេនឡា<br>ខ.រាជធានី<br>**សំណួរត្រិះរិះ** :<br>• តើចេនឡា លាតសន្ធឹងពីណាដល់ណាធៀបនឹងទីតាំងបច្ចុប្បន្ន? តើមានភស្តុតាងអ្វីខ្លះបន្សល់ទុក?<br>• តើរាជធានីស្ថិតនៅឯណាធៀបនឹងទីតាំងបច្ចុប្បន្ន?<br>២.២- ចេនឡា និងក្សត្របុរី<br>**សំណួរត្រិះរិះ** :<br>• តើសម័យកាលចេនឡា មានក្សត្របុរីសំខាន់ៗ អ្វីខ្លះ? និងនៅទីកន្លែងណាធៀបនឹងទីតាំងបច្ចុប្បន្ន? មានភស្តុតាងអ្វីខ្លះបន្សល់ទុក?<br>២.៣- ការហៅឈ្មោះ<br>**សំណួរត្រិះរិះ** :<br>• តើមានទស្សនៈអ្វីខ្លះបានពន្យល់ពីអត្ថន័យនៃពាក្យ **ចេនឡា**?<br>២.៤- សន្តតិវង្ស និងស្នាព្រះហស្ត<br>ក. ព្រះបាទភវវរ្ម័នទី១ និងសុខទុក្ខរបស់រាស្ត្រ<br>ខ. ព្រះបាទមហេន្ទ្រវរ្ម័នទី១ និងភក្តីភាព<br>គ. ព្រះបាទឥសានវរ្ម័នទី១ និងសន្តិភាព<br>ឃ. ព្រះបាទជ័យវរ្ម័នទី១ និងគំនិតផ្តួចផ្តើម<br>ង. ព្រះនាងជ័យទេវី និង ភាពរឹងប៉ឹង | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីវិសាលភាពទឹកដីដោយប្រើភស្តុតាង<br>- ប្រាប់អំពីរាជធានី និងក្សត្របុរីសំខាន់ៗក្នុងសម័យចេនឡាដោយប្រើភស្តុតាង<br>- ប្រាប់អត្ថន័យពាក្យ ចេនឡា តាមទស្សនៈផ្សេងៗ<br>- ប្រាប់អំពីព្រះរាជាដែលមានស្នាព្រះហស្ត និងមនុស្សសំខាន់ៗក្នុងសម័យចេនឡា<br>- រៀបរាប់អំពីស្នាព្រះហស្តផ្នែកស្ថាបត្យកម្ម និងវប្បធម៌របស់ព្រះរាជាមួយអង្គៗ។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យបានពីវីរភាពរបស់ស្ត្រីខ្មែរក្នុងការអភិវឌ្ឍជាតិ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីការគិត វាចា និងទង្វើវិជ្ជមាន ដើម្បីថែរក្សា និងអភិវឌ្ឍមរតកប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្សជាតិ។ | ៦ ម៉ |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើមានព្រះរាជាសម័យកាលចេនឡាអង្គណាខ្លះដែលមានភាពជាអ្នកដឹកនាំល្អ?<br>• តើភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈបែបណារបស់ព្រះរាជាមួយអង្គៗ ដែលគួរឱ្យមនុស្សជំនាន់ក្រោយប្រតិបត្តិតាម?<br>• តើព្រះរាជាមួយអង្គៗបានបន្សល់មរតកល្អអ្វីខ្លះដល់មនុស្សជំនាន់ក្រោយ និងដល់ពិភពលោក?<br>• តើហេតុអ្វីបានជាព្រះនាងជ័យទេវី ក្លាយជាមហាក្សត្រីដែលមានការទទួលស្គាល់?<br>២.៥- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• តើចំណុចល្អអ្វីខ្លះ ដែលប្អូនបានរៀនសូត្រពីព្រះមហាក្សត្រខ្មែរ? | | |
| **មេរៀនទី៣** : **ការប្រើប្រាស់ដីនៅតាមតំបន់នានា**<br>៣.១- ដីដាំដុះដំណាំស្រូវ<br>៣.២- ដីដាំដុះដំណាំចម្ការ និងដំណាំបន្ទាប់បន្សំ<br>៣.៣- ដីដាំដុះដំណាំឧស្សាហកម្ម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការប្រើប្រាស់ដីនៅតាមតំបន់ ។<br>**បំណិនសម្បទា**<br>- ចេះបែងចែកប្រភេទដីទៅតាមតំបន់ និងប្រើប្រាស់ដីលើការដាំដុះក្នុងជីវភាពប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- មានគំនិតក្នុងការថែរក្សាការពារគុណភាពដី និងស្រឡាញ់ការងារកសិកម្ម។ | ៦ម៉ |
| **មេរៀនទី៤** : **ភាពជឿជាក់**<br>៤.១- សកម្មភាពបង្ហាញនូវភាពស្មោះត្រង់<br>៤.២- ការសេពគប់មិត្តភក្តិ និងការប្រុងប្រយ័ត្ន<br>៤.៣- ការផ្សព្វផ្សាយទង្វើល្អ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអាកប្បកិរិយាសកម្មភាពដែលនាំឱ្យទទួលបានភាពជឿជាក់។(ឧ.ការទទួលខុសត្រូវលើកម្ចី និងបំណុល...)<br>- រៀបរាប់លក្ខណសម្បត្តិនៃមិត្តដែលត្រូវសេពគប់។<br>**បំណិនសម្បទា**<br>- កំណត់បានអាកប្បកិរិយា ឬសកម្មភាពបង្ហាញនូវភាពស្មោះត្រង់ក្នុងការសេពគប់មិត្តភក្តិ។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយត្នជានិច្ចក្នុងការសេពគប់មិត្តភក្តិ និងបង្កើនការជឿជាក់។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : ការធ្វើជីកំប៉ុស**<br>៥.១- សារប្រយោជន៍នៃជីកំប៉ុស<br>៥.២- របៀបធ្វើជីកំប៉ុស | **វិជ្ជាសម្បទា**<br>- រៀបរាប់សមាសធាតុនៃជីកំប៉ុស។<br>**បំណិនសម្បទា**<br>- ចេះរបៀបធ្វើជីកំប៉ុស។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើជីកំប៉ុស។ | ២ម៉ |
| **មេរៀនទី៦:ប្រើប្រាស់ជីកំប៉ុសទឹក**<br>៦.១- របៀបប្រើប្រាស់ជីកំប៉ុសទឹក<br>៦.២- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់វិធីប្រើប្រាស់ជីកំប៉ុសទឹក។<br>**បំណិនសម្បទា**<br>- បង្ហាញ ឬអនុវត្តការប្រើប្រាស់ជីកំប៉ុសទឹក។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការប្រើប្រាស់ជីកំប៉ុសទឹក។ | ២ម៉ |

| **ជំពូក៥ : សង្គមជាតិ** | | |
|---|---|---|
| **មេរៀនទី១ : សុវត្ថិភាពក្នុង ការធ្វើដំណើរ**<br>១.១- ការឆ្លងផ្លូវ<br>១.២- ផ្លូវសុវត្ថិភាពសម្រាប់ថ្មើរជើង<br>១.៣- សុវត្ថិភាពអ្នកដំណើរ<br>១.៤- មួកសុវត្ថិភាព<br>១.៥- សុវត្ថិភាពអ្នកជិះកង់ | **វិជ្ជាសម្បទា**<br>- រៀបរាប់វិធីនៃការឆ្លងផ្លូវ  សុវត្ថិភាពក្នុងការធ្វើដំណើរ ការជិះកង់ និងការពាក់មួកសុវត្ថិភាព។<br>**បំណិនសម្បទា**<br>- បង្ហាញសុវត្ថិភាពនៃការធ្វើដំណើរដោយថ្មើរជើងនិងការ ជិះកង់<br>- អនុវត្តការពាក់មួកសុវត្ថិភាពបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- គោរពច្បាប់ចរាចរណ៍គ្រប់ពេលវេលាដើម្បីសុវត្ថិភាព រាងកាយ។ | ២ម៉ |
| **មេរៀនទី២ : ចក្រភពអង្គរ និង គំនិតច្នៃប្រឌិត**<br>**សិក្ខាបញ្ញត្តិ :** ចក្រពត្តិ, ភូមិសាស្ត្រ, កាលប្រវត្តិ, ការអភិវឌ្ឍ, វីរភាព, ជ័យភូមិ តម្លៃមនុស្ស, បរិយាបន្ន, ការចូលរួម គំនិតផ្តួចផ្តើម, វប្បធម៌កត្តញ្ញូ<br>**មាតិកា :**<br>២.១- ទីតាំងភូមិសាស្ត្រ និងភស្តុតាង<br>ក. វិសាលភាពទឹកដី<br>ខ. រាជធានី<br>**សំណួរត្រិះរិះ :**<br>• តើចក្រភពអង្គរមានវិសាលភាព | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីវិសាលភាពនៃចក្រភពអង្គរដោយផ្អែកលើភស្តុតាង<br>- ប្រាប់អំពីលក្ខណៈពិសេសនៃរាជធានីក្នុងសម័យអង្គរ និងអំណោយផលនៃទីតាំងភូមិសាស្ត្រ ដោយប្រើភស្តុតាង<br>- ប្រាប់ពីភាពខ្លាំង ស្នាព្រះហស្ត និងទស្សនវិជ្ជាក្នុងការដឹកនាំ រដ្ឋរបស់ព្រះមហាក្សត្រសំខាន់ៗក្នុងសម័យអង្គរ។<br>**បំណិនសម្បទា**<br>- សង្ខេបពីជីវប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧<br>- លើកឧទាហរណ៍ និងភស្តុតាងអំពីតួនាទីរបស់ស្ត្រីក្នុងការ កសាងជាតិ។<br>**ចរិយាសម្បទា**<br>- ធ្វើបទបង្ហាញស្តីពីការចូលរួមក្នុងការថែរក្សាបេតិកភណ្ឌជាតិ | ៦ ម៉ |

| | | |
|---|---|---|
| ទឹកដីយ៉ាងដូចម្តេច? មានអ្វីជាភស្តុតាង?<br>• តើតំបន់អង្គរមានលក្ខណៈសម្បត្តិបែបណា ទើបគេចាត់ទុកជាជ័យភូមិ?<br>• តើរាជធានីអង្គរសង់ឡើងជាប៉ុន្មានដំណាក់កាល? មានអ្វីជាភស្តុតាង?<br>• ហេតុអ្វីបានជាបុព្វបុរសខ្មែរកសាងប្រាសាទស្នូលក្នុងរាជធានី?<br>២.២- ព្រះមហាក្សត្រ និងការប្តេជ្ញាចិត្ត<br>ក. ជ័យវរ្ម័នទី២ និងការកសាងចក្រពត្តិ<br>ខ. យសោវរ្ម័នទី១ និងគំនិតច្នៃប្រឌិត<br>គ. ឧទយាទិត្យវរ្ម័នទី២ និងការបន្តនិរន្តរភាព<br>ឃ. សូរ្យវរ្ម័នទី២ និងភាពអំណត់<br>**សំណួរត្រិះរិះ** :<br>• តើសម័យកាលចក្រភពអង្គរមានព្រះរាជាសំខាន់ៗ អង្គណាខ្លះ? តើព្រះអង្គមានគុណសម្បត្តិអ្វីខ្លះ?<br>• តើព្រះអង្គមានគុណតម្លៃ និងទស្សនវិជ្ជាយ៉ាងដូចម្តេចខ្លះក្នុងការគ្រប់គ្រងរដ្ឋ?<br>២.៣- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• តើប្អូនអាចចូលរួមក្នុងការថែរក្សាបេតិកភណ្ឌជាតិក្នុងសម័យអង្គរបានតាមសកម្មភាពអ្វីខ្លះ?<br>• សរសេរអត្ថបទខ្លីស្តីពីលក្ខណៈសម្បត្តិល្អចំនួន៥របស់ព្រះមហាក្សត្រខ្មែរដែល គួរប្រកាន់យកដោយបញ្ជាក់ពីមូលហេតុ។ | ក្នុងសម័យអង្គរ<br>- សរសេរអត្ថបទខ្លីស្តីពីលក្ខណៈសម្បត្តិល្អចំនួន៥របស់ព្រះមហាក្សត្រខ្មែរដែលកូនខ្មែរគួរប្រកាន់យកដោយបញ្ជាក់ពីមូលហេតុ។ | |

| | | |
|---|---|---|
| **មេរៀនទី៣ : អភិបាលកិច្ច**<br>៣.១- អភិបាលកិច្ចល្អ<br>៣.២- ប្រជាធិបតេយ្យមូលដ្ឋាន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីបញ្ញត្តិនៃអភិបាលកិច្ចល្អ និងប្រជាធិបតេយ្យមូលដ្ឋាន។<br>- រៀបរាប់បានពីការគ្រប់គ្រងបែបប្រជាធិបតេយ្យ<br>**បំណិនសម្បទា**<br>- ឆ្លុះបញ្ចាំងពីការងារអភិបាលកិច្ចល្អនិងប្រជាធិបតេយ្យដែលបានជួបប្រទះក្នុងមូលដ្ឋានរស់នៅ។<br>**ចរិយាសម្បទា**<br>- មានស្មារតីចូលរួមអភិវឌ្ឍមូលដ្ឋានស្របតាមគោលការណ៍អភិបាលល្អ និងប្រជាធិបតេយ្យ។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤ : គូរចម្លងផែនទីប្រទេសកម្ពុជា**<br>៤.១- គូរចម្លងផែនទី<br>៤.២- ផាត់ពណ៌លើផែនទី | **វិជ្ជាសម្បទា**<br>- ចេះពីរបៀបគូរចម្លងផែនទី និងដាក់ពណ៌កំណត់សម្គាល់។<br>**បំណិនសម្បទា**<br>- ពន្យល់បានពីកំណត់សម្គាល់នៅលើផែនទីទៅតាមពណ៌ និងតាមទីតាំងនីមួយៗ<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងចូលចិត្តគូរផែនទី | ៦ម៉ |
| **មេរៀនទី៥ : បូរណភាពរាងកាយ**<br>៥.១- ផ្នែកឯកជននៃរាងកាយ<br>៥.២- ការអនុញ្ញាតនិងការមិនអនុញ្ញាតឱ្យប៉ះពាល់រាងកាយ<br>៥.៣- ការប៉ះពាល់រាងកាយក្នុងបំណងល្អនិងក្នុងបំណងមិនល្អ | **វិជ្ជាសម្បទា**<br>- រៀបរាប់ផលល្អ និងផលអាក្រក់នៃការប៉ះពាល់រាងកាយដោយមានការអនុញ្ញាតនិងគ្មានការអនុញ្ញាត។<br>**បំណិនសម្បទា**<br>- បែងចែកបានច្បាស់លាស់អំពីបំណងនៃការប៉ះពាល់រាងកាយ<br>- វិភាគអំពីបំណងនៃការប៉ះពាល់រាងកាយ និងទំនាក់ទំនងទៅនឹងការរំលោភបំពានផ្លូវភេទ។<br>**ចរិយាសម្បទា**<br>- ការពារខ្លួនឱ្យចៀសផុតពីអំពើរំលោភបំពាននានា។ | ២ម៉ |
| **មេរៀនទី៦ : សីលធម៌**<br>៦.១- អត្ថន័យពាក្យសីលធម៌<br>៦.២- សីលធម៌ និងអសីលធម៌<br>៦.៣- ការគោរពវិន័យសាលារៀន និងវិន័យគ្រួសារ<br>៦.៤- ការគោរពច្បាប់សង្គម | **វិជ្ជាសម្បទា**<br>- ប្រាប់បានអត្ថន័យនៃពាក្យសីលធម៌<br>- ពន្យល់ឥរិយាបថប្រកបដោយសីលធម៌ និងសេចក្ដីថ្លៃថ្នូរ<br>- រៀបរាប់មូលហេតុនៃការគោរពវិន័យ និងគោរពច្បាប់សង្គម។<br>**បំណិនសម្បទា**<br>- បង្ហាញឥរិយាបថប្រកបដោយសីលធម៌ សេចក្ដីថ្លៃថ្នូរ ជាកូនល្អ សិស្សល្អ មិត្តល្អ<br>- បង្ហាញផលវិបាកនៃឥរិយាបថប្រកបដោយអសីលធម៌។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ និងណែនាំមិត្តភក្ដិឱ្យចេះគោរពច្បាប់ វិន័យគ្រួសារ សាលារៀន និងសង្គម។ | ៣ម៉ |

| ជំពូកទី៦ : កិច្ចការខ្ញុំ | | |
|---|---|---|
| **មេរៀនទី១ : ថ្នេរដាន**<br>១.១- និយមន័យ "ថ្នេរដាន"<br>១.២- របៀបដេរថ្នេរដាន<br>១.៣- សារៈសំខាន់នៃថ្នេរដាន<br>១.៤- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យថ្នេរដាន របៀបដេរថ្នេរដាន និងសារៈសំខាន់នៃដេរថ្នេរដាន។<br>**បំណិនសម្បទា**<br>- បត់ជាយកន្សែងហើយដេរថ្នេរដាន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដេរដោយដៃក្នុងករណីចាំបាច់។ | ២ម៉ |
| **មេរៀនទី២ : ថ្នេរថយឡាំង**<br>២.១- និយមន័យ "ថ្នេរថយឡាំង"<br>២.២- របៀបដេរថ្នេរថយឡាំង<br>២.៣- សារៈសំខាន់នៃថ្នេរថយឡាំង<br>២.៤- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ របៀបដេរ និងសារៈ សំខាន់នៃថ្នេរថយឡាំង។<br>**បំណិនសម្បទា**<br>- បត់ជាយកន្សែងហើយដេរថ្នេរថយឡាំង។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដេរដោយដៃក្នុងករណីចាំបាច់។ | ២ម៉ |
| **មេរៀនទី៣ : ផ្កាម៉ោងដប់**<br>៣.១- រូបភាពផ្កាម៉ោងដប់<br>៣.២- លក្ខណៈរូបនៃផ្កាម៉ោងដប់<br>៣.៣- ផលប្រយោជន៍នៃផ្កាម៉ោងដប់<br>៣.៤- របៀបដាំផ្កាម៉ោងដប់<br>៣.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់លក្ខណៈរូបនៃផ្កាម៉ោងដប់ ផលប្រយោជន៍នៃផ្កាម៉ោងដប់។<br>**បំណិនសម្បទា**<br>- ដាំផ្កាម៉ោងដប់ដាក់ក្នុងផើងហើយថែទាំបានល្អ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដាំផ្កាផ្សេងៗ ដើម្បីបង្កើតសោភ័ណភាពនៃទីកន្លែងរស់នៅ។ | ២ម៉ |
| **មេរៀនទី៤ : ដងកាំបិត**<br>៤.១- រូបភាពមុខងារនៃកាំបិតផ្សេងៗ<br>៤.២- ប្រភេទដងកាំបិត<br>៤.៣- របៀបដាក់ដងកាំបិត<br>៤.៤- រូបភាពឧបករណ៍ទំនើបប្រើមុខកាំបិត | **វិជ្ជាសម្បទា**<br>- ប្រាប់មុខងារនៃកាំបិតប្រភេទផ្សេងៗ។<br>**បំណិនសម្បទា**<br>- ចេះរបៀបដាក់ដងកាំបិត។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការច្នៃបង្កើតឧបករណ៍ប្រើប្រាស់ផ្សេងៗដោយដៃក្នុងករណីចាំបាច់។ | ២ម៉ |
| **មេរៀនទី៥ : ដងពូថៅនិងដងញញួរ**<br>៥.១- រូបភាព មុខងារនៃពូថៅ និងដងញញួរ<br>៥.២- ប្រភេទដងពូថៅ និងដងញញួរ<br>៥.៣- របៀបដាក់ដងពូថៅ និងដងញញួរ | **វិជ្ជាសម្បទា**<br>- ប្រាប់មុខងារនៃពូថៅ និងញញួរ។<br>**បំណិនសម្បទា**<br>- ចេះរបៀបដាក់ដងពូថៅ និងដងញញួរ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការច្នៃបង្កើតឧបករណ៍ប្រើប្រាស់ផ្សេងៗដោយដៃក្នុងករណីចាំបាច់។ | ១ម៉ |

## ៧.៥- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៥ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១ : គ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : ឥរិយាបថល្អនៅផ្ទះ**<br>១.១- សណ្តាប់ធ្នាប់ល្អក្នុងគេហដ្ឋាន<br>១.២- សណ្តាប់ធ្នាប់ល្អក្នុងការទទួលទានអាហារ<br>១.៣- ការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវមកលេងផ្ទះ | **វិជ្ជាសម្បទា**<br>- រៀបរាប់សណ្តាប់ធ្នាប់ល្អក្នុងគេហដ្ឋាន ការទទួលទានអាហារ ការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវមកលេងផ្ទះ។<br>**បំណិនសម្បទា**<br>- បង្ហាញសណ្តាប់ធ្នាប់ល្អក្នុងគេហដ្ឋាន សណ្តាប់ធ្នាប់ល្អក្នុងការទទួលទានអាហារ និងការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវមកលេងផ្ទះ<br>- ចូលរួមសម្តែងតួអំពីការរៀបចំសណ្តាប់ធ្នាប់ល្អក្នុងគេហដ្ឋាន សណ្តាប់ធ្នាប់ល្អក្នុងការទទួលទានអាហារ និងការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវមកលេងផ្ទះ។<br>**ចរិយាសម្បទា**<br>- បណ្តុះឥរិយាបថឱ្យមានសណ្តាប់ធ្នាប់ក្នុងគ្រួសារ ការទទួលទានអាហារ និងទទួលភ្ញៀវឱ្យបានសមរម្យ។ | ២ម៉ |
| **មេរៀនទី២ : ការប្រព្រឹត្តអំពើល្អ**<br>២.១- អាកប្បកិរិយាសមរម្យ និងមិនសមរម្យ<br>២.២-ការគោរពចាស់ព្រឹទ្ធាចារ្យ តាមបែបខ្មែរ និងជាតិសាសន៍ផ្សេងៗ ( ជនជាតិជប៉ុន និងជនជាតិអឺរ៉ុប)<br>- | **វិជ្ជាសម្បទា**<br>- ពន្យល់ភាពខុសគ្នារវាងអាកប្បកិរិយាសមរម្យ និងមិនសមរម្យ<br>- រៀបរាប់អាកប្បកិរិយាគោរពចំពោះចាស់ព្រឹទ្ធាចារ្យតាមទំនៀមទម្លាប់ចំពោះជនជាតិខ្លួន និងសាសន៍ដទៃ។<br>**បំណិនសម្បទា**<br>- សម្តែងកាយវិការបង្ហាញពីតម្លៃនៃឥរិយាបថខុសគ្នា (ឈ្លើយ ឬសុភាព ចេះគោរពឱនលំទោន ឬមិនចេះគោរពឱនលំទោន)<br>- បង្ហាញអាកប្បកិរិយាផ្សេងៗដែលឆ្លុះបញ្ចាំងតម្លៃខុសៗគ្នារបស់មនុស្សនិងការគោរពពិពិធភាព<br>- អនុវត្តការគោរពចាស់ព្រឹទ្ធាចារ្យតាមលក្ខណៈជាតិនិងអន្តរជាតិ។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់តម្លៃផ្សេងៗ និងការគោរពពិពិធភាព។ | ២ម៉ |
| **មេរៀនទី៣ : កន្លែងទទួលភ្ញៀវ**<br>៣.១- ទិដ្ឋភាពនៃកន្លែងទទួលភ្ញៀវ<br>៣.២- សារៈសំខាន់នៃកន្លែង ទទួលភ្ញៀវ<br>៣.៣- ការរៀបចំកន្លែង ទទួលភ្ញៀវ | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីវិធីរៀបចំកន្លែងទទួលភ្ញៀវ។<br>**បំណិនសម្បទា**<br>- រៀបចំឲ្យមានកន្លែងទទួលភ្ញៀវជាចាំបាច់នៅក្នុងគេហដ្ឋាន។ | ២ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ឱ្យតម្លៃការរៀបចំឱ្យមានកន្លែងទទួលភ្ញៀវ។ | |
| **មេរៀនទី៤ : សោភណភាពនៃកន្លែងទទួលភ្ញៀវ**<br>៤.១- រូបភាពកន្លែងទទួលភ្ញៀវ តាមប្រភេទ គេហដ្ឋាន<br>៤.២- សោភណភាពនៃកន្លែងទទួលភ្ញៀវ<br>- ការមានសណ្ដាប់ធ្នាប់<br>- ការមានអនាម័យ<br>- ការមានគ្រឿងលម្អផ្សេងៗ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសារសំខាន់នៃការធ្វើឱ្យកន្លែងទទួលភ្ញៀវក្នុងគេហដ្ឋានមានសោភណភាព។<br>**បំណិនសម្បទា**<br>- រៀបចំកន្លែងទទួលភ្ញៀវនៅក្នុងគេហដ្ឋានឲ្យមានសោភណភាព។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃសោភណភាពនៃកន្លែងទទួលភ្ញៀវក្នុងគេហដ្ឋាន។ | ២ម៉ |
| **មេរៀនទី៥ : ការទទួលស្គាល់កំហុស**<br>៥.១- មូលហេតុនៃកំហុស<br>៥.២- ការចៀសវាងកំហុស<br>៥.៣- ការទទួលស្គាល់និងកែកំហុស | **វិជ្ជាសម្បទា**<br>- រៀបរាប់មូលហេតុដែលនាំឱ្យកើតមានកំហុសទាំងចេតនាទាំងអចេតនា។<br>**បំណិនសម្បទា**<br>- បង្ហាញវិធី និងសកម្មភាព ក្នុងការចៀសវាងកំហុសដែលកើតមាន។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីសិស្សឱ្យទទួលស្គាល់កំហុស និងចៀសវាងកំហុស។ | ២ម៉ |
| **ជំពូក២ : ភូមិខ្ញុំ** | | |
| **មេរៀនទី១ : កសិករនៅភូមិខ្ញុំ**<br>១.១-រូបភាពផលិតផលកសិកម្ម<br>១.២-អ្វីខ្លះជាការងាររបស់កសិករ ?<br>១.៣-លក្ខណសម្បត្តិចាំបាច់របស់កសិករ:<br>- ចំណេះដឹងផ្នែកបច្ចេកទេសកសិកម្ម<br>- ការតស៊ូព្យាយាមក្នុងការងារ<br>- ចំណេះដឹងផ្នែកហិរញ្ញវត្ថុ<br>១.៤-អត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់កសិករ<br>- កម្រៃពលកម្ម<br>- ចំណូលពីការលក់<br>- ផលិតផល និងការទូទាត់ចំណាយ | **វិជ្ជាសម្បទា**<br>- រៀបរាប់ផលិតផលកសិកម្មដែលមានបង្ហាញក្នុងរូបភាព<br>- រៀបរាប់លក្ខណសម្បត្តិចាំបាច់របស់កសិករ។<br>**បំណិនសម្បទា**<br>- សម្ភាសជាមួយកសិករដែលកំពុងបម្រើការងារកសិកម្មដែលមាននៅក្នុងមូលដ្ឋាន ដែលខ្លួនរស់នៅ។<br>**ចរិយាសម្បទា**<br>- ស្គាល់តម្លៃ និងគោរពកសិករដែលកំពុងប្រកបការងារកសិកម្មណាមួយដោយជោគជ័យ។ | ៣ម៉ |

| | | |
|---|---|---|
| - ការទទួលស្គាល់គុណភាព<br>ផលិតផល | | |
| **មេរៀនទី២ : ការយកចិត្តទុកដាក់**<br>២.១- ការយកចិត្តទុកដាក់<br>២.២- គុណតម្លៃនៃការយកចិត្តទុកដាក់<br>២.៣- ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអត្ថន័យនៃការយកចិត្តទុកដាក់ និងឱ្យឧទាហរណ៍<br>- ប្រាប់បានគុណតម្លៃនៃការយកចិត្តទុកដាក់ចំពោះខ្លួនឯង គ្រួសារ មិត្តភក្តិ សហគមន៍ និង សង្គមជាតិ។<br>**បំណិនសម្បទា**<br>- ឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ចំពោះខ្លួនឯង គ្រួសារ មិត្តភក្តិ សហគមន៍ និងសង្គមជាតិ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃនិងកោតសរសើរដល់បុគ្គលដែលបានផ្តល់ការយកចិត្តទុកដាក់ចំពោះខ្លួនឯង គ្រួសារ មិត្តភក្តិ សហគមន៍ និង សង្គមជាតិ។ | ២ម៉ |
| **មេរៀនទី៣ : ការកេងប្រវញ្ចផ្លូវភេទកុមារ**<br>៣.១- ការកេងប្រវញ្ចផ្លូវភេទកុមារ<br>៣.២- មធ្យោបាយផ្សេងៗក្នុងការកេងប្រវញ្ច<br>៣.៣- ផលអាក្រក់នៃការកេងប្រវញ្ចផ្លូវភេទកុមារ | **វិជ្ជាសម្បទា**<br>- ពណ៌នារូបភាពនិងផលអាក្រក់នៃការកេងប្រវញ្ចផ្លូវភេទកុមារ។<br>**បំណិនសម្បទា**<br>- ឱ្យឧទាហរណ៍ពីរបៀបការពារខ្លួនរបស់កុមារឱ្យចៀសផុតពីការកេងប្រវញ្ចផ្លូវភេទ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នដើម្បីការពារខ្លួនឱ្យចៀសផុតពីអំពើរំលោភបំពានផ្លូវភេទគ្រប់រូបភាព។ | ២ម៉ |
| **មេរៀនទី៤ : ល្បិចកលជនខិលខូច**<br>៤.១- ល្បិចកលជនខិលខូច<br>៤.២- ការសង្កេតលើជនសង្ស័យ<br>៤.៣- ដំណោះស្រាយ | **វិជ្ជាសម្បទា**<br>- ពណ៌នាសញ្ញាណមួយចំនួនដែលជាល្បិចកលបោកប្រាស់របស់ជនខិលខូច។<br>**បំណិនសម្បទា**<br>- បង្ហាញវិធីការពារខ្លួននិងដោះស្រាយបញ្ហាជាមួយជនខិលខូចដើម្បីសុវត្ថិភាពរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- មានការប្រុងប្រយត្នចំពោះល្បិចកលជនខិលខូច។ | ២ម៉ |
| **មេរៀនទី៥ : បងប្រធានថ្នាក់ខ្ញុំ**<br>៥.១-លក្ខណសម្បត្តិ<br>៥.២-សកម្មភាពការងាររបស់ប្រធានថ្នាក់<br>- ក្នុងសាលា | **វិជ្ជាសម្បទា**<br>- រៀបរាប់បានលក្ខណសម្បត្តិរបស់ប្រធានថ្នាក់ក្នុងអត្ថបទមេរៀន។ | ៣ម៉ |

| | | |
|---|---|---|
| - នៅផ្ទះ<br>៥.៣-ការគ្រប់គ្រងប្រាក់កាសផ្ទាល់ខ្លួន<br>- ការរកចំណូល<br>- ការចំណាយ<br>- ការសន្សំ<br>- ការបរិច្ចាគ | **បំណិនសម្បទា**<br>- គ្រាប់តាមលក្ខណសម្បត្តិសមស្របរបស់ប្រធានថ្នាក់ក្នុងមេរៀន ពាក់ព័ន្ធនឹងសកម្មភាពការងារ និងការគ្រប់គ្រងប្រាក់កាស។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃ និងគោរពមនុស្សធំដែលមានកិត្តិនាម។ | |
| **មេរៀនទី៦** : **សុវត្ថិភាពនៅពេលជិះកង់និងម៉ូតូ**<br>៦.១- ឥរិយាបថការពារសុវត្ថិភាពរបស់ថ្មើរជើង<br>៦.២- ផ្លាកសញ្ញាចរាចរណ៍<br>៦.៣- ល្បឿនយានយន្ត<br>៦.៤- សុវត្ថិភាពក្នុងការជិះកង់ ម៉ូតូ | **វិជ្ជាសម្បទា**<br>- រៀបរាប់សុវត្ថិភាពរបស់ថ្មើរជើង សុវត្ថិភាពនៅពេលជិះកង់ ម៉ូតូ ផ្លាកសញ្ញាចរាចរណ៍ ល្បឿនយានយន្ត<br>- ប្រាប់បានពីសុវត្ថិភាពចរាចរណ៍ ជាពិសេសសុវត្ថិភាពថ្មើរជើង និងសុវត្ថិភាពក្នុងការជិះកង់ ម៉ូតូ។<br>**បំណិនសម្បទា**<br>- បង្ហាញការយល់ដឹងពីថ្មើរជើង វិធីជិះកង់ ម៉ូតូឱ្យមានសុវត្ថិភាពនៅតាមដងផ្លូវ<br>- កំណត់មូលហេតុ និងផលអាក្រក់នៃគ្រោះថ្នាក់ចរាចរណ៍។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចក្នុងការធ្វើដំណើរ | ២ម៉ |
| **មេរៀនទី៧** : **ដងចប**<br>៧.១- រូបភាព ដងចប តាមប្រភេទ<br>៧.២- សារៈប្រយោជន៍នៃចប<br>៧.៣- ដងចបធ្វើអំពីអ្វី?<br>៧.៤- របៀបដាក់ដងចប<br>៧.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសម្ភារៈ និងវិធីដាក់ដងចប។<br>**បំណិនសម្បទា**<br>- អនុវត្តវិធីដាក់ដងចប។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការផលិតសម្ភារៈប្រើប្រាស់។ | ២ម៉ |
| **ជំពូកៗ៣ : សហគមន៍** | | |
| **មេរៀនទី១** : **ទីតាំងភូមិសាស្ត្រប្រទេសកម្ពុជា**<br>១.១- ទីតាំង និងព្រំប្រទល់<br>១.២- ផ្លូវទឹក និងទីតាំង រាជធានី/ខេត្ត | **វិជ្ជាសម្បទា**<br>- ពណ៌នាបានពីទីតាំងព្រំប្រទល់ ផ្លូវទឹក និងទីតាំងរាជធានីខេត្ត<br>**បំណិនសម្បទា**<br>- មានសមត្ថភាពអានផែនទីប្រទេសកម្ពុជាដោយកំណត់ព្រំដែន ផ្លូវទឹក និងទីតាំងរាជធានី/ខេត្ត ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្រឡាញ់មាតុភូមិ។ | ៦ម៉ |
| **មេរៀនទី២**: **ចតុមុខ និងវីរភាពខ្មែរ**<br>**សិក្សាបញ្ញត្តិ** : ភស្តុតាង មរតក និរន្តរភាព ឥរិយាបថវិជ្ជមាន | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរាជធានីសំខាន់ៗក្នុងសម័យកាលចតុមុខ តាមរយៈរឿងព្រេង និងភស្តុតាងប្រវត្តិសាស្ត្រ និងបុរាណវិទ្យា<br>- រៀបរាប់ពីវីរភាព និងមនសិការស្នេហាជាតិ | ៦ម៉ |

| | | |
|---|---|---|
| **មាតិកា :**<br>២.១- រាជធានី<br>ក. ទីតាំងភូមិសាស្ត្រ និងគុណសម្បត្តិរាជធានី (ទួលបាសានចតុមុខ)<br>ខ. ប្រវត្តិចតុមុខ<br>គ. ព្រះរាជាស្ថាបនិក<br>ឃ. ប្រវត្តិរាជធានីតាមរយៈរឿងព្រេង<br>**សំណួរត្រិះរិះ** :<br>• តើមានរឿងតំណាលអ្វីខ្លះអំពីរាជធានីចតុមុខ?<br>• តើកន្លែងណាខ្លះដែលធ្លាប់ជារាជធានី ក្នុងសម័យចតុមុខ ហើយមានលក្ខណៈអំណោយផលអ្វីខ្លះ?<br>• តើរាជធានីថ្មីមានគុណសម្បត្តិអ្វីខ្លះ?<br>• តើរាជវាំងចតុមុខស្ថិតនៅឯណា?<br>• តើមានភស្តុតាងអ្វីខ្លះបញ្ជាក់ពីការរស់នៅរបស់មនុស្សក្នុងតំបន់នេះ មុនសម័យចតុមុខ?<br>• តើប្រវត្តិភ្នំដូនពេញមានលក្ខណៈបែបណា?<br>២.២- ព្រះមហាក្សត្រសម័យចតុមុខ<br>ក. ព្រះបាទស្រីរាជា និងស្មារតីបង្រួបបង្រួម<br>ខ. ហ្លួងព្រះស្តេចកន និងការព្យាយាមសាងសមត្ថភាព<br>**សំណួរត្រិះរិះ** :<br>• តើព្រះរាជាស្ថាបនិកនិងព្រះរាជាមួយអង្គៗ មានទឹកព្រះទ័យដូចម្តេចខ្លះចំពោះប្រទេសជាតិ?<br>២.៣- បេតិកភណ្ឌសម័យចតុមុខ<br>**សំណួរត្រិះរិះ** :<br>• តើសម័យចតុមុខបានបន្សល់ទុកនូវសមិទ្ធផលអ្វីខ្លះសម្រាប់មនុស្ស | និងស្នាព្រះហស្ត របស់ព្រះរាជាមួយអង្គៗ<br>- ពណ៌នាពីបេតិកភណ្ឌសម័យចតុមុខ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបគោលការណ៍ដឹកនាំរបស់ព្រះរាជាមួយអង្គៗ។<br>**ចរិយាសម្បទា**<br>- បង្កើតទម្លាប់ដោះស្រាយជម្លោះដោយប្រើគោលការណ៍អហិង្សា។ | |

| | | |
|---|---|---|
| ជំនាន់ក្រោយ?<br>២.៤- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• តើព្រះរាជាមួយអង្គៗមានគុណសម្បត្តិជាអ្នកដឹកនាំបម្រើប្រយោជន៍រាស្ត្រទូទៅអ្វីខ្លះ និងដោះស្រាយបញ្ហាប្រទេសជាតិតាមវិធីអ្វីខ្លះ? | | |
| **មេរៀនទី៣** : **លង្វែក និង រាជធានីពិសិដ្ឋ**<br>**សិក្សាបញ្ញត្តិ** : មនុស្សសំខាន់, រាជធានី, ស្នាដៃ, បញ្ញវន្ត<br>**មាតិកា ៖**<br>៣.១- ការជ្រើសរើសរាជធានី<br>ក. ទីតាំងភូមិសាស្ត្រ<br>ខ. ព្រះរាជាស្ថាបនិក<br>គ. មូលហេតុនៃការផ្លាស់ប្ដូររាជធានី<br>• កត្តាភូមិសាស្ត្រ និងជំនឿ<br>• កត្តាភូមិសាស្ត្រ និងពាណិជ្ជកម្ម<br>• លង្វែកមុនក្លាយជារាជធានី<br>**សំណួរត្រិះរិះ** :<br>• តើរាជធានីលង្វែកស្ថិតនៅឯណា? ហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរជ្រើសរើសទីនេះជារាជធានី?<br>• តើមានភស្តុតាងអ្វីខ្លះស្ដីពីការរស់នៅរបស់មនុស្សក្នុងតំបន់នេះមុនសម័យលង្វែក?<br>៣.២- ការរៀបចំរាជធានី<br>ក. វប្បធម៌ និងជំនឿ<br>ខ. យុទ្ធសាស្ត្រ និងស្ថាបត្យកម្ម<br>**សំណួរត្រិះរិះ** :<br>• តើព្រះមហាក្សត្រខ្មែរមានយុទ្ធសាស្ត្របែបណាក្នុងការរៀបចំរាជធានីលង្វែកឱ្យមាន | **វិជ្ជាសម្បទា**<br>- ពន្យល់ពីវីរភាព និងមនសិការស្នេហាជាតិ និងស្នាព្រះហស្ដរបស់ព្រះរាជាមួយអង្គៗ និងការចូលរួមរបស់បញ្ញវន្តក្នុងការអភិវឌ្ឍជាតិ។<br>**បំណិនសម្បទា**<br>- កត់សម្គាល់ពីទីកន្លែងសំខាន់ៗ និងលក្ខណៈពិសេសរបស់រាជធានីដោយប្រើភស្តុតាងប្រវត្តិសាស្ត្រ និងភស្តុតាងបុរាណវិទ្យា។<br>- វិភាគសារៈសំខាន់នៃការរៀបចំរាជធានីនិងព្រះបរមរាជវាំង និងការរក្សាវឌ្ឍនភាពប្រទេស<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីការគិត វាចា ទម្លាប់ និងការប្រព្រឹត្តរបស់ថ្នាក់ដឹកនាំក្នុងការរក្សាវឌ្ឍនភាពប្រទេស និងថែរក្សាមរតកប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្សជាតិ។ | ៦ម៉ |

| | | |
|---|---|---|
| លក្ខណៈកាន់តែពិសេស?<br>៣.៣- វីរភាពមហាក្សត្រខ្មែរ និង បុព្វបុរស<br>ក. ចន្ទរាជា និងភាពកតញ្ញូ<br>ខ. បរមិន្ទរាជា និងការប្ដេជ្ញាចិត្ត<br>គ. សត្ថាទី១ និងខ្វះការលះបង់<br>ឃ. បញ្ញាវន្ត និងការចូលរួមកសាងជាតិ<br>ង. មរតកវប្បធម៌-ប្រវត្តិសាស្ត្រសម័យលង្វែក<br>**សំណួរត្រិះរិះ** :<br>• តើលក្ខណៈសម្បត្តិ ការចូលរួម និងសម្រេចចិត្តរបស់ព្រះមហាក្សត្រខ្មែរចូលរួមក្នុងការអភិវឌ្ឍ ឬឱនភាពរដ្ឋយ៉ាងដូចម្ដេចខ្លះ?<br>• តើព្រះមហាក្សត្រសម័យលង្វែកបានបន្សល់មរតកល្អអ្វីខ្លះដល់មនុស្សជំនាន់ក្រោយ?<br>• តើបញ្ញាវន្តមានតួនាទីយ៉ាងដូចម្ដេចខ្លះក្នុងការអភិវឌ្ឍជាតិ? | | |
| **មេរៀនទី៤** : **កិច្ចសហការ**<br>៤.១- កិច្ចសហការ<br>៤.២- សារប្រយោជន៍នៃកិច្ចសហការ<br>៤.៣- ការចូលរួមដោះស្រាយបញ្ហា | **វិជ្ជាសម្បទា**<br>- ពណ៌នាអត្ថន័យនៃកិច្ចសហការ និងការធ្វើការងារជាក្រុម<br>- រៀបរាប់សារៈសំខាន់នៃកិច្ចសហការ និងការដោះស្រាយបញ្ហាដែលកើតមានចំពោះកិច្ចសហការ។<br>**បំណិនសម្បទា**<br>- កំណត់បានគុណសម្បត្តិនៃកិច្ចសហការនិងការដោះស្រាយបញ្ហាដែលកើតមានដោយសន្តិវិធី<br>- អនុវត្តការងារជាក្រុម និងបង្ហាញសកម្មភាពណាដែលតម្រូវឱ្យមានកិច្ចសហការ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្រឡាញ់ក្រុម ចូលរួមក្នុងកិច្ចសហការការងារជាក្រុម។ | ២ម៉ |
| **មេរៀនទី៥** : **កោះ និងជីវភាពរស់នៅ**<br>៥.១- ស្ទើរកោះ<br>- លក្ខណៈទូទៅ | **វិជ្ជាសម្បទា**<br>- រៀបរាប់ និងបង្ហាញឱ្យឃើញថា អ្វីដែលជា ស្ទើរកោះ  កោះប្រជុំកោះ និងកម្រងកោះ។ | ៦ម៉ |

| | | |
|---|---|---|
| - ការកកើតស្ទើកោះ<br>- ជីវភាពរស់នៅ<br>៥.២- កោះ<br>- លក្ខណៈទូទៅ<br>- ការកកើត<br>- ជីវភាពរស់<br>៥.៣- ប្រជុំកោះ និងកម្រងកោះ | **បំណិនសម្បទា**<br>- បង្ហាញពីភាពខុសគ្នារវាងលក្ខណៈទូទៅនិងជីវភាពរស់នៅរបស់អ្នកនៅតំបន់ទាំងនេះ។<br>**ចរិយាសម្បទា**<br>- មានគំនិតក្នុងការការពារធនធានធម្មជាតិទាំងនេះឱ្យបានគង់វង្ស ។ | |
| **មេរៀនទី៦** : **ជំនឿសាសនា**<br>៦.១- សាសនាព្រះពុទ្ធ<br>៦.២- សាសនាគ្រិស្ត<br>៦.៣- សាសនាអ៊ិស្លាម | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនិយមន័យ "សាសនា"<br>- ប្រាប់បានពីប្រវត្តិព្រះពុទ្ធសាសនា គ្រិស្តសាសនា និងអ៊ិស្លាមសាសនា។<br>**បំណិនសម្បទា**<br>- បង្ហាញការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា គ្រិស្តសាសនានិងអ៊ិស្លាមសាសនា។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីរួមរស់ជាមួយគ្នាដោយភាពសុខសន្តិភាពមិនមានការរើសអើងសាសនា។ | ២ម៉ |
| **មេរៀនទី៧** : **សង់ខ្យាល្ពៅ**<br>៧.១- រូបភាព<br>៧.២- គ្រឿងផ្សំ<br>៧.៣- របៀបធ្វើ<br>៧.៤- គណនានិងប្រៀបធៀបថ្លៃដើម និងថ្លៃ លក់លើទីផ្សារ | **វិជ្ជាសម្បទា**<br>- រៀបរាប់គ្រឿងផ្សំនិងវិធីធ្វើសង់ខ្យាល្ពៅ<br>- ប្រៀបធៀបតម្លៃផលិតផលដែលលក់នៅទីផ្សារ និងតម្លៃផលិតផលដែលផលិតដោយខ្លួនឯង។<br>**បំណិនសម្បទា**<br>- អនុវត្តការធ្វើសង់ខ្យាល្ពៅនៅសាលារៀន និងគណនានិងប្រៀបធៀបថ្លៃដើម និងថ្លៃលក់លើទីផ្សារ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើម្ហូបចំណីដោយខ្លួនឯង។ | ២ម៉ |
| **ជំពូក៤ : ស្រុកខ្ញុំ** | | |
| **មេរៀនទី១** : **ដីនៅប្រទេសកម្ពុជា**<br>១.១- លក្ខណៈទូទៅនៃដី<br>- ដីជ្រាបទឹក និងដីមិនជ្រាបទឹក<br>- ដីមានជីជាតិ និងដីគ្មានជីជាតិ<br>១.២- ដីតាមតំបន់នានា<br>- ដីតំបន់បឹងទន្លេសាប<br>- ដីតំបន់វាលរាប<br>- ដីតំបន់ខ្ពង់រាប និងភ្នំ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីលក្ខណៈទូទៅនៃដីនៅក្នុងប្រទេសកម្ពុជា។<br>**បំណិនសម្បទា**<br>- កំណត់បានពីប្រភេទដីតាមតំបន់នានា។<br>**ចរិយាសម្បទា**<br>- មានគំនិតស្រឡាញ់ការពារនិងថែរក្សាធនធាន ធម្មជាតិក្នុងប្រទេស។ | ៧ម៉ |

| | | |
|---|---|---|
| - ដីតំបន់មាត់សមុទ្រ | | |
| **មេរៀនទី២** : **ឧដុង្គ និងការ ចាត់ចែងរៀបចំ**<br>**សិក្សាបញ្ញត្តិ** : មនុស្សសំខាន់ៗ រាជធានី ទីកន្លែងប្រវត្តិសាស្ត្រ ការអប់រំ ច្បាប់ ការដឹកនាំ<br>**មាតិកា** :<br>២.១- វិសាលភាពទឹកដី<br>**សំណួរគន្លឹះ** :<br>• តើវិសាលភាពទឹកដីនៃនគរខ្មែរ មានការប្រែប្រួលយ៉ាងដូចម្តេចខ្លះ? មានភស្តុតាងអ្វីខ្លះ?<br>២.២- រាជធានី<br>ក. ទីតាំងភូមិសាស្ត្រ<br>ខ. ព្រះរាជាស្ថាបនិក<br>គ. មូលហេតុនៃការផ្លាស់ប្តូររាជធានី<br>ឃ. ប្រវត្តិសាស្ត្រក្រុងឧដុង្គ<br>• ភូមិសាស្ត្រ<br>• ពាណិជ្ជកម្ម<br>• ជំនឿ និងស្ទូលរាជធានី<br>**សំណួរគន្លឹះ** :<br>• សម័យឧដុង្គ បានបង្កើតរាជធានីនៅកន្លែងណាខ្លះ? ឈ្មោះអ្វីខ្លះ?<br>• តើសម័យឧដុង្គបន្សល់ទុក ទីកន្លែងនិងភស្តុតាង ប្រវត្តិសាស្ត្រនៅកន្លែងណាខ្លះ?<br>• តើសមិទ្ធផលលើភ្នំឧដុង្គមានអ្វីខ្លះ មានគោលបំណងអ្វី និងបានផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ?<br>• តើមានភស្តុតាងអ្វីខ្លះបង្ហាញអំពីការរស់នៅរបស់មនុស្សក្នុងតំបន់ឧដុង្គ មុនសម័យឧដុង្គ?<br>• ហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរ បានផ្លាស់ចេញពីរាជវាំងលង្វែក មកកាន់ឧដុង្គ? | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីវិសាលភាពនៃនគរខ្មែរដោយផ្អែកលើភស្តុតាង<br>- ប្រាប់អំពីទីកន្លែងប្រវត្តិសាស្ត្រ និងរាជធានីក្នុងសម័យឧដុង្គដោយប្រើភស្តុតាង<br>- រៀបរាប់ពីវីរភាពរបស់ព្រះរាជាក្នុងការរក្សាអត្តសញ្ញាណជាតិ។<br>**បំណិនសម្បទា**<br>- ភ្ជាប់ទីកន្លែង និងភស្តុតាងប្រវត្តិសាស្ត្រសម្រាប់បម្រើប្រយោជន៍សេដ្ឋកិច្ចបច្ចុប្បន្ន។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីការគិត វាចា និងការប្រព្រឹត្តវិជ្ជមានរបស់ព្រះរាជាក្នុងសម័យឧដុង្គ។ | ៧ម៉ |

| | | |
|---|---|---|
| ២.៣- វីរភាពព្រះមហាក្សត្រសម័យឧដុង្គ<br>ក. ព្រះបាទជ័យជេដ្ឋាទី៣ អង្គសូរ<br>ខ. ព្រះបាទនារាយណ៍រាជាអង្គតន់<br>គ. ព្រះបាទអង្គដួង និងការស្ដាបនាជាតិ<br>**សំណួរត្រិះរិះ** :<br>• តើវីរភាពរបស់ព្រះមហាក្សត្រខ្មែរក្នុងសម័យឧដុង្គក្នុងការរក្សាអត្តសញ្ញាណជាតិមានអ្វីខ្លះ?<br>២.៤- វប្បធម៌ចែករំលែក និងសាមគ្គីភាព<br>**សំណួរត្រិះរិះ** :<br>• តើវិបត្តិរាជវង្សខ្មែរ និងដំណោះស្រាយដែលព្រះរាជាសម័យឧដុង្គបានប្រើមានអ្វីខ្លះ និងផ្ដល់ឥទ្ធិពលអ្វីខ្លះដល់មនុស្សជំនាន់ក្រោយ?<br>២.៥- ឧដុង្គ និងមរតក<br>**សំណួរត្រិះរិះ** :<br>• តើមរតកប្រវត្តិសាស្ត្របន្សល់ទុកពីសម័យឧដុង្គ ផ្ដល់ប្រយោជន៍អ្វីខ្លះដល់បច្ចុប្បន្ន?<br>• តើមនុស្សជំនាន់ក្រោយត្រូវបណ្ដុះទម្លាប់អ្វីខ្លះដើម្បីប្រើប្រាស់មរតកប្រវត្តិសាស្ត្រអភិវឌ្ឍប្រទេស?<br>២.៦- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• តើប្រជារាស្ត្រ និងប្រទេសជាតិទទួលបានផលប្រយោជន៍អ្វីខ្លះ នៅពេលព្រះរាជាប្រកាន់ព្រះទ័យ វិជ្ជមាន ទូលាយ និងចែករំលែកអំណាច?<br>• តើប្រជារាស្ត្រ និងប្រទេសជាតិ | | |

| | | |
|---|---|---|
| ទទួលបានផលប្រយោជន៍អ្វីខ្លះ នៅពេលព្រះរាជាយកព្រះទ័យ ទុកដាក់ចំពោះការអនុវត្តច្បាប់ និងការអប់រំ ជាអាទិភាព? | | |
| **មេរៀនទី៣ : អាណាព្យាបាលបារាំង និងវរជនខ្មែរ**<br>**សិក្សាបញ្ញត្តិ :** វិសាលភាពទឹកដី មនុស្សសំខាន់ នគរូបនីយកម្ម សិទ្ធិអំណាច អធិបតេយ្យភាព<br>**មាតិកា :**<br>៣.១- វិសាលភាពទឹកដី<br>**សំណួរត្រិះរិះ :**<br>• តើវិសាលភាពទឹកដីខ្មែរមានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះក្នុងអំឡុងសម័យអាណាព្យាបាលបារាំង?<br>៣.២- ការវិលត្រឡប់មកភ្នំពេញវិញ<br>**សំណួរត្រិះរិះ :**<br>• ហេតុអ្វីបានជាភ្នំពេញត្រូវបានជ្រើសរើសជារាជធានីឡើងវិញ?<br>៣.៣- រាជធានីភ្នំពេញ និងនគរូបនីយកម្ម<br>**សំណួរត្រិះរិះ :**<br>• តើមានការរៀបចំផែនការ និងអភិវឌ្ឍន៍រាជធានីភ្នំពេញយ៉ាងដូចម្តេចខ្លះក្នុងសម័យអាណាព្យាបាលបារាំង?<br><br>៣.៤- បុគ្គលសំខាន់ៗ<br>ក. ព្រះបាទនរោត្តម និងអធិបតេយ្យផ្ទៃក្នុង<br>ខ. ព្រះបាទស៊ីសុវត្ថិ និងកំណែទម្រង់<br>គ. ព្រះបាទ នរោត្តម សីហនុ និងទេពកោសល្យ<br>ឃ. បញ្ញវន្ត និងការរក្សាអត្តសញ្ញាណ ខ្មែរ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការប្រែប្រួលនៃវិសាលភាពទឹកដីខ្មែរមុន និងក្រោយពេលបារាំងដាក់អាណាព្យាបាលលើកម្ពុជា<br>- ប្រាប់ពីមូលហេតុនៃការផ្លាស់ប្តូររាជធានីពីឧដុង្គមកភ្នំពេញ<br>- ពណ៌នាពីនគរូបនីយកម្មនៃរាជធានីភ្នំពេញក្នុងសម័យអាណាព្យាបាលបារាំង<br>- បង្ហាញពីព្រះរាជា ថ្នាក់ដឹកនាំ និងឥស្សរជនខ្មែរសំខាន់ៗដែលចូលរួមអភិរក្សអត្តសញ្ញាណខ្មែរក្នុងសម័យអាណា-ព្យាបាលបារាំង។<br>**បំណិនសម្បទា**<br>- វិភាគពីតួនាទីរ៉េស៊ីដង់ជាន់ខ្ពស់បារាំងក្នុងការគ្រប់គ្រងនៅកម្ពុជា។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីតម្លៃនៃបញ្ញវន្តភាពក្នុងការអភិរក្សអត្តសញ្ញាណជាតិ។ | ៦ម៉ |

| | | |
|---|---|---|
| • ក្រមង៉ុយ និងទំនៀមខ្មែរ<br>• សម្ដេចសង្ឃរាជ ជួន ណាត និងសកវាជថ្មីនៃភាសាខ្មែរ<br>**សំណួរត្រិះរិះ** :<br>• ហេតុអ្វីបានជាព្រះបាទ នរោត្តម ដាក់កម្ពុជាឱ្យស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង?<br>• តើព្រះបាទស៊ីសុវត្ថិបានបន្សល់ទុកនូវស្នាព្រះហស្តអ្វីខ្លះ?<br>• តើព្រះបាទ នរោត្តម សីហនុ មានទេពកោសល្យ និងវីរភាពអ្វីខ្លះក្នុងការរក្សា និងការពារប្រយោជន៍ជាតិ?<br>• តើបញ្ញវន្តខ្មែរបានចូលរួមយ៉ាងដូចម្ដេចខ្លះក្នុងការអភិរក្សអត្តសញ្ញាណខ្មែរ?<br>៣.៥- រ៉េស៊ីដង់ជាន់ខ្ពស់ និងរដ្ឋការបារាំង<br>**សំណួរត្រិះរិះ** :<br>• តើរ៉េស៊ីដង់ជាន់ខ្ពស់មានតួនាទីអ្វីខ្លះក្នុងការគ្រប់គ្រងកម្ពុជា?<br>៣.៦- បញ្ញវន្ត និងអត្តសញ្ញាណជាតិ<br>**សំណួរត្រិះរិះ** :<br>• ចូរសរសេរអត្ថបទខ្លីស្ដីពីបញ្ញវន្តផ្សេងទៀតដែល បានចូលរួមអភិរក្សអត្តសញ្ញាណជាតិ | | |
| **មេរៀនទី៤** : **ពិធីបុណ្យប្រពៃណីជាតិ**<br>៤.១- បុណ្យចូលឆ្នាំ<br>៤.២- បុណ្យភ្ជុំបិណ្ឌ<br>៤.៣- បុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ | **វិជ្ជាសម្បទា**<br>- ប្រាប់បានកាលបរិច្ឆេទ សារៈសំខាន់ និងអត្ថន័យសំខាន់ៗ នៃពិធីបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ។<br>**បំណិនសម្បទា**<br>- បង្ហាញរបៀបរៀបចំពិធីបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីយកចិត្តទុកដាក់ថែរក្សា និងចូលរួមក្នុងពិធីបុណ្យប្រពៃណីជាតិ។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : តម្លៃកេរមតកជាតិ**<br>៥.១- តម្លៃប្រាសាទអង្គរវត្ត<br>៥.២- ផលប្រយោជន៍នៃបេតិកភណ្ឌជាតិ (ចំពោះសេដ្ឋកិច្ចជាតិ)<br>៥.៣- ការថែរក្សាបេតិកភណ្ឌជាតិ | **វិជ្ជាសម្បទា**<br>- រៀបរាប់តម្លៃស្នាដៃបុព្វបុរសក្នុងការកសាងសម្បត្តិវប្បធម៌ជាតិ<br>- ប្រាប់បានផលប្រយោជន៍ក្នុងការថែរក្សាបេតិកភណ្ឌជាតិ<br>- ពណ៌នាផលប្រយោជន៍ដែលបានមកពីបេតិកភណ្ឌជាតិសម្រាប់ខ្លួននិងគ្រួសារ(ធ្វើជាមគ្គុទេសន៍ទេសចរណ៍)។<br>**បំណិនសម្បទា**<br>- បង្ហាញសកម្មភាពនៃការចូលរួមថែរក្សាបេតិកភណ្ឌជាតិ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់និងចូលរួមថែរក្សាសម្បត្តិបេតិកភណ្ឌជាតិ។ | ៣ម៉ |
| **មេរៀនទី៦ : ផ្កាម្លិះ**<br>៦.១- រូបភាពផ្កាម្លិះនៅលើដើម<br>៦.២- រូបលក្ខណៈ នៃផ្កាម្លិះ<br>៦.៣- សារប្រយោជន៍នៃផ្កាម្លិះ<br>៦.៤- របៀបដាំផ្កាម្លិះ<br>៦.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីវិធីដាំផ្កាម្លិះក្នុងផើង។<br>**បំណិនសម្បទា**<br>- អនុវត្តរបៀបដាំផ្កាម្លិះ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដាំប្រភេទផ្កាម្លិះ ដើម្បីបង្កើតស្នាដៃ។ | ៣ម៉ |
| **ជំពូក៥ : សន្តមជាតិ** | | |
| **មេរៀនទី១ : គុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន**<br>១.១- និយមន័យគ្រឿងញៀន<br>១.២- ប្រភេទគ្រឿងញៀន<br>១.៣- គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>១.៤- វិធានការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន | **វិជ្ជាសម្បទា**<br>- ប្រាប់បានអំពីនិយមន័យគ្រឿងញៀន<br>- រៀបរាប់ប្រភេទផ្សេងៗនៃគ្រឿងញៀន<br>- ពន្យល់ពីទង្វើដែលនាំឱ្យមានគ្រោះថ្នាក់ដោយសារការប្រើប្រាស់គ្រឿងញៀន។<br>**បំណិនសម្បទា**<br>- បង្ហាញផលវិបាកធ្ងន់ធ្ងរនៃការប្រើប្រាស់គ្រឿងញៀន<br>- ឱ្យឧទាហរណ៍អំពីរបៀបឆ្លើយបដិសេធនឹងការបបួលរបស់អ្នកដទៃក្នុងការប្រើប្រាស់គ្រឿងញៀន។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នការពារខ្លួន ចៀសឱ្យឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន។ | ៣ម៉ |
| **មេរៀនទី២ : អំពីឆ្នេរសមុទ្រ**<br>២.១- ឆ្នេរសមុទ្រ<br>- ឆ្នេររាប(ឆ្នេរទាប)<br>- ឆ្នេរចោត<br>២.២- ជ្រោយ ឆក ឈូង<br>- ជ្រោយ និងសារៈប្រយោជន៍<br>- ឆក | **វិជ្ជាសម្បទា**<br>- រៀបរាប់ និងបង្ហាញបានថា អ្វីដែលជា ឆ្នេរសមុទ្រ ឆ្នេររាប ឆ្នេរចោត ជ្រោយ ឆក ឈូង។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យឃើញពីភាពខុសគ្នារវាង ជ្រោយ ឆក ឈូងថា និងបញ្ជាក់បានពីសារៈប្រយោជន៍របស់វា ។ | ៦ម៉ |

| | | |
|---|---|---|
| - ឈូង | **ចរិយាសម្បទា**<br>- ស្គាល់ពីគុណតម្លៃ និងមានគំនិតក្នុងការ ការពារធនធានធម្មជាតិទាំងនេះ។ | |
| **មេរៀនទី៣ : ការចែករំលែក**<br>៣.១- ការចែករំលែកសម្ភារៈនិងទ្រព្យធន<br>៣.២- ការចែករំលែកចំណេះដឹង និងបទពិសោធ<br>៣.៣- បុគ្គលគួរកោតសរសើរ (ឧទាហរណ៍: លោក ប៊ីត រិចន័រ Beat Richner) | **វិជ្ជាសម្បទា**<br>- ពន្យល់បានអ្វីជាការចែករំលែក និងប្រភេទនៃការចែករំលែក ដូចជា ចែករំលែកសម្ភារៈ ទ្រព្យធន និងបទពិសោធ<br>- ប្រាប់បានអំពីសកម្មភាពជនគំរូក្នុងការចែករំលែក។<br>**បំណិនសម្បទា**<br>- បង្ហាញសារប្រយោជន៍នៃការផ្ដល់តម្លៃ និងកោតសរសើរចំពោះការចែករំលែកសម្ភារៈ ទ្រព្យធន និងបទពិសោធ<br>- ឱ្យឧទាហរណ៍ជាក់ស្ដែងអំពីជនគំរូក្នុងការចែករំលែក។<br>**ចរិយាសម្បទា**<br>- លះបង់គំនិតលោភលន់ និងបណ្ដុះឆន្ទៈសិស្សឱ្យចេះចែករំលែក<br>- ចូលរួមលើកកម្ពស់វប្បធម៌ចែករំលែក។ | ២ម៉ |
| **មេរៀនទី៤ : ថ្នេរឆិត**<br>៤.១- រូបភាព ថ្នេរឆិត<br>៤.២- រូបលក្ខណៈនៃ"ថ្នេរឆិត"<br>៤.៣- សារប្រយោជន៍នៃថ្នេរឆិត<br>៤.៤- របៀបដេរថ្នេរឆិត<br>៤.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រាប់ឈ្មោះសម្ភារៈមួយចំនួនដែលត្រូវមកប្រើប្រាស់ក្នុងការដេរថ្នេរឆិត។<br>**បំណិនសម្បទា**<br>- ចេះពីរបៀបកាន់ម្ជុលដេរ និងប្រើប្រាស់ថ្នេរឆិត។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ក្នុងការបត់ជាយកន្សែងនិងដេរថ្នេរឆិត។ | ៣ម៉ |
| **មេរៀនទី៥ : ថ្នេរកន្ទុយកណ្ដុរ**<br>៥.១- រូបភាព ថ្នេរកន្ទុយកណ្ដុរ<br>៥.២- រូបលក្ខណៈនៃ"ថ្នេរកន្ទុយកណ្ដុរ"<br>៥.៣- សារប្រយោជន៍នៃថ្នេរកន្ទុយកណ្ដុរ<br>៥.៤-របៀបដេរថ្នេរកន្ទុយកណ្ដុរ<br>៥.៥-កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីវិធីដេរថ្នេរកន្ទុយកណ្ដុរលើកំណាត់ស្រោមខ្នើយ។<br>**បំណិនសម្បទា**<br>- អនុវត្តការដេរថ្នេរកន្ទុយកណ្ដុរលើកំណាត់ស្រោមខ្នើយ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដេរថ្នេរកន្ទុយកណ្ដុរដើម្បីលម្អលើកំណាត់ប្រើប្រាស់ផ្សេងៗ។ | ៣ម៉ |

## ៧.៦- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៦ (១០៥ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១ : គ្រួសារខ្ញុំ** | | |
| **មេរៀនទី១ : ឥរិយាបថល្អនៅទីសាធារណៈ**<br>១.១- ឥរិយាបថតាមដណ្តើរ<br>១.២- ឥរិយាបថក្នុងវត្ត<br>១.៣- ឥរិយាបថតាមទីសាធារណៈ<br>១.៤- ឥរិយាបថក្នុងរថយន្តឈ្នួល និងចំណតរថយន្តឈ្នួល<br>១.៥- ការខាកស្តោះនិងកណ្តាស់ | **វិជ្ជាសម្បទា**<br>- ប្រាប់បានសុជីវធម៌របស់មនុស្សម្នាក់ៗ៖<br>- នៅតាមដណ្តើរ<br>- ក្នុងវត្តអារាម<br>- តាមទីសាធារណៈ<br>- ក្នុងរថយន្តឈ្នួល និងចំណតរថយន្តឈ្នួល<br>- ក្នុងការខាកស្តោះឬកណ្តាស់។<br>**បំណិនសម្បទា**<br>- អនុវត្តឥរិយាបថល្អរបស់ខ្លួននៅគ្រប់ទីកន្លែង។<br>- បង្ហាញការខាកស្តោះឬកណ្តាស់ប្រកបដោយឥរិយាបថសមរម្យ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់សុជីវធម៌ក្នុងការរស់នៅ ក្នុងគ្រួសារ សាលារៀន និងក្នុងសង្គម។ | ៣ម៉ |
| **មេរៀនទី២ : កន្លែងចម្អិនអាហារ**<br>២.១- រូបភាពកន្លែងចម្អិនអាហារតាមប្រភេទគេហដ្ឋាន<br>២.២- កន្លែងចម្អិនអាហារជាអ្វី?<br>២.៣- សារៈសំខាន់នៃកន្លែង ចម្អិនអាហារ<br>២.៤- ការរៀបចំកន្លែងចម្អិនអាហារ<br>២.៥- ទីកន្លែងចាំបាច់ដទៃទៀត | **វិជ្ជាសម្បទា**<br>- ពន្យល់អំពីសារៈសំខាន់នៃកន្លែងចម្អិនអាហារ។<br>**បំណិនសម្បទា**<br>- រៀបចំឲ្យមានទីកន្លែងចម្អិនអាហារដាច់ដោយឡែក និងប្រកបដោយសោភ័ណភាពនៅក្នុងគេហដ្ឋាន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការរៀបចំឱ្យមានកន្លែងចាំបាច់នានាដាច់ដោយឡែកក្នុងគេហដ្ឋាន។ | ២ម៉ |
| **មេរៀនទី៣ : កន្លែងទទួលទានអាហារ**<br>៣.១- រូបភាពកន្លែងទទួលទានអាហារតាមប្រភេទគេហដ្ឋាន<br>៣.២- កន្លែងទទួលទានអាហារជាអ្វី?<br>៣.៣- សារៈសំខាន់នៃកន្លែង ទទួលទានអាហារ<br>៣.៤- ការរៀបចំកន្លែងទទួលទានអាហារ<br>៣.៥- ទីកន្លែងចាំបាច់ដទៃទៀត | **វិជ្ជាសម្បទា**<br>- ពន្យល់អំពីសារៈសំខាន់នៃកន្លែងទទួលទានអាហារ។<br>**បំណិនសម្បទា**<br>- រៀបចំឲ្យមានទីកន្លែងទទួលទានអាហារដាច់ដោយឡែក និងប្រកបដោយសោភ័ណភាពនៅក្នុងគេហដ្ឋាន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការរៀបចំឱ្យមានកន្លែងចាំបាច់នានា ដាច់ដោយឡែកក្នុងគេហដ្ឋាន។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤ : កន្លែងទុកទឹក**<br>៤.១- រូបភាពបន្ទប់ទឹក<br>តាមប្រភេទគេហដ្ឋាន<br>៤.២- បន្ទប់ទឹកជាអ្វី?<br>៤.៣- សារៈសំខាន់នៃបន្ទប់ទឹក<br>៤.៤- ការរៀបចំបន្ទប់ទឹក<br>៤.៥- ទីកន្លែងចាំបាច់ដទៃទៀត | **វិជ្ជាសម្បទា**<br>- ពន្យល់អំពីសារៈសំខាន់នៃបន្ទប់ទឹក។<br>**បំណិនសម្បទា**<br>- រៀបចំឲ្យមានបន្ទប់ទឹកដោយឡែក និងប្រកប<br>ដោយសោភ័ណភាពនៅក្នុងគេហដ្ឋាន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការរៀបចំឱ្យមានកន្លែងចាំបាច់នានា ដាច់ដោយ<br>- ឡែកក្នុងគេហដ្ឋាន។ | ២ម៉ |
| **ជំពូក២ : ភូមិខ្ញុំ** | | |
| **មេរៀនទី១ : ការជួញដូរកុមារ**<br>១.១- និយមន័យនៃការរត់ពន្ធ<br>មនុស្ស ការជួញដូរកុមារ<br>១.២- ឈ្មួញនិងវិធីគ្រប់គ្រងកុមារ<br>១.៣- មូលហេតុដែលនាំឱ្យមានការ<br>ជួញដូរកុមារ<br>១.៤- ការជួញដូរកុមារតាមបណ្តាញ<br>ព័ត៌មានសង្គម និងអិនធឺណិត | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យអំពីការជួញដូរមនុស្ស ការជួញដូរកុមារ<br>- ប្រាប់បានមូលហេតុ និងវិធីនៃការជួញដូរកុមារ។<br>**បំណិនសម្បទា**<br>- បង្ហាញមូលហេតុផ្សេងៗដែលបណ្តាលឱ្យមានការជួញដូរ<br>- មនុស្ស និងការជួញដូរកុមារ<br>- ចូលរួមសម្តែងតួអំពីរបៀបការពារខ្លួនឱ្យចៀសផុតពីការជួញ<br>ដូរមនុស្ស និងកុមារ។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រឆាំងនឹងអំពើជួញដូរមនុស្សនិងកុមារ<br>និងចូលរួមទប់ស្កាត់អំពើជួញដូរមនុស្សនិងកុមារ។ | ៣ម៉ |
| **មេរៀនទី២ : ស្ថាប័នផ្សេងៗ<br>ក្នុងភូមិខ្ញុំ**<br>២.១- និយមន័យ "ស្ថាប័ន"<br>២.២- ស្ថាប័នរដ្ឋ<br>ក- សាលាឃុំ/សង្កាត់<br>ខ- សាលារៀន<br>គ- មន្ទីរពេទ្យ<br>ឃ- វត្តអារាម<br>២.៣- ស្ថាប័នឯកជនគ្រឹះស្ថានឯកជន<br>ផ្សេងៗ (ក្នុងនោះ មានគ្រឹះស្ថាន<br>ហិរញ្ញវត្ថុ) | **វិជ្ជាសម្បទា**<br>- ប្រាប់និយមន័យ "ស្ថាប័ន" ។<br>**បំណិនសម្បទា**<br>- សម្គាល់បាន និងអធិប្បាយតួនាទីនៃស្ថាប័ននីមួយៗ ដែល<br>មាននៅក្នុងភូមិដែលសិស្សម្នាក់ៗរស់នៅ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃ និងគោរពតួនាទីនៃស្ថាប័ននីមួយៗ ដែលមាននៅ<br>ក្នុងភូមិ។ | ១ម៉ |
| **មេរៀនទី៣ : អាជីវករលក់ដូរ<br>នៅភូមិខ្ញុំ**<br>៣.១- រូបភាពកន្លែងលក់ដូរទំនិញ ចំណី<br>អាហារ បន្លែបង្កា ត្រីសាច់ | **វិជ្ជាសម្បទា**<br>- រៀបរាប់ប្រភេទនៃទំនិញដែលមានលក់ដូរ នៅក្នុងភូមិខ្ញុំ<br>តាមអត្ថបទមេរៀន។ | ២ម៉ |

| | | |
|---|---|---|
| ៣.២- ការលក់ដូរជាអ្វី ?<br>៣.៣- លក្ខណសម្បត្តិទូទៅរបស់អាជីវករលក់ដូរ<br>- មានភាពសកម្មការងារ<br>- មានភាពរួសរាយរាក់ទាក់<br>- លក់តាមតម្លៃសមរម្យ<br>- គោរពផលប្រយោជន៍របស់អតិថិជន<br>៣.៤- ជោគជ័យរបស់អាជីវករលក់ដូរ<br>- ទំនិញលក់ដាច់ច្រើន<br>- ទទួលការគាំទ្រពីអតិថិជន<br>- មានផលចំណេញ | **បំណិនសម្បទា**<br>- សម្គាល់បាន និងអធិប្បាយលក្ខណសម្បត្តិរបស់អាជីវករលក់ដូរនៅភូមិខ្ញុំ តាមអត្ថបទមេរៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃ គោរពផលប្រយោជន៍ និងសុខុមាលភាពអាជីវករ និងរបស់អតិថិជន។ | |
| **មេរៀនទី៤ : ពូសំអ្នកចាំចំការនៅភូមិខ្ញុំ**<br>៤.១-លក្ខណសម្បត្តិរបស់ពូសំ<br>៤.២-កិច្ចការរបស់ពូសំ<br>៤.៣-ថវិកាចំណូលរបស់ពូសំ<br>- ចំណូលថេរ<br>- ចំណូលពីប្រភពផ្សេងៗ<br>៤.៤- ការគ្រប់គ្រងថវិកាចំណូលរបស់ពូសំ<br>- ចំណាយប្រចាំថ្ងៃ<br>- ការសន្សំ<br>- ការបរិច្ចាគ | **វិជ្ជាសម្បទា**<br>- រៀបរាប់កិច្ចការប្រចាំថ្ងៃរបស់ពូសំ តាមអត្ថបទមេរៀន។<br>**បំណិនសម្បទា**<br>- សម្គាល់បាន និងអធិប្បាយអំពីការបង្កើនគុណសម្បត្តិដើម្បីមានកិត្តិនាម និងការគ្រប់គ្រងថវិកា ចំណូលរបស់ពូសំ តាមអត្ថបទមេរៀន។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការសន្សំគុណសម្បត្តិ ដើម្បីមានកិត្តិនាម<br>- ឱ្យតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា ផ្ទាល់ខ្លួន។ | ២ម៉ |
| **មេរៀនទី៥ : សមភាព សមធម៌ និងយុត្តិធម៌**<br>៥.១- អត្ថន័យនៃពាក្យ " សមភាព សមធម៌ និងយុត្តិធម៌ "<br>៥.២- សារៈសំខាន់នៃសមភាព សមធម៌និងយុត្តិធម៌ | **វិជ្ជាសម្បទា**<br>- ពន្យល់បានអ្វីជាសមភាព អ្វីជាសមធម៌ អ្វីជាយុត្តិធម៌ និងការប្រកាន់ខ្ជាប់អាកប្បកិរិយាប្រកបដោយយុត្តិធម៌។<br>**បំណិនសម្បទា**<br>- ឱ្យឧទាហរណ៍អំពីសមភាព សមធម៌ និងយុត្តិធម៌។<br>**ចរិយាសម្បទា**<br>- មានស្មារតីស្រឡាញ់សមភាព សមធម៌ និងយុត្តិធម៌ ។ | ២ម៉ |
| **មេរៀនទី៦ : ព្រហ្មវិហារធម៌**<br>៦.១- អត្ថន័យនៃព្រហ្មវិហារធម៌<br>៦.២- ធាតុនៃព្រហ្មវិហារធម៌<br>៦.៣- ការប្រកាន់ខ្ជាប់ព្រហ្មវិហារធម៌ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថាអ្វីជាព្រហ្មវិហារធម៌។<br>- រៀបរាប់បានធាតុទាំងបួននៃព្រហ្មវិហារធម៌។ | ២ម៉ |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- អនុវត្តខ្ជាប់ខ្ជួនធាតុនៃព្រហ្មវិហារធម៌ជាប្រចាំក្នុងការរស់នៅ<br>- រកធាតុព្រហ្មវិហារធម៌ដែលមាននៅក្នុងការគ្រប់គ្រងរបស់ឪពុកម្ដាយចំពោះកូន<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់គោរព និងផ្ដល់តម្លៃដល់បុគ្គលដែលមានព្រហ្មវិហារធម៌។ | |
| **ជំពូក៣ : សហគមន៍** | | |
| **មេរៀនទី១ : កូអរដោនេភូមិសាស្ត្រ**<br>១.១- ផែនទី<br>១.២- ភូគោល<br>- ខ្សែអេក្វាទ័រ<br>- ខ្សែស្រប<br>- ខ្សែបណ្ដោយ<br>- រយៈទទឹង<br>- រយៈបណ្ដោយ | **វិជ្ជាសម្បទា**<br>- បង្ហាញទីតាំងនៅលើផែនទីដោយប្រើប្រាស់ពាក្យរយៈទទឹង រយៈបណ្ដោយ អឌ្ឍគោលខាងជើង និងអឌ្ឍគោលខាងត្បូង។<br>**បំណិនសម្បទា**<br>- ចេះពីរបៀបកំណត់ពីកូអរដោនេភូមិសាស្ត្រ និងទីតាំងណាមួយនៅលើផែនទី<br>- ប្រើប្រាស់ផែនទីក្នុងការរៀនសូត្រ និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- ចូលចិត្តពិនិត្យ និងសង្កេតពីទីតាំង ភូមិសាស្ត្រនៅលើផែនទី និងភូគោល។ | ៦ម៉ |
| **មេរៀនទី២ : ប្រទេសកម្ពុជា**<br>២.១- របៀបគូរផែនទីកម្ពុជា<br>២.២- ស្ថានភាពភូមិសាស្ត្រ<br>- សណ្ឋានដី<br>- ផ្លូវទឹក<br>២.៣- បណ្ដាញគមនាគមន៍<br>២.៤- តំបន់ទេសចរណ៍<br>២.៥- ប្រជាជន | **វិជ្ជាសម្បទា**<br>- ពណ៌នាទីតាំងនៃប្រទេសកម្ពុជាដែលទាក់ទងនឹងស្ថានភាពភូមិសាស្ត្រ បណ្ដាញគមនាគមន៍ តំបន់ទេសចរណ៍សំខាន់ៗ និងប្រជាជនកម្ពុជា។<br>**បំណិនសម្បទា**<br>- កំណត់បានពីរបៀបគូរផែនទីប្រទេស កម្ពុជាដោយបង្ហាញពីបណ្ដាញគមនាគមន៍ និង តំបន់ទេសចរណ៍<br>- បង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធផ្លូវទឹកនិងលក្ខខណ្ឌធម្មជាតិផ្សេងៗទៀត (ធនធានធម្មជាតិ)។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្នេហាមាតុភូមិនិងមានគំនិតអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈវិស័យ ទេសចរណ៍ និងគមនាគមន៍។ | ៦ម៉ |
| **មេរៀនទី ៣ : សច្ចមនាស្ត្រនិយម : «កោះសន្តិភាព»**<br>**សិក្សាបញ្ញត្តិ :** កោះសន្តិភាព មនុស្សសំខាន់ ស្នាដៃ ថ្នៃប្រឌិត ឯករាជ្យ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីស្នាព្រះហស្តរបស់ព្រះបាទ នរោត្តម សីហនុ<br>- ពណ៌នាពីបុគ្គលសំខាន់ៗមួយចំនួនដែលមានស្នាដៃក្នុងនយោបាយ សិល្បៈ អក្សរសាស្ត្រ និងស្ថាបត្យកម្ម។ | ៦ម៉ |

| | | |
|---|---|---|
| បង្រួបបង្រួមជាតិ កសាងជាតិ<br>បិតាឯករាជ្យជាតិ<br>**មាតិកា :**<br>៣.១- ព្រះបាទនរោត្តម សីហនុ និងការ<br>អប់រំ<br>ក. ជីវប្រវត្តិ<br>ខ. ការគ្រងរាជ្យ<br>គ. ស្នាព្រះហស្ត<br>ឃ. បិតាឯករាជ្យជាតិ<br><br>**សំណួរត្រិះរិះ** :<br>• តើព្រះបាទ នរោត្តម សីហនុ បានបន្សល់ទុកស្នាព្រះហស្ត និងបេតិកភណ្ឌអ្វីខ្លះសម្រាប់ជាប្រយោជន៍ ដល់ខ្មែរបច្ចុប្បន្ន?<br>• តើហេដ្ឋារចនាសម្ព័ន្ធអប់រំ ដែលបានបន្សល់ទុកពីសង្គមរាស្ត្រនិយមមានអ្វីខ្លះ និងនៅកន្លែងណាខ្លះ?<br>• តើចរិយាវិជ្ជមានដែលមនុស្សជំនាន់ក្រោយត្រូវរៀនសូត្រពីព្រះបាទនរោត្តម សីហនុ មានអ្វីខ្លះ?<br>៣.២- បុគ្គលសំខាន់ៗ<br>ក. ជួន ណាត និងអក្សរសាស្ត្រខ្មែរ<br>ខ. វណ្ណ មូលីវណ្ណ និងនគរូបនីយកម្ម<br>គ. សោហឺ និងការអប់រំ<br>ឃ. ស៊ិន ស៊ីសាមុត និងសិល្បៈខ្មែរ<br>**សំណួរត្រិះរិះ** :<br>• តើសម័យសង្គមរាស្ត្រនិយមមានបុគ្គលណាខ្លះគួរចងចាំ?<br>• តើបុគ្គលសំខាន់ៗ បានសាងស្នាដៃ ឬបង្កើតតម្លៃអ្វីខ្លះដែលមនុស្សជំនាន់ក្រោយត្រូវចងចាំ?<br>• តើចរិយាវិជ្ជមានដែលមនុស្សជំនាន់ក្រោយត្រូវរៀនសូត្រពី | **បំណិនសម្បទា**<br>- វិភាគគោលការណ៍ដឹកនាំរបស់ព្រះបាទ នរោត្តមសីហនុ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍការប្រព្រឹត្តវិជ្ជមាន ក្នុងការថែរក្សាមរតកប្រវត្តិសាស្ត្រ។ | |

| | | |
|---|---|---|
| មនុស្សសំខាន់ៗក្នុងសម័យសង្គមរាស្ត្រនិយមមានអ្វីខ្លះ?<br>៣.៣- កោះសន្តិភាព<br>**សំណួរត្រិះរិះ** :<br>• តើព្រះបាទនរោត្តមសីហនុបានប្រើគោលវិធីអ្វីខ្លះក្នុងការដឹកនាំប្រទេសកម្ពុជាឱ្យក្លាយជា«កោះសន្តិភាព»?<br>• ក្នុងនាមជាកុមារដែលមានការទទួលខុសត្រូវតើត្រូវប្រកាន់ចរិយាបែបណាខ្លះ ដើម្បីមានសមត្ថភាពបង្កើតស្នាដៃជាប្រយោជន៍ដល់សង្គម? | | |
| **មេរៀនទី ៤** : **សាធារណរដ្ឋខ្មែរ និងការផ្លាស់ប្តូរ**<br>**សិក្សាបញ្ញត្តិ** : ទីប្រជុំជន ជនបទ បុគ្គលសំខាន់ៗ មរតក<br>**មាតិកា** :<br>៤.១- តំបន់គ្រប់គ្រងនៃរបបសាធារណរដ្ឋខ្មែរ<br>**សំណួរត្រិះរិះ** :<br>• តើវិសាលភាពទឹកដីក្នុងរបបសាធារណរដ្ឋខ្មែរមានការប្រែប្រួលដូចម្តេច?<br>• ហេតុអ្វីបានជាវិសាលភាពទឹកដីខ្មែរមានការប្រែប្រួល?<br>៤.២- ជីវភាពរស់នៅរបស់ប្រជាជន<br>**សំណួរត្រិះរិះ** :<br>• តើជីវភាពរស់នៅរបស់ប្រជាជននៅទីប្រជុំជន និងជនបទមានលក្ខណៈដូចម្តេច?<br>៤.៣- បុគ្គលសំខាន់ៗ និងភាពជាអ្នកដឹកនាំ<br>ក. លន់ នល់ និងការប្តូររបប<br>ខ. ស៊ីសុវត្ថិសិរិមតៈ និងការលះបង់<br>គ. សឺង ង៉ុកថាញ់ និងការតស៊ូ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវិសាលភាពទឹកដីក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ<br>- ពណ៌នាពីទិដ្ឋភាពទីប្រជុំជន និងជនបទក្នុងរបបសាធារណរដ្ឋខ្មែរ។<br>**បំណិនសម្បទា**<br>- វិភាគពីភាពជាអ្នកដឹកនាំរបស់ថ្នាក់ដឹកនាំសំខាន់ៗក្នុងរបបសាធារណរដ្ឋខ្មែរ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍការប្រព្រឹត្តវិជ្ជមានក្នុងការថែរក្សាមរតកប្រវត្តិសាស្ត្រ។ | ៥ម៉ |

| | | |
|---|---|---|
| ឃ. ឡុង បូរ៉េត និងភក្តីភាព<br>ង. លន់ ណុន និងយុទ្ធសាស្ត្រ<br>**សំណួរត្រិះរិះ** :<br>• តើលន់នល់មានឆន្ទៈដោះស្រាយបញ្ហាជាតិយ៉ាងដូចម្ដេច?<br>• តើស៊ីសុវត្ថិ សិរិមតៈមានស្មារតីលះបង់ដើម្បីប្រជាជាតិខ្មែរយ៉ាងដូចម្ដេច?<br>• តើសឹង ង៉ុកថាញ់មានស្មារតីតស៊ូដើម្បីប្រជាជាតិខ្មែរយ៉ាងដូចម្ដេចខ្លះ?<br>• តើឡុង បូរ៉េត ស្មោះត្រង់ចំពោះរបបសាធារណរដ្ឋខ្មែរ និងប្រជាជនខ្មែរយ៉ាងដូចម្ដេចខ្លះ?<br>• តើសកម្មភាពរបស់លន់ ណុនបានជះឥទ្ធិពលអ្វីដល់ជាតិខ្មែរ?<br>៤.៤- មរតកប្រវត្តិសាស្ត្រ<br>ក. ការបណ្ដុះគំនិតជាតិនិយម<br>ខ. ការបង្កើតវិទ្យាស្ថានខ្មែរមន<br>គ. ការជំរុញស្មារតីកតញ្ញូ<br>**សំណួរត្រិះរិះ** :<br>• តើមេដឹកនាំរបបសាធារណរដ្ឋខ្មែរចូលរួមកសាង និងថែរក្សាមរតកខ្មែរយ៉ាងដូចម្ដេចខ្លះក្នុងកាលៈទេសៈលំបាក? | | |
| **មេរៀនទី៥** : **ការចៀសវាងគ្រោះថ្នាក់ចរាចរណ៍**<br>៥.១- មូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍<br>៥.២- ឥរិយាបថមានសុវត្ថិភាព និងមានគ្រោះថ្នាក់<br>៥.៣- ការជិះកង់តាមផ្លូវសាធារណៈ<br>៥.៤- ទំនួលខុសត្រូវក្នុងការធ្វើដំណើរ<br>៥.៥- ដំណើរទៅសាលារៀនថ្មី (សិស្សឆ្លងភូមិសិក្សា) | **វិជ្ជាសម្បទា**<br>- ប្រាប់បានអំពីមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍<br>- រៀបរាប់វិធីនៃការចៀសផុតពីគ្រោះថ្នាក់ចរាចរណ៍នៅពេលជិះ<br>- កង់ និងធ្វើដំណើរតាមផ្លូវសាធារណៈ។<br>**បំណិនសម្បទា**<br>- កំណត់បានមូលហេតុសំខាន់ៗនិងវិធីដែលចៀសផុតគ្រោះថ្នាក់ចរាចរណ៍។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចនៅពេលធ្វើដំណើរតាមផ្លូវសាធារណៈ<br>- គោរព និងអនុវត្តច្បាប់ចរាចរណ៍គ្រប់ពេលវេលានៅពេល | ២ម៉ |

| | | |
|---|---|---|
| | ធ្វើដំណើរ ។ | |
| **មេរៀនទី៦ : ការអប់រំសាសនា**<br>៦.១- គោលការណ៍អប់រំសំខាន់ៗ<br>របស់ព្រះពុទ្ធសាសនា<br>៦.២- គោលការណ៍អប់រំសំខាន់ៗនៃ<br>សាសនាគ្រិស្ត<br>៦.៣- គោលការណ៍អប់រំសំខាន់ៗនៃ<br>សាសនាអ៊ីស្លាម<br>៦.៤- ការរស់នៅដោយសុខដុមរមនា | **វិជ្ជាសម្បទា**<br>- ពន្យល់គោលការណ៍អប់រំរបស់ព្រះពុទ្ធសាសនា គ្រិស្តសាសនា និងអ៊ីស្លាមសាសនា។<br>**បំណិនសម្បទា**<br>- គោរពនិងប្រតិបត្តិតាមគោលការណ៍អប់រំសាសនារៀងៗខ្លួន។<br>**ចរិយាសម្បទា**<br>- ចេះរួមរស់នៅជាមួយគ្នាដោយសុខសន្តិភាព មិនមានការរើសអើងសាសនា។ | ៣ម៉ |
| **មេរៀនទី៧ : ការសម្រេចចិត្តនិងការដោះស្រាយបញ្ហា**<br>៧.១- លំនាំនៃការធ្វើសេចក្តីសម្រេចចិត្ត<br>៧.២- វិធីដោះស្រាយបញ្ហា | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីលំនាំនៃការធ្វើសេចក្តីសម្រេចចិត្តនិងវិធីដោះស្រាយបញ្ហា។<br>**បំណិនសម្បទា**<br>- បង្ហាញអំពីវិធីដែលមានប្រសិទ្ធភាពក្នុងការសម្រេចចិត្តនិងដោះស្រាយបញ្ហានៅផ្ទះ សាលារៀន និងនៅសហគមន៍<br>- ចូលរួមសម្តែងតួបង្ហាញអំពីការសម្រេចចិត្តនិងការដោះស្រាយបញ្ហា។<br>**ចរិយាសម្បទា**<br>- មានស្មារតីធ្វើការសម្រេចចិត្តក្នុងផ្លូវត្រឹមត្រូវនិងដោះស្រាយបញ្ហាដោយសន្តិវិធី។ | ២ម៉ |
| **ជំពូក៤ : ស្រុកខ្ញុំ** | | |
| **មេរៀនទី ១ : កម្ពុជាប្រជាធិបតេយ្យ និងសោកនាដកម្ម**<br>**សិក្សាបញ្ញត្តិ :** ខ្មែរក្រហម អង្គការសិទ្ធិកុមារ ពលកម្មកុមារ កងចល័តកុមារ កងកុមារភូមិ ហិង្សាលើកុមារ ក្រមសីលធម៌<br>**មាតិកា ៖**<br>១.១- មេដឹកនាំខ្មែរក្រហម<br>ក. ប៉ុល ពត<br>ខ. នួន ជា<br>គ. អៀង សារី<br>ឃ. ខៀវ សំផន<br>**សំណួរគន្លឹះ :** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>- រៀបរាប់ពីជីវភាពរបស់កុមាររស់ក្នុងកងចល័តកុមារ និងកងកុមារភូមិ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>- ប្រាប់ពីពលកម្មកុមារ និងអំពើហិង្សាលើកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>- ប្រាប់ពីការដ្ឋានពលកម្មធំៗ ដែលកុមារចូលរួមដោយបង្ខំ ដូចជាលើកទំនប់ ជីកប្រឡាយ និងអាងទឹក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>- ប្រាប់ពីមន្ទីរសន្តិសុខធំៗ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<br>- រៀបរាប់ពីភូមិសាស្ត្ររដ្ឋបាល នៃរបបកម្ពុជាប្រជាធិបតេយ្យ។ | ៦ម៉ |

| | | |
|---|---|---|
| • តើអ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ?<br>• តើមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យប្រកាន់គោលការណ៍ និងទ្រឹស្តីដឹកនាំប្រទេសបែបណាខ្លះ ទើបនាំប្រទេសកម្ពុជាឱ្យក្លាយជាវាលពិឃាដ?<br>១.២- ជីវភាព និងការរស់នៅ<br>**សំណួរត្រិះរិះ** :<br>• តើកុមារត្រូវបានគេបង្ខំឱ្យធ្វើពលកម្មប្រភេទអ្វីខ្លះ?<br>• តើកងចល័តកុមារ និងកងកុមារភូមិជាអ្វី និងទម្រង់យ៉ាងដូចម្តេច?<br>១.៣- ពលកម្ម និងហិង្សា<br>**សំណួរត្រិះរិះ** :<br>• តើកុមារត្រូវប្រឈមនឹងគ្រោះថ្នាក់ និងអំពើរំលោភសិទ្ធិបែបណាខ្លះ?<br>• តើហេតុអ្វីបានជាកុមារត្រូវគេបង្ខំឱ្យធ្វើពលកម្មធ្ងន់ធ្ងរ និងបំបាត់សិទ្ធិ?<br>• តើកុមាររស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបាត់បង់សិទ្ធិអ្វីខ្លះ?<br>• តើទារុណកម្ម ការរំលោភសិទ្ធិ និងពលកម្មកុមារដោយបង្ខំ បង្កផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់ផ្លូវចិត្តរបស់មនុស្សដែលបានឆ្លងកាត់កុមារភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?<br>១.៤- ទីកន្លែងប្រវត្តិសាស្ត្រ<br>**សំណួរត្រិះរិះ** :<br>• តើការដ្ឋានដែលកុមារត្រូវគេបង្ខំឱ្យចូលរួម មានទីតាំងនៅកន្លែង | **បំណិនសម្បទា**<br>- វិភាគពីផលប៉ះពាល់នៃពលកម្មកុមារដោយបង្ខំ ពីការរំលោភសិទ្ធិកុមារ ឬពីជីវភាពកុមារក្នុងកងចល័ត របស់បុគ្គលណាម្នាក់ ដែលបានឆ្លងកាត់កុមារភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីទង្វើវិជ្ជមានក្នុងការបង្កើតបរិយាកាសសង្គមយោគយល់ អធ្យាស្រ័យ និងរស់ជាមួយគ្នាដោយក្តីសុខ។ | |

| | | |
|---|---|---|
| ណាខ្លះ និងមានស្ថានភាពដូចម្តេចខ្លះ?<br>• តើមន្ទីរសន្តិសុខធំៗ មានឈ្មោះអ្វី និងទីតាំងនៅកន្លែងណាខ្លះ?<br>• តើមន្ទីរសន្តិសុខ ត្រូវបានបង្កើតក្នុងគោលបំណងអ្វី?<br>• តើរបបកម្ពុជាប្រជាធិបតេយ្យបានបែងចែកភូមិសាស្ត្ររដ្ឋបាលជាប៉ុន្មានភូមិភាគ និងមានឈ្មោះអ្វីខ្លះ?<br>• តើភូមិភាគណាខ្លះដែលកុមារទទួលរងគ្រោះធ្ងន់ធ្ងរ និងស្លាប់ច្រើន?<br>១.៥- ពលរដ្ឋសកល និងសេចក្តីសុខ<br>**សំណួរគន្លឹះ** :<br>• ក្នុងនាមជាពលរដ្ឋដែលមានការទទួលខុសត្រូវ តើត្រូវគិត និងប្រព្រឹត្តដូចម្តេចខ្លះ ដើម្បីលើកកម្ពស់សិទ្ធិកុមារ?<br>• ដើម្បីបង្កើតសេចក្តីសុខដល់ខ្លួនឯង និងអ្នកដទៃ តើត្រូវប្រកាន់ខ្ជាប់ការទទួលខុសត្រូវដូចម្តេច? | | |
| **មេរៀនទី២** : **សេរីភាព**<br>២.១- អត្ថន័យនៃពាក្យ " សេរីភាព "<br>២.២- សារៈសំខាន់នៃសេរីភាព<br>២.៣- ការប្រើប្រាស់សេរីភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានអត្ថន័យនៃពាក្យថា"សេរីភាព"និងសារៈសំខាន់នៃសេរីភាព<br>- រៀបរាប់ពីការប្រើប្រាស់សេរីភាព ត្រូវស្ថិតនៅក្នុង ក្របខណ្ឌច្បាប់។<br>**បំណិនសម្បទា**<br>- ឆ្លុះបញ្ចាំងអំពីក្របខណ្ឌនៃការប្រើប្រាស់សេរីភាពរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់សេរីភាពរបស់ខ្លួន មិនឱ្យប៉ះពាល់សិទ្ធិអ្នកដទៃ។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី ៣ : របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា**<br>**សិក្សាបញ្ញត្តិ :** ជម្លោះ ក្រុមសីលធម៌ សម្ព័ន្ធត្រីភាគី សិទ្ធិកុមារ ចលនាតស៊ូ សាមគ្គីភាព បង្រួបបង្រួមជាតិ សន្តិភាព<br>**មាតិកា :**<br>សេចក្ដីផ្ដើម<br>៣.១- សេរីភាព និងសិទ្ធិមនុស្ស<br>ក. សេរីភាព និងការរស់នៅ<br>ខ. កុមារ និងការអប់រំ<br>គ. ក្រុមសាមគ្គីបង្កបង្កើនផល<br>**សំណួរត្រិះរិះ :**<br>• តើប្រជាជន មានសេរីភាពបែបណាខ្លះ?<br>• តើកុមារបានទទួលសិទ្ធិអ្វីខ្លះ?<br>• ហេតុអ្វីបានជារដ្ឋាភិបាលបង្កើតក្រុមសាមគ្គីបង្កបង្កើនផល?<br>៣.២- សន្តិភាព និងការអភិវឌ្ឍ<br>ក. សម្ព័ន្ធត្រីភាគី និងការតស៊ូ<br>ខ. ការចរចា និងសន្តិភាព<br>**សំណួរត្រិះរិះ :**<br>• តើគំនិតផ្ដួចផ្ដើមចរចា និងបង្រួបបង្រួមជាតិ បានផ្ដល់ប្រយោជន៍ដល់សន្តិភាពមកដល់បច្ចុប្បន្ន? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរស់ឡើងវិញនៃសេរីភាព សិទ្ធិមនុស្ស និងជីវភាពរស់នៅ<br>**បំណិនសម្បទា**<br>- វិភាគគំនិតផ្ដួចផ្ដើមបង្រួបបង្រួមជាតិរបស់រដ្ឋាភិបាលទីក្រុងភ្នំពេញ ជាមួយសម្ព័ន្ធត្រីភាគី<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការរួមចំណែករបស់ភាគីរដ្ឋាភិបាលទីក្រុងភ្នំពេញ និងថ្នាក់ដឹកនាំចលនាតស៊ូត្រីភាគី ក្នុងការបង្រួបបង្រួមជាតិ និងបង្កើតសន្តិភាព។ | ៥ម៉ |
| **មេរៀនទី៤ : កិច្ចការពារខ្លួនឱ្យរួចផុតពីការរំលោភផ្លូវភេទ**<br>៤.១- ការរំលោភបំពានផ្លូវភេទ<br>៤.២- វិធីការពារខ្លួនរបស់កុមារ<br>៤.៣- បណ្ដាញទំនាក់ទំនងសម្រាប់ជួយកុមារ | **វិជ្ជាសម្បទា**<br>- ពណ៌នាពីការរំលោភបំពានផ្លូវភេទលើកុមារ និងរបៀបទាក់ទង<br>- ជាមួយនឹងអ្នកដែលអាចជួយការពារសុវត្ថិភាពបាន។<br>**បំណិនសម្បទា**<br>- ឱ្យឧទាហរណ៍ពីរបៀបការពារខ្លួនឱ្យចៀសផុតពីការរំលោភបំពានផ្លូវភេទ<br>- បង្ហាញពីវិធីទំនាក់ទំនងជាមួយបណ្ដាញផ្សេងៗសម្រាប់ជួយកុមារឱ្យចៀសផុតពីការគំរាមកំហែងការរំលោភផ្លូវភេទ។ | ២ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្ន ការពារខ្លួន និងមិត្តភក្តិ ឱ្យចៀសផុតពីការប៉ុនប៉ងរំលោភបំពានផ្លូវភេទ។ | |
| **មេរៀនទី៥ : ការញែកសំរាម ឬសំណល់ផ្សេងៗ និងការផ្សំជីកំប៉ុស**<br>៥.១- រំឭកឡើងវិញអំពីការញែកសំរាម និងការផ្សំជីកំប៉ុសគោក និង ដីកំប៉ុសទឹក<br>៥.២- កិច្ចការប្រតិបត្តិក្រៅថ្នាក់រៀន | **វិជ្ជាសម្បទា**<br>- រៀបរាប់វិធីញែកសំរាម ឬសំណល់ផ្សេងៗតាមប្រភេទ និងវិធីផ្សំជីកំប៉ុស។<br>**បំណិនសម្បទា**<br>- ទុកដាក់សំរាមដោយ ឬសំណល់ផ្សេងៗដោយញែកតាមប្រភេទ និងផ្សំជីកំប៉ុស។<br>**ចរិយាសម្បទា**<br>- រក្សាទម្លាប់ទុកដាក់សំរាម ឬសំណល់ផ្សេងៗតាមប្រភេទ។ | ២ម៉ |
| **មេរៀនទី៦ : រួមគ្នាមិនប្រព្រឹត្តអំពើពុករលួយ**<br>៦.១- អត្ថន័យនៃពាក្យ: ការប្រយុទ្ធប្រឆាំងអំពើពុករលួយ<br>៦.២- មូលហេតុ  និងផលវិបាកនៃអំពើពុករលួយ<br>៦.៣- ករណីសិក្សា | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីសកម្មភាពផ្សេងៗក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ។<br>**បំណិនសម្បទា**<br>- បង្ហាញមូលហេតុ និងផលវិបាកនៃអំពើពុករលួយ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ផ្នត់គំនិតនិងចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ | ៣ម៉ |
| **មេរៀនទី៧ : ស្ថាប័នហិរញ្ញវត្ថុ**<br>៧.១- ធនាគារពាណិជ្ជ<br>៧.២- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ<br>៧.៣- ការប្រើប្រាស់ សេវាកម្មនិង ផលិតផលផ្សេងៗរបស់ធនាគារ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រភេទស្ថាប័នហិរញ្ញវត្ថុ។<br>**បំណិនសម្បទា**<br>- បង្ហាញភាពខុសគ្នារវាងស្ថាប័នទាំងពីរ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃមុខងាររបស់ស្ថាប័នហិរញ្ញវត្ថុ។ | ២ម៉ |
| **ជំពូក៥ : សង្គមជាតិ** | | |
| **មេរៀនទី១ : ជាតិសាសន៍នៅលើពិភពលោក**<br>១.១- លក្ខណៈទូទៅនៃជាតិសាសន៍<br>១.២- ជនជាតិស្បែកស<br>- លក្ខណៈរូបសាស្ត្រ<br>- លក្ខណៈអរិយធម៌<br>១.៣- ជនជាតិស្បែកលឿង<br>- លក្ខណៈរូបសាស្ត្រ<br>- លក្ខណៈអរិយធម៌<br>១.៤- ជនជាតិស្បែកខ្មៅ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីលក្ខណៈទូទៅរបស់ជាតិសាសន៍និងអរិយធម៌របស់ជនជាតិនីមួយៗរបស់ជាតិសាស្ត្រទាំងពីរ។<br>**បំណិនសម្បទា**<br>- បែងចែកបានពីភាពខុសគ្នានៃលក្ខណៈទូទៅនិងអរិយធម៌របស់ជាតិសាសន៍នីមួយៗ។<br>**ចរិយាសម្បទា**<br>- មានគំនិតសាមគ្គីភាពរវាងជាតិសាសន៍នីមួយៗ ។ | ៤ម៉ |

| | | |
|---|---|---|
| - លក្ខណៈរូបសាស្ត្រ<br>- លក្ខណៈអរិយធម៌ | | |
| **មេរៀនទី២** : **បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍**<br>២.១- ប្រទេសថៃ<br>២.២- ប្រទេសហ្វីលីពីន<br>២.៣- ប្រទេសម៉ាឡេស៊ី<br>២.៤- ប្រទេសសិង្ហបុរី<br>២.៥- ប្រទេសឡាវ<br>២.៦- ប្រទេសមីយ៉ាន់ម៉ា<br>២.៧- ប្រទេសឥណ្ឌូណេស៊ី<br>២.៨- ប្រទេសទីម័រខាងកើត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ឈ្មោះប្រទេស រាជធានី ឬរដ្ឋធានី ក្រឡាផ្ទៃចំនួនប្រជាជន របបនយោបាយ និងរូបិយប័ណ្ណប្រទេស។<br>**បំណិនសម្បទា**<br>- កំណត់បានពីរដ្ឋ/រាជធានីនិងរូបិយប័ណ្ណ និងរបបនយោបាយនៅបណ្តាបណ្តាប្រទេសអាស៊ីអាគ្នេយ៍។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្នេហាមាតុភូមិនិងមានគំនិតអភិវឌ្ឍប្រទេសជាតិ ។ | **៦ម៉** |
| **មេរៀនទី៣** : **អំណាចតុលាការ**<br>៣.១- ប្រាប់បានពីពាក្យ តុលាការ<br>៣.២- ស្ថាប័នតុលាការ<br>៣.៣- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នតុលាការ<br>៣.៤- ការអនុវត្តច្បាប់ដោយមិនមានការរើសអើង | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីពាក្យ តុលាការ។<br>- រៀបរាប់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នតុលាការ។<br>**បំណិនសម្បទា**<br>- កំណត់បានពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នតុលាការ។<br>**ចរិយាសម្បទា**<br>- ចូលរួមសហការក្នុងការអនុវត្តច្បាប់ ។ | ២ម៉ |
| **មេរៀនទី ៤** : **ព្រះរាជាណាចក្រទី២ និងឆន្ទៈរួមក្នុងការដោះស្រាយបញ្ហា**<br>**សិក្សាបញ្ញត្តិ** : បង្រួបបង្រួម ផ្សះផ្សាឯកភាពជាតិ ការបោះឆ្នោត ប្រជាធិបតេយ្យ ការចូលរួម អភិវឌ្ឍន៍ ស្មារជាតិនយោបាយឈ្នះ-ឈ្នះ ស្ថិរភាព<br>**មាតិកា** :<br>៤.១- សន្តិភាព និងពហិការ<br>**សំណួរគន្លឹះ** :<br>• ហេតុអ្វីបានជាក្រុមខ្មែរក្រហមចូលរួមក្នុងដំណើរការចរចាសន្តិភាព?<br>• តើហេតុអ្វីបានជាភាគីខ្មែរក្រហមមិនចូលរួមការបោះឆ្នោត១៩៩៣ | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីការផ្តាច់ខ្លួនមិនចូលរួមបោះឆ្នោត និងការបង្កើតតំបន់អបគមន៍របស់ភាគីខ្មែរក្រហម<br>- រៀបរាប់ពីការយោគយល់គ្នារបស់អ្នកនយោបាយខ្មែរ ដើម្បីប្រជាធិបតេយ្យ និងការបោះឆ្នោតនៅកម្ពុជា<br>- ប្រាប់ពីវិធីផ្សះផ្សាជាតិដែលត្រូវបានប្រើក្រោយការបោះឆ្នោត១៩៩៣<br>- ប្រាប់ពីលទ្ធផលនៃនយោបាយឈ្នះ-ឈ្នះរបស់អ្នកដឹកនាំខ្មែរ។<br>**បំណិនសម្បទា**<br>- វាយតម្លៃពីប្រយោជន៍នៃការឯកភាពជាតិក្រោយបោះឆ្នោតឆ្នាំ១៩៩៣។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យលើជម្រើសនៃដំណោះស្រាយជម្លោះនយោបាយខ្មែរចាប់ពីក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន។ | ៦ម៉ |

| | | |
|---|---|---|
| ហើយបង្កើតតំបន់អបគមន៍?<br>• តើតំបន់អបគមន៍របស់ក្រុមខ្មែរក្រហមនៅកន្លែងណាខ្លះ?<br>៤.២- គណបក្សនយោបាយ និងការបោះឆ្នោត<br>**សំណួរត្រិះរិះ** :<br>• តើមានគណបក្សអ្វីខ្លះ បានចូល រួមបោះឆ្នោតសកលក្នុងឆ្នាំ១៩៩៣?<br>• តើការយោគយល់គ្នា និងឱ្យតម្លៃគ្នា រវាងតំណាងបក្សនយោបាយដែលបានចូលរួមបោះឆ្នោតឆ្នាំ១៩៩៣ បានផ្ដល់ប្រយោជន៍អ្វីខ្លះដល់មនុស្សជំនាន់ក្រោយ?<br>៤.៣- វិបត្តិ និងការសម្រុះសម្រួល<br>**សំណួរត្រិះរិះ** :<br>• តើអ្នកនយោបាយខ្មែរបានប្រើវិធីអ្វីខ្លះដើម្បីដោះស្រាយវិបត្តិនយោបាយក្រោយបោះឆ្នោតឆ្នាំ១៩៩៣?<br>• តើវិធីដែលអ្នកនយោបាយបានប្រើដើម្បីផ្សះផ្សារជាតិក្រោយបោះឆ្នោតឆ្នាំ១៩៩៣ បានផ្ដល់ប្រយោជន៍អ្វីខ្លះ ដល់មនុស្សជំនាន់ក្រោយ?<br>៤.៤- សម្ដេចហ៊ុន សែន និងនយោបាយឈ្នះ-ឈ្នះ<br>**សំណួរត្រិះរិះ** :<br>• តើនយោបាយឈ្នះ-ឈ្នះជាអ្វី និងត្រូវបានអនុវត្តក្នុងស្ថានភាពនយោបាយបែបណា នៅកន្លែងណា និងនៅពេលណានៅកម្ពុជា?<br>• តើនយោបាយឈ្នះឈ្នះ បានផ្ដល់ប្រយោជន៍អ្វីខ្លះដល់សង្គមបច្ចុប្បន្ន? | | |

| | | |
|---|---|---|
| ៤.៥- លទ្ធិប្រជាធិបតេយ្យ និងចីរភាពអភិវឌ្ឍន៍<br>**សំណួរត្រិះរិះ** :<br>• តើស្ថិរភាពនយោបាយកើតឡើងដោយរបៀបណា?<br>• តើប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ កើតឡើងដោយរបៀបណា?<br>៤.៦- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• តើវិធីដោះស្រាយជម្លោះនយោបាយដែលត្រូវបានអនុវត្ត ចាប់ពីក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន មានអ្វីខ្លះ?<br>• តើវិធីដោះស្រាយវិបត្តិនយោបាយដែលត្រូវបានអនុវត្ត ចាប់ពីក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ? | | |
| **មេរៀនទី៥** : **ពិភពលោក**<br>៥.១- ទ្វីប<br>៥.២- ទំហំ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំនួនទ្វីប ឈ្មោះទ្វីបនិងទំហំ ដែលមានលើពិភពលោក។<br>**បំណិនសម្បទា**<br>- កំណត់បានពីទីតាំងទ្វីបនានា និងទីតាំងប្រទេសកម្ពុជាដែលមានលើពិភពលោក។<br>**ចរិយាសម្បទា**<br>- ចូលចិត្តពិនិត្យ និងសង្កេតពីទីតាំងនានានៅលើពិភពលោក | ៣ម៉ |
| **មេរៀនទី៧** : **ពិធីបុណ្យ និងសាសនា**<br>៧.១- ការរៀបចំពិធីបុណ្យចូលឆ្នាំ<br>៧.២- ការរៀបចំបុណ្យភ្ជុំបិណ្ឌ<br>៧.៣- ពិធីបុណ្យវ៉ាម៉ាដន<br>៧.៤- ពិធីបុណ្យគ្រិស្តសាសនា | **វិជ្ជាសម្បទា**<br>- ពន្យល់អត្ថន័យ និងរបៀបរៀបចំពិធីបុណ្យប្រពៃណីជាតិនិងអន្តរជាតិ ៖ ពិធីបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យវ៉ាម៉ាដន បុណ្យ គ្រឹស្តសាសនា ព្រមទាំងប្រាប់កាលបរិច្ឆេទ។<br>**បំណិនសម្បទា**<br>- បង្ហាញរបៀបរៀបចំពិធីបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យវ៉ាម៉ាដន បុណ្យគ្រិស្តសាសនា។<br>**ចរិយាសម្បទា**<br>- គោរព ស្រឡាញ់ ឱ្យតម្លៃ និងចូលរួមថែរក្សាបុណ្យប្រពៃណី។ | ២ម៉ |

| ជំពូក៦: កិច្ចការខ្ញុំ | | |
|---|---|---|
| **មេរៀនទី១ : ស្ងោរជ្រក់ត្រី**<br>១.១- គ្រឿងផ្សំ<br>១.២- របៀបធ្វើ<br>១.៣- គណនានិងប្រៀបធៀប ថ្លៃដើម និងតម្លៃលក់នៅលើទីផ្សារ<br>១.៤- ប្រភេទមុខម្ហូបស្ងោជ្រក់ដទៃទៀត | **ចំណេះសម្បទា**<br>- រៀបរាប់គ្រឿងផ្សំនិងវិធីធ្វើម្ហូបស្ងោរជ្រក់ត្រី ។<br>**បំណិនសម្បទា**<br>- គណនានិងប្រៀបធៀបថ្លៃដើម និងតម្លៃលក់លើទីផ្សារ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការធ្វើម្ហូបអាហារដោយខ្លួនឯង។ | ២ម៉ |
| **មេរៀនទី២ : តុ កៅអីឈើ**<br>២.១- រូបភាពតុកៅអីឈើតាមប្រភេទផ្សេងៗ<br>២.២- រូបភាពភាគផ្សំ និងការផ្គុំតុ<br>២.៣- រូបភាពភាគផ្សំ និងការផ្គុំកៅអី<br>២.៤- រូបភាព<br>២.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ឧបករណ៍សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការជួសជុល និងធ្វើតុកៅអី និងគ្រឿង សង្ហារិមមួយចំនួនដែលធ្វើ អំពីឈើ។<br>**បំណិនសម្បទា**<br>- ជួសជុល ឬធ្វើតុ ឬកៅអីឈើដែលមានទ្រង់ទ្រាយសាមញ្ញ។<br>**ចរិយាសម្បទា**<br>- បណ្តុះទម្លាប់ជួសជុលដើម្បីប្រើប្រាស់ឡើងវិញនូវវត្ថុប្រើប្រាស់ដែលមានការខូចខាត។ | ២ម៉ |
| **មេរៀនទី៣ : ថ្នេរផ្កាដូង**<br>៣.១- រូបភាព ថ្នេរផ្កាដូង<br>៣.២- ថ្នេរផ្កាដូងជាអ្វី?<br>៣.៣- សារប្រយោជន៍នៃថ្នេរផ្កាដូង<br>៣.៤- របៀបដេរ ថ្នេរផ្កាដូង<br>៣.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីវិធីដេរថ្នេរផ្កាដូងតាមស្នាមគំនូរ លើកំណាត់រនាំងបង្អួច។<br>**បំណិនសម្បទា**<br>- អនុវត្តការដេរថ្នេរផ្កាដូងលើកំណាត់រនាំងបង្អួច។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការដេរថ្នេរផ្កាដូងលើកំណាត់ ប្រើប្រាស់ផ្សេងៗ។ | ២ម៉ |
| **មេរៀនទី៤ : ផ្កាស្ពៃរឿង**<br>៤.១- រូបភាពផ្កាស្ពៃរឿងនៅលើដើម<br>៤.២-លក្ខណៈ រូបនៃផ្កាស្ពៃរឿង<br>៤.៣-សារប្រយោជន៍នៃផ្កាស្ពៃរឿង<br>៤.៤- របៀបដាំផ្កាស្ពៃរឿង<br>៤.៥- កិច្ចការប្រតិបត្តិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីវិធីដាំផ្កាស្ពៃរឿងក្នុងផើង។<br>**បំណិនសម្បទា**<br>- អនុវត្តរបៀបដាំផ្កាស្ពៃរឿង។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្តក្នុងការដាំផ្កាផ្សេងៗ។ | ២ម៉ |

## ៨- ឯកសារយោង


១- ក្រសួងអប់រំ យុវជន និងកីឡា (២០០៦) កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះ ទូទៅ ភ្នំពេញ : នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណា ចក្រកម្ពុជា។

២- ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ភ្នំពេញ : នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

៣- ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ក្របខណ្ឌកម្មវិធីសិក្សា ភ្នំពេញ : នាយកដ្ឋានអភិវឌ្ឍកម្មវិធី សិក្សានៃក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

៤- Prudential's initiative on Cha Ching (2016) - a three-minute musical cartoon series with an aim eSpend, and Donate: Mr. Pankaj Banerjee.

៥- Hall/Lieberman Web Site www.cengage.com/economics/hall

៦- ECONOMICS: Concepts and Choices

៧- គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥ ដល់ ២០០៩

៨- កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ ២០០៦

៩- កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ ២០០៦

១០- កម្មវិធីសិក្សាប្រទេសសិង្ហបុរីឆ្នាំ ២០១២

១១- កម្មវិធីសិក្សាលម្អិតអាស៊ានឆ្នាំ ២០១២

១២- ASEAN Curriculumn Sourcebook ២០១២

១៣- ការអប់រំភាពជាពលរដ្ឋសកល ប្រធានបទ និងវត្ថុបំណងនៃការសិក្សា UNESCO 2015

១៤- សៀវភៅសិក្សាសង្គមថ្នាក់ទី១ដល់ថ្នាក់ទី៦ឆ្នាំ ២០០៧

១៥- ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់បឋមសិក្សាឆ្នាំ ២០១៦

១៦- ការអប់រំស្តីពីសុវត្ថិភាពចរាចរណ៍បឋមសិក្សាឆ្នាំ ២០០៥

១៧- សៀវភៅកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៥-១៩៧៩ (មជ្ឈមណ្ឌលឯកសារកម្ពុជា)

១៨- ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៥

១៩- សុភាវធម៌ឆ្នាំ១៩៦០

២០- សៀវភៅបច្ចេកទេសជំនាញឈើ អ្នកនិពន្ធម៉ៅ សាខាន់ ឆ្នាំ១៩៨៨ គ្រឹះស្ថានបោះពុម្ពអប់រំភ្នំពេញ ទំព័រ១៩ "ការកាន់និងការប្រើប្រាស់សម្រាប់អារជ្រៀកបណ្តោយសាច់ឈើ"

២១- សៀវភៅគុណភាពជីវិតផ្តោតលើការអប់រំ សុខភាព អនាម័យ និង ទឹកស្អាត អ្នកនិពន្ធ លោកស្រី អ៊ឹងគឹមសានឆ្នាំ២០១០គ្រឹះស្ថានបោះពុម្ពអប់រំភ្នំពេញទំព័រ៣៣ដល់៧៤ "ទឹកដើម្បីសុខភាព" "ទឹកនិងបញ្ហាប្រឈមនាថ្ងៃអនាគត"

២២- សៀវភៅទំនៀមទម្លាប់និងប្រពៃណីខ្មែរ អ្នកនិពន្ធ ញ៉ិក នូវ ឆ្នាំ១៩៥៨ ចំណងជើងរង "ការនាំឱ្យស្គាល់" ទំព័រ ៥១ដល់៥៣ ចំណងជើងរង "ពណ៌សំពត់ស្លៀកតម្រូវតាមថ្ងៃ" ទំព័រ ៣៨និង៣៩ ចំណងជើងរង "បន្ទប់ទទួលភ្ញៀវ" ទំព័រ ៤០ដល់៤៣

២៣- សៀវភៅសម្បត្តិនារី អ្នកនិពន្ធ ស ចរិយា ចំណងជើង វិជ្ជាមេផ្ទះ និងអប់រំកុលបុត្រធីតា លេខ៥៥វិថីប៉ាស្ទ័រ (ភ្នំពេញ) ទំព័រ៨ដល់១៥ "ការរៀបចំផ្ទះសម្បែង បន្ទប់ទទួលភ្ញៀវ អនាម័យ"

២៤- សៀវភៅពលកម្មសិប្បកម្មថ្នាក់ទី១ អ្នកនិពន្ធ ហួត សេយ៉ោន ចុះថ្ងៃទី១៥ខែមិថុនា ឆ្នាំ១៩៩០ ចំណងជើងរង ការបត់ក្រដាស ទំព័រ៨ដល់១០

២៥- សៀវភៅលំនាំនៃការបត់ក្រដាស រៀបចំដោយអង្គការសន្តិស័្មគ្រចិត្ត(SVA) ចុះថ្ងៃទី៨ខែកក្កដា ឆ្នាំ ២០០២ នៅទីក្រុងភ្នំពេញ ចំណងជើង មូលដ្ឋានការបត់ក្រដាស

២៦- សៀវភៅបត់ក្រដាសជារូបចាប អ្នកនិពន្ធ ក.កាម៉ាគូរ៉ា(SVA) ឆ្នាំបោះពុម្ពលើកទី១ ថ្ងៃទី៨ខែកក្កដា ឆ្នាំ ២០០២ ភ្នំពេញ ទំព័រ២០ដល់២៦ ចំណងជើង "ផ្កា"និង"ចាបហើរ"

២៧- សៀវភៅGeneral Picture អ្នកនិពន្ធ សុខ ផល្លែន ចំណងជើង Fun and fast to learn Trace and Color

២៨- សៀវភៅបច្ចេកទេសជំនាញឈើ គ្រឹះស្ថានបោះពុម្ពក្រសួងអប់រំ ឆ្នាំ១៩៨៨ ភ្នំពេញ ចំណងជើង ពំនុះនិង ស្នាមកាត់ ទំព័រ៧១

២៩- សៀវភៅខ្លួនមនុស្សនិងសុខភាព អ្នកនិពន្ធវេជ្ជបណ្ឌិត ម៉ៅ ហេវ បោះពុម្ពឆ្នាំ២០០១ សម្រាប់ចំណេះទូទៅ ទំព័រ១១និង១២ ចំណងជើង "ឆាកជីវិតរបស់មនុស្ស"

៣០- សៀវភៅ ការធ្វើជីកំប៉ុស្ត អ្នកនិពន្ធកែវ គីណាល់ អំណោយពីអង្គការSIPARចំណងជើង កំប៉ុសគោក និង កំប៉ុសទឹក

៣១- សៀវភៅវិជ្ជាមេផ្ទះថ្នាក់ទី១០ ឆ្នាំបោះពុម្ពអប់រំ១៩៨៥ ភ្នំពេញ ទំព័រ៧១ដល់៧៤ ចំណងជើង"នារីនិងរូបកាយ ការសំអាតនិងកក់សក់ ការតុបតែងសក់"

៣២- សៀវភៅវិជ្ជាមេផ្ទះថ្នាក់ទី៨ ឆ្នាំបោះពុម្ពអប់រំ១៩៨៤ ភ្នំពេញ ទំព័រ៥២ ចំណងជើង"សង្ក្សាល្ពៅ"

៣៣- សៀវភៅ ការដេរនិងការប៉ះថ្នាក់ទី៧ ចំណងជើង"សម្ភារៈនិងឧបករណ៍ដេរនិងប៉ះព្រមទាំងថ្មេរ សំខាន់ៗ" ទំព័រ១១ដល់៣០

៣៤- សៀវភៅផលិតកម្មស្បៀង ជាលក្ខណៈគ្រួសារ ភាគ១ អំណោយពីអង្គការUNICEF

## ៩- បញ្ជីឈ្មោះគណៈកម្មការ

### គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**
២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**
៣- ឯកឧត្តមបណ្ឌិត **អ៊ឹម កុច**
៤- ឯកឧត្តម **យក់ ង៉ុយ**
៥- ឯកឧត្តម **ថោង ប៉្លាន**
៦- លោកជំទាវបណ្ឌិត **សឿ សុជាតា**
៧- លោកជំទាវ **យុន រចនា**
៨- ឯកឧត្តម **ហ៊ាង ស៊ីណេ**
៩- លោកជំទាវ **ទន់ សាអ៊ីម**
១០- ឯកឧត្តម **ពុត សាមិត្ត**
១១- ឯកឧត្តមបណ្ឌិត **ស៊ន សេងហុក**
១២- ឯកឧត្តម **ចាន់ សុភា**
១៣- លោកបណ្ឌិត **ម៉ុក សារ៉ុម**
១៤- លោក **ផោ សៀម**

### គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត

#### មុខវិជ្ជាសីលធម៌ពលរដ្ឋវិជ្ជា

១- ឯកឧត្តមបណ្ឌិត **ស៊ន សេងហុក**
២- លោកបណ្ឌិត **ម៉ុក សារ៉ុម**
៣- លោក **ឡុច ចាន់ថន**
៤- លោក **ប៉ូវ វី**
៥- លោកស្រី **នូ ចន្ទី**
៦- លោកបណ្ឌិត **ថៅ លិន**
៧- លោក **ង៉ែត ធឿន**
៨- លោក **មាស ជុតិមា**
៩- លោក **ប៉េង ទិត្យសុទ្ធី**
១០- លោក **ទែន គឹមតុន**
១១- លោកបណ្ឌិត **កាង ស៊ុងឆាង**
១២- លោក **ញឹម បាក់ងន**
១៣- លោក **សាម សារុំ**
១៤- លោក **ឡេង បូរី**
១៥- លោក **ប្រាក់ ពៅ**
១៦- លោក **ផ្លុង តូន**
១៧- លោក **ឃិន វណ្ណី**
១៨- លោក **បាន កក្កដា**
១៩- លោក **ជុំ សាម**
២០- លោកស្រី **ខូវ សោភ័ណ**
២១- លោក **សំ សែន**
២២- លោក **លុយ ឡែម**
២៣- លោក **លឹម ស៊ីវុឌ្ឍី**
២៤- លោក **ជា សៅវ៉ាន់ថន**

## មុខវិជ្ជាភូមិវិទ្យា

១- ឯកឧត្តម **ចាន់ សុភា**
២- លោក **ប៊ុន សិរី**
៣- លោក **ជុំ សុផល**
៤- លោក **ម៉ៅ សំរិទ្ធី**
៥- លោកស្រី **ឡុង ប៊ុនណាត**
៦- លោក **អេង វ៉ាត់**
៧- លោក **ឈុន រ៉ាមី**
៨- លោក **ផឺន ថុល**
៩- លោកស្រី **តឹក វណ្ណាផ័ត**
១០- លោកស្រី **ថោង ច័ន្ទដាវ័ណ**
១១- លោក **ហុង ពិដោរ**
១២- លោក **ប៉ុល សារិទ្ធ**
១៣- លោក **គង់ ហាក់**

## មុខវិជ្ជាប្រវត្តិវិទ្យា

១- ឯ.ឧ.បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**
២- ឯ.ឧ.បណ្ឌិតសភាចារ្យ **ស៊ន សំណាង**
៣- ល.សបណ្ឌិត **ឃួន វិច្ឆិកា**
៤- លោកបណ្ឌិត **វង់ សុធារ៉ា**
៥- លោក **មួង សុផាត**
៦- លោក **សំបូរ មាណ្ណារ៉ា**
៧- លោកបណ្ឌិត **ឌី ខាំបូលី**
៨- លោកបណ្ឌិត **តឹក មេង**
៩- លោក **ចេង ហុង**
១០- លោកស្រី **ជា កល្យាណ**
១១- លោក **ប៉ូ សុខា**
១២- លោក **ទី សុផល**
១៣- លោក **ណុប សុខា**
១៤- កញ្ញា **ហ៊ា ស៊ីវី**
១៥- លោក **មាស ភិរុណ**
១៦- លោក **អ៊ីវ សៅសុខា**
១៧- លោក **ស៊ីវ ធួន**
១៨- លោក **ឈឹម ឌីណា**
១៩- លោក **លី រមនី**

**ជំនួយការ**

២០- កញ្ញា **ជិត ចាន់វន្នី**
២១- លោកស្រី **ងួន សុខកែវ**
២២- លោកស្រី **ព្រីង ចាន់រស្មី**
២៣- លោក **ឃិន សុធា**
២៤- លោក **ចេង សីហា**
២៥- លោក **ហួត ប៊ុនថន**
២៦- លោក **ស៊ុន ផុន**
២៧- កញ្ញា **លន់ ម៉ាឡា**

## មុខវិជ្ជាគេហសេដ្ឋកិច្ចវិទ្យា

១- លោក **គួច គូលំអ**
២- លោក **សំ ចាន់ទិត**
៣- លោកស្រី **ជិន យ៉ាហន**
៤- លោក **ហេង វិបុល**
៥- លោក **ម៉ន មុនិន្ទ**
៦- លោកស្រី **ឃិន សាណូន**
៧- លោក **ឈិន វិត**
៨- លោក **យាវ ផលសាយ**
៩- លោក **ហង្ស ច័ន្ទសុវណ្ណ**
១០- លោកស្រី **វុយ សុភលក្ខិណា**
១១- កញ្ញា **ថោ ធារី**
១៣- លោក **លន លីណា**
១៤- លោក **ថុល ប៊ុនថាត**
១៥- លោកស្រី **មឿង ចាន់ផល្លី**
១៦- លោកស្រី **ជួង សុវណ្ណា**
១៧- លោកស្រី **កង សុថាវី**
១៨- លោក **ជឹម បូរាណ**
១៩- លោក **ញ៉ែម ភីណាផ័ត**
២០- លោក **ស្រ៊ុន ម៉ាទី**
២១- លោក **សឿង សុខៀន**
២២- លោក **អ៊ូច បុត្រខេមរ៉ា**
២៣- លោកស្រី **លាង រ័ត្នមុន្នី**

១២- កញ្ញា **ឈុន សូរីយា**

២៤- លោក **ផែង កុសល្យ**

២៥- កញ្ញា **ណាក់ ប៊ុណ្ណា**

## គណៈកម្មការត្រួតពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**

៣- ឯកឧត្តមបណ្ឌិត **ជេត ជាលី**

៤- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៥- លោក **យិន ធី**

៦- លោក **យឹម សារិន**

៧- លោក **ស៊ុន ប៊ុណ្ណា**

៨- លោក **វ៉ា វុទ្ធី**

## ជំនួយការបច្ចេកទេសកុំព្យូទ័រ

១- លោក **លឹម សុត្ថារិទ្ធ**

២- លោក **អេង វណ្ណារិទ្ធ**

៣- លោក **មឿន លិនណា**

៤- លោក **ជួន ថៃវ**

## លេខាធិការដ្ឋាន

១- លោកបណ្ឌិត **ម៉ុក សារ៉ុម**

២- លោកបណ្ឌិត **ជ័យ ចាន់អឿន**

៣- លោកបណ្ឌិត **ឃុន គឹមលាង**

៤- លោកបណ្ឌិត **ម៉ម សុជាតិ**

៥- លោក **អុន ស៊ីវុធថា**

៦- លោក **យិន ធី**

៧- លោក **យឹម សារិន**

៨- លោក **ហាក់ ធម្មតា**

៩- លោកស្រី **វ៉ាន់ លីណា**

កម្មវិធីសិក្សាលម្អិត មុខវិជ្ជា សិក្សាសង្គម សម្រាប់កម្រិតមធ្យមសិក្សា ២០១៨

**ចរិយាសម្បទា**

អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម
សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ការទទួលខុសត្រូវ
កាយសុខភាព
ចិត្តសុខភាព

**វិជ្ជាសម្បទា**

អក្ខរសាស្ត្រ
លេខសាស្ត្រ
ភាសាបរទេស
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

**បំណិនសម្បទា**

បំណិនពិចារណានិងការបង្កើតថ្មី
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
អនុវត្តចំណេះដឹងនិងជំនាញ